## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


**សារណាបញ្ចប់ការសិក្សា**

# នីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២០


តាក់តែងឡើងដោយ

និស្សិតឈ្មោះ: **គា កន្និកា**

**រុន យ៉ាដា**

សាស្ត្រាចារ្យណែនាំ

លោក **សួន ចំរើន**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១៣

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **គា កន្និកា** និង **រុន យ៉ាដា** ជានិស្សិតជំនាន់ទី១៣ ជំនាញធនាគារ និងហិរញ្ញវត្ថុនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យ វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ឆ្នាំសិក្សា ២០១៦-២០២០ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

**លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើតដល់កូន ចិញ្ចឹមបីបាច់ និងខិតខំជំនះរាល់ឧបសគ្គទាំងឡាយដើម្បីថែរក្សាដល់កូនព្រមទាំងផ្គត់ផ្គង់សម្ភារៈ និងថវិកាដល់ការសិក្សារបស់កូនជាដរាបរៀងមក។

**ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង លោក-លោកស្រីព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក-លោកស្រី ដែលជាសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនដល់យើងខ្ញុំអស់ពីកម្លាំងកាយចិត្ត ដោយយកចិត្តទុកដាក់ក្នុងរយៈពេលកន្លងមកនេះ។

**លោកសាស្ត្រាចារ្យ សួន ចំរើន** ដែលជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការណែនាំ ផ្តល់ជាគំនិត ជួយកែសម្រួលតម្រូវ តាំងពីដើមរហូតដល់បញ្ចប់ការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ។

**សិស្សច្បង** ដែលបានបន្សល់ទុកនូវស្នាដៃដែលជាឯកសារដ៏មានសារៈសំខាន់ចំពោះប្អូនៗជំនាន់ក្រោយយកមកធ្វើជាគំរូ សម្រាប់ការស្រាវជ្រាវបន្តទៀត។

យើងខ្ញុំទាំងពីររូប សូមជូនពរដល់លោកអ្នកមានគុណទាំងអស់ ឲ្យជួបតែសំណាងល្អ សុខភាពល្អ ប្រកបការងារទទួលបានជោគជ័យគ្រប់ពេលវេលា និងមានសេចក្តីសុខសុភមង្គល និងទទួលបានពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំជានិស្សិតជំនាន់ទី១៣ ជំនាញធនាគារ និងហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច មហាវិទ្យាល័យ វិទ្យាសាស្រ្តសេដ្ឋកិច្ច និងគ្រប់គ្រង កូដថ្នាក់ B4A1 ឆ្នាំសិក្សា២០១៦-២០២០ បានធ្វើការស្រាវជ្រាវ និងចងក្រងសារណានេះឡើងក្នុងគោលបំណងដើម្បីពង្រីកនូវចំណេះដឹង និងស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់ទៅលើនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនៅកម្ពុជា ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែងដែលបានឆ្លងកាត់តាមរយៈការសិក្សានៅសាកលវិទ្យាល័យអស់រយៈពេលបួនឆ្នាំកន្លងមក។ ចំណែកឯ ការសិក្សាស្រាវជ្រាវវិញ គឺជាវិធីសាស្រ្តដ៏ល្អមួយសម្រាប់បង្កើនចំណេះដឹងមួយកម្រិតទៀត អោយកាន់តែដឹង និងយល់ច្បាស់ហើយក៏ជម្រុញអោយការសិក្សារបស់យើងទទួលបានលទ្ធផលល្អ ក៏ដូចជាចំណេះដឹងកើនក្នុងខ្លួនកាន់តែច្រើន។

ដើម្បីសម្រេចបានជោគជ័យនៅក្នុងការរៀបចំជាសៀវភៅនេះឡើង យើងខ្ញុំបានខិតខំស្រាវជ្រាវ ព្រមទាំងមានការជួយជ្រោមជ្រែងពន្យល់ ណែនាំ និងការផ្តល់យោបល់ល្អៗរបស់សាស្រ្តាចារ្យដឹកនាំ។

ការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ គឺមានបំណងចង់អោយអ្នកទាំងអស់គ្នាយល់ដឹងបន្ថែម អំពីប្រធានបទ "នីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនៅកម្ពុជា" ដែលនឹងអាចជាទុនមួយសម្រាប់និស្សិតជំនាន់ក្រោយៗទុកជាគំរូឯកសារក្នុងការស្រាវជ្រាវបន្តទៀត។

យើងខ្ញុំជឿជាក់ថាកិច្ចការស្រាវជ្រាវនេះ នៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ តែទោះបីជាយ៉ាងណាក្តី យើងខ្ញុំសង្ឃឹមថា និស្សិត និងមិត្តអ្នកអានទាំងអស់ពិតជាមានការអធ្យាស្រ័យនូវរាល់កំហុសឆ្គងទាំងឡាយ ដែលកើតមានឡើងដោយអចេតនា។

# មាតិកា

អក្សរកាត់.......................................................................................vi
បញ្ជីរូបភាព....................................................................................... vii
បញ្ជីឧបសម្ព័ន្ធ.......................................................................................viii

# សេចក្តីផ្តើម

១. លំនាំបញ្ហា....................................................................................... ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ....................................................................................... ៣
៣. គោលបំណងនៃការស្រាវជ្រាវ....................................................................................... ៣
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.......................................................................................៤
៥. សារៈសំខាន់នៃការស្រាវជ្រាវ.......................................................................................៤
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ.......................................................................................៦
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.......................................................................................៦

# ជំពូកទី១

# រំលឹកទ្រឹស្តី

១.១. ប្រវត្តិនៃការកកើតទីផ្សារហ៊ុន.......................................................................................៨
១.២. ទីផ្សារមូលបត្រ.......................................................................................១០
១.៣. ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រកម្ពុជា....................................................................................... ១២
១.៣.១ ប្រវត្តិទីផ្សារមូលបត្រកម្ពុជា....................................................................................... ១២
១.៣.២ ការគ្រប់គ្រងទីផ្សារ.......................................................................................១៣
១.៤ ទីផ្សារដំបូង និងទីផ្សារបន្ទាប់.......................................................................................១៤
១.៤.១ ទីផ្សារដំបូង....................................................................................... ១៤
១.៤.២ ទីផ្សារបន្ទាប់....................................................................................... ១៤
១.៥ មូលបត្រ.......................................................................................១៥
១.៥.១ ប័ណ្ណភាគហ៊ុន....................................................................................... ១៦
១.៥.២ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត និងភាគហ៊ុនបុរិមា....................................................................................... ១៧
១.៥.២.១ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត....................................................................................... ១៧

១.៥.២.២ ភាគហ៊ុនបុរិមា ..... ១៨
១.៥.៣ ផលចំណេញដែលទទួលបានពីការវិនិយោគលើមូលបត្រ ..... ១៨
១.៥.៣.១ ភាគលាភ ..... ១៩
១.៥.៣.២ ប្រាក់ចំណេញមូលធន ..... ១៩
១.៦ គុណសម្បត្តិ និងគុណវិបត្តិរបស់ទីផ្សារមូលបត្រដល់សេដ្ឋកិច្ចជាតិ ..... ២០
១.៦.១. គុណសម្បត្តិរបស់ទីផ្សារមូលបត្រ ..... ២០
១.៦.២. គុណវិបត្តិរបស់ទីផ្សារមូលបត្រ ..... ២១

## ជំពូកទី២

## ស្ថានភាពទូទៅរបស់គណៈកម្មការមូលបត្រកម្ពុជា

២.១. ប្រវត្តិសង្ខេបរបស់គណៈកម្មការមូលបត្រកម្ពុជា ..... ២៣
២.២. ទីស្នាក់ការរបស់គណៈកម្មការមូលបត្រកម្ពុជា ..... ២៣
២.៣. រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា ..... ២៤
២.៣.១. រូបសញ្ញា ..... ២៤
២.៣.២. អត្ថន័យនៃរូបសញ្ញា ..... ២៥
២.៣.៣. មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា ..... ២៥
២.៣.៤. ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា ..... ២៦
២.៤. ចក្ខុវិស័យ និងបេសកកម្ម ..... ២៦
២.៤.១. ចក្ខុវិស័យ ..... ២៦
២.៤.២. បេសកកម្ម ..... ២៧
២.៥. គោលដៅ និងគោលបំណងទូទៅរបស់គណៈកម្មការមូលបត្រកម្ពុជា ..... ២៧
២.៦. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា ..... ២៨
២.៧. សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា ..... ២៨
២.៨. អង្គការចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា ..... ២៩
២.៨.១. រចនាសម្ព័ន្ធចាត់តាំង ..... ២៩
២.៨.២. នាយកដ្ឋាននីមួយៗ ..... ២៩
២.៨.២.១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ..... ២៩

២.៨.២.២. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ........................................................ ៣០
២.៨.២.៣. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ........................................................ ៣១
២.៨.២.៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ........................................................ ៣១
២.៨.២.៥. នាយកដ្ឋានកិច្ចការគតិយុត្ត ........................................................ ៣២
២.៨.២.៦. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ ......... ៣៣
២.៨.៣. អង្គភាពសវនកម្មផ្ទៃក្នុង ........................................................ ៣៣

## ជំពូកទី៣

## នីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

៣.១. និយមន័យទីផ្សារដំបូង ........................................................ ៣៥
៣.២. តើអ្វីទៅជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO)? ...................... ៣៥
៣.៣. មូលហេតុដែលក្រុមហ៊ុនធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO) .... ៣៥
៣.៤. ហានិភ័យនៃការជួញដូរមូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន ........................................................ ៣៦
៣.៥. ការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ ........................................................ ៣៦
៣.៥.១. គោលបំណង និងវិសាលភាពនៃអនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ............... ៣៦
៣.៥.២. ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ........................................................ ៣៧
៣.៥.៣. ការលើកទឹកចិត្តពន្ធកាត់ទុក ........................................................ ៣៨
៣.៦. តួអង្គសំខាន់ៗដែលចូលរួមក្នុងនីតិវិធីនៃការធ្វើ IPO ........................................................ ៣៨
៣.៦.១. និយ័តករមូលបត្រ ........................................................ ៣៨
៣.៦.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........................................................ ៣៨
៣.៦.៣. ក្រុមហ៊ុនធានាទិញមូលបត្រ ........................................................ ៣៩
៣.៦.៤. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ........................................................ ៤០
៣.៦.៥. វិនិយោគិនសាធារណៈ ........................................................ ៤១
៣.៧. លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ............................ ៤១
៣.៨. លក្ខខណ្ឌតម្រូវនៃការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ....................... ៤២
៣.៨.១. លក្ខខណ្ឌបរិមាណ ........................................................ ៤៣
៣.៨.២. លក្ខខណ្ឌគុណភាព ........................................................ ៤៣

៣.៩. នីតិវិធីនៃការធ្វើ IPO ........ ៤៤

៣.៩.១. ការដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ គ.ម.ក ........ ៤៤

៣.៩.២. ការដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ គ.ម.ក ........ ៤៥

៣.៩.៣. ការដាក់ឯកសារភ្ជាប់ ........ ៤៦

៣.១០. យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ........ ៤៨

៣.១០.១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ........ ៤៨

៣.១០.២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ ........ ៤៨

៣.១០.៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ........ ៤៩

៣.១០.៤. ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ........ ៤៩

៣.១០.៥. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ៤៩

៣.១០.៦. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងទទួលបានការអនុញ្ញាតជាគោលការណ៍សំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក ........ ៤៩

៣.១០.៧. ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ........ ៥០

៣.១០.៨. ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ៥០

៣.១០.៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក ........ ៥០

៣.១០.១០. ការធ្វើបរិវិសកម្មមូលបត្រ ........ ៥០

៣.១០.១១. ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ........ ៥១

៣.១០.១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ៥១

៣.១១. ករណីសិក្សារបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ........ ៥១

៣.១១.១. ទស្សនៈវិស័យ ........ ៥១

៣.១១.២. បេសកកម្ម ........ ៥១

៣.១១.៣. ព័ត៌មានទូទៅទាក់ទងនឹងមូលបត្រកម្មសិទ្ធិ ........ ៥២

៣.១១.៤. លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ........ ៥៣

៣.១១.៥. គោលនយោបាយភាគលាភរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ........ ៥៤

៣.១១.៦. លក្ខខណ្ឌនៃការបែងចែកភាគលាភ ..................... ៥៤
៣.១១.៧. ចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូង ..................... ៥៥
៣.១១.៨. សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូង ..................... ៥៥
៣.១២. ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ ..................... ៥៦
៣.១២.១. ចំណុចខ្លាំង ..................... ៥៦
៣.១២.២. ចំណុចខ្សោយ ..................... ៥៧

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..................... ៥៨
២. ការផ្តល់អនុសាសន៍ ..................... ៥៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# អក្សរកាត់

| | |
|---|---|
| គ.ម.ក | គណៈកម្មការមូលបត្រកម្ពុជា |
| ផ.ម.ក | ផ្សារមូលបត្រកម្ពុជា |
| IPO | Initial Public Offering |
| SECC | Securities and Exchange Commission of Cambodia |
| CSX | Cambodia Stock Exchange |
| ACLEDA | Associate of Cambodia Local Economic Development Agencies |

# បញ្ជីរូបភាព


រូបភាពទី១៖ ភាពខុសគ្នារវាងសញ្ញាបណ្ណ និងភាគហ៊ុន

រូបភាពទី២៖ ផែនទីទៅកាន់ ទីស្នាក់ការរបស់គណៈកម្មការមូលបត្រកម្ពុជា

រូបភាពទី៣៖ រូបសញ្ញារបស់គណៈកម្មការមូលបត្រ

រូបភាពទី៤៖ ត្រារបស់គណៈកម្មការមូលបត្រ

រូបភាពទី៥៖ រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មការមូលបត្រ

រូបភាពទី៦៖ ចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូង

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ០៧ កញ្ញា ២០០៧

ឧបសម្ព័ន្ធទី២៖ អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ០១អនក្រ.បក, ០៤ មករា ២០១៩

ឧបសម្ព័ន្ធទី៣៖ ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥

ឧបសម្ព័ន្ធទី៤៖ គណៈកម្មការមូលបត្រកម្ពុជា, ២០១១, "គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង"

ឧបសម្ព័ន្ធទី៥៖ គណៈកម្មការមូលបត្រកម្ពុជា, "ទម្រង់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ"

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសជាច្រើនប្រកាន់យករបបសេដ្ឋកិច្ចទីផ្សារសេរី ពោលគឺវិស័យឯកជនដើរតួនាទីជាកម្លាំងស្នូលយ៉ាងសំខាន់នៅក្នុងវិស័យសេដ្ឋកិច្ច។

ជាការពិតណាស់ វិស័យឯកជនអាចរីកចម្រើនទៅមុខបានអាស្រ័យទៅលើកត្តាជាច្រើនដូចជា ការទទួលបានការលើកទឹកចិត្តពីសំណាក់រដ្ឋាភិបាល តាមរយៈគោលនយោបាយនានា ភាពសម្បូរបែបនៃកម្លាំងពលកម្មដែលប្រកបដោយជំនាញខ្ពស់ ព្រមទាំងមានមូលធនទំនេរច្រើនក្នុងខឿនសេដ្ឋកិច្ចជាដើម។ កង្វះខាតមូលធនជាកត្តាចម្បងមួយដែលវិស័យឯកជនតែងតែគិតគូរ និងជួបប្រទះក្នុងកិច្ចការជំនួញរបស់ខ្លួនដូចជាតម្រូវការមូលធនក្នុងគោលបំណងពង្រីកអាជីវកម្មបន្ថែម ការបង្កើនសកម្មភាពផលិតកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ការកែលម្អសេវាកម្មរបស់ក្រុមហ៊ុនតាមរយៈ ការវិនិយោគលើសម្ភារៈបច្ចេកវិទ្យាទំនើបដែលស្របទៅតាមកការវិវត្តទីផ្សារនៃសម័យកាលនីមួយៗ។ ដើម្បីអាចឆ្លើយតបនឹងតម្រូវការ និងការលំបាកផ្នែកហិរញ្ញវត្ថុនោះ ក្រុមហ៊ុនឯកជនជាច្រើនតែងតែស្វះស្វែងរកប្រភពទុនពីខាងក្រៅក្រុមហ៊ុន ដែលក្នុងនោះមានកម្ចីពីធនាគារពាណិជ្ជ ការបោះផ្សាយលក់មូលបត្រនៅលើទីផ្សារមូលធន និងមធ្យោបាយផ្សេងៗទៀតដែលអាចមាន។

ទីផ្សារមូលបត្រ ក៏ជាប្រភពដែលវិនិយោគិនទាំងឡាយ អាចធ្វើការគៀងគរមូលធន ដើម្បីយកទៅវិនិយោគលើវិស័យនានាដែលខ្លួនត្រូវការ។ នៅក្នុងទីផ្សារនេះ មានឧបករណ៍ហិរញ្ញវត្ថុជាច្រើនត្រូវបានធ្វើការជួញដូរដូចជា ភាគហ៊ុន សញ្ញាប័ណ្ណជាដើម។ ឧបករណ៍នីមួយៗសុទ្ធតែមានលក្ខណៈពិសេស និងផលប្រយោជន៍របស់វាហើយអ្នកវិនិយោគអាចជ្រើសរើសយកឧបករណ៍ណាក៏បាន ដើម្បីតម្រូវទៅតាមតម្រូវការរបស់ខ្លួន។

យ៉ាងណាមិញព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលមានកំណើនសេដ្ឋកិច្ចខ្ពស់នៅក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ រួមទាំងការរីកចម្រើនផ្នែកឯកជនលើគ្រប់វិស័យផងដែរ តាមរយៈការគាំទ្រ និងលើកទឹកចិត្ត ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដោយសហការជាមួយដៃគូអភិវឌ្ឍនានា។ ជាក់ស្តែង គេឃើញមានក្រុមហ៊ុនឯកជនជាច្រើន បាននឹងកំពុងធ្វើប្រតិបត្តិការក្នុងប្រទេសកម្ពុជា និងមានសហគ្រិនជាសញ្ជាតិខ្មែរជាច្រើន។ ក្រុមហ៊ុនទាំងនេះមានការអភិវឌ្ឍគួរឲ្យកត់សម្គាល់លើកិច្ចដំណើរការរបស់ខ្លួន ព្រមទាំងមានការប្រកួតប្រជែងយ៉ាងស្វិតស្វាញជាមួយដៃគូជំនួញនានានៅក្នុងតំបន់។ ដោយសារការរីកចំរើននេះ ក្រុមហ៊ុនឯកជនទាំងនោះ

ត្រូវការទុនបន្ថែមដើម្បីទ្រទ្រង់អាជីវកម្មរបស់ខ្លួន និងឆ្លើយតបទៅនឹងតម្រូវការ ក៏ដូចជារក្សាស្ថានភាពជំនួញរបស់ក្រុមហ៊ុនឲ្យនៅតែនាំមុខគេក្នុងការប្រកួតប្រជែងនៅលើទីផ្សារ។

ក្នុងន័យនេះ ដើម្បីជួយដល់វិស័យឯកជននៅក្នុងប្រទេសកម្ពុជាឲ្យមានជម្រើសថ្មីមួយទៀតបន្ថែមពីលើហិរញ្ញប្បទានដែលទទួលបានពីធនាគារ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ឲ្យដំណើរការក្រុមហ៊ុនផ្សារមូលបត្រជាលើកដំបូង នៅក្នុងប្រទេសកម្ពុជានាថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១១។

ប្រទេសកម្ពុជាយើង ក៏បានបង្កើតទីផ្សារមូលបត្រនេះ ដើម្បីផ្តល់ភាពងាយស្រួលដល់វិនិយោគិនក្នុង និងក្រៅប្រទេសក្នុងការស្វែងរកការវិនិយោគ ក៏ដូចជាជំរុញការអភិវឌ្ឍប្រទេស។ ការវិនិយោគលើភាគហ៊ុនកម្មសិទ្ធិមានភាពប្រថុយប្រថាន និងមានហានិភ័យខ្ពស់ជាងការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ ហេតុនេះវិនិយោគិនគ្រប់រូបត្រូវយកចិត្តទុកដាក់ និងតាមដានលម្អិតរាល់ស្ថានការណ៍នានាដែលពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ដើម្បីកាត់បន្ថយហានិភ័យ និងបញ្ចៀសការខាតបង់។ មានបញ្ហាជាច្រើនដែលអ្នកវិនិយោគត្រូវស្វែងយល់មុននឹងសម្រេចចិត្តទិញភាគហ៊ុនកម្មសិទ្ធិពីក្រុមហ៊ុនមួយដូចជា ស្ថានភាពក្រុមហ៊ុន ស្ថានភាពហិរញ្ញវត្ថុ ស្ថានភាពហានិភ័យ ជាដើម។ ក្នុងនោះការបង្ហាញ ពីព័ត៌មានសារជីវកម្ម ក៏ជាអ្វីដែលវិនិយោគិនគ្រប់រូបត្រូវយកចិត្តទុកដាក់ និងមិនអាចធ្វេសប្រហែសបានជាដាច់ខាត។ ដូច្នេះ ការបង្ហាញពីនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ពិតជាមានសារៈសំខាន់ក្នុងការចង្អុលបង្ហាញដល់អ្នកវិនិយោគថាគួរ ឬមិនគួរវិនយោគលើភាគហ៊ុនកម្មសិទ្ធិរបស់ក្រុមហ៊ុនមួយ ដោយសារតែការបង្ហាញពីនីតិវិធីរបស់ក្រុមហ៊ុនបោះផ្សាយនីមួយៗ គេត្រូវបង្ហាញពីព័ត៌មានសារជីវកម្មដែលធ្វើឡើងក្រោយពេលក្រុមហ៊ុនធ្វើ IPO (Initial Public Offering)។ ការបង្ហាញព័ត៌មាននេះដើរតួយ៉ាងសំខាន់ក្នុងការសម្រេចចិត្តរបស់វិនិយោគិន ពីព្រោះវាបង្ហាញពីទិដ្ឋភាពទូទៅដែលពាក់ព័ន្ធនឹងក្រុមហ៊ុន ហើយផ្តល់ភាពងាយស្រួលក្នុងការថ្លឹងថ្លែង និងធ្វើការសម្រេចចិត្តចំពោះការជួញដូរភាគហ៊ុនកម្មសិទ្ធិរបស់ក្រុមហ៊ុន។ ផ្ទុយទៅវិញ ប្រសិនបើព័ត៌មានមានការខ្វះខាត ឬជាព័ត៌មានមិនពិតនោះវិនិយោគិននឹងជួបផលវិបាកជាច្រើនដែលអាចជះឥទ្ធិពលអវិជ្ជមានដល់ សេដ្ឋកិច្ចផ្ទាល់ខ្លួន និងរបស់ក្រុមហ៊ុនទៀតផង។

ដោយយល់ឃើញពីអត្ថប្រយោជន៍ និងសារៈសំខាន់ ព្រមទាំងចង់ស្វែងយល់ពីការបង្ហាញពីនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់គណៈកម្មការមូលបត្រកម្ពុជា ទើបក្រុមនាងខ្ញុំសម្រេចចិត្តជ្រើសយកប្រធានបទស្តីពី «នីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង» មកធ្វើការសិក្សាស្រាវជ្រាវឲ្យបានលម្អិត និងចូលរួមដោះស្រាយនូវចម្ងល់ដែលកើតមានមួយចំនួន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅក្នុងបរិបទនៃការរីកធំធាត់ឥតឈប់ឈរនៃឧស្សាហកម្មហិរញ្ញវត្ថុកម្ពុជា ការដាក់ឲ្យដំណើរការក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាសញ្ញាវិជ្ជមានមួយថែមទៀតសម្រាប់ព្រះរាជាណាចក្រកម្ពុជា និងជាពិសេសសម្រាប់សហគមន៍ធុរកិច្ចកម្ពុជាទាំងមូល។ ជាការពិត ទីផ្សារមូលបត្រ គឺជាវិស័យថ្មីមួយសម្រាប់ប្រទេសកម្ពុជាដែលបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុនទាំងអស់ក្នុងការគៀងគរប្រភពទុន ដើម្បីយកមកពង្រីកអាជីវកម្មរបស់ខ្លួនតាមរយៈការបោះផ្សាយមូលបត្រលក់ជាសាធារណៈជាលើកដំបូងនៅលើទីផ្សារមូលបត្រ។

ដោយសារវិស័យមូលបត្រជាវិស័យមួយដែលមានលក្ខណៈស្មុគស្មាញ និងប្រទាក់ក្រឡាគ្នាយ៉ាងស្អិតស្អាញជាមួយវិស័យផ្សេងៗទៀតក្នុងប្រព័ន្ធហិរញ្ញវត្ថុ ហេតុដូចនេះហើយទើបអាជ្ញាធរមូលបត្រនៃប្រទេសកម្ពុជាយកចិត្តទុកដាក់ជាចម្បងលើការបណ្តុះបណ្តាលដល់សាធារណៈជនអ្នកវិនិយោគ និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រទាំងអស់ឲ្យបានយល់ និងស្គាល់ពីបច្ចេកទេស ព្រមទាំងប្រតិបត្តិការនានាដែលពាក់ព័ន្ធនឹងមូលបត្រ ក៏ដូចជាការពារអ្នកវិនិយោគពីសកម្មភាពមិនប្រក្រតី អំពើល្មើស និងបទល្មើសដែលអាចនាំឲ្យបាត់បង់ទំនុកចិត្តលើទីផ្សារមូលបត្រ និងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។

ដោយសារតែក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ បានឆ្លងកាត់នីតិវិធីជាច្រើនដំណាក់កាលដើម្បីបោះផ្សាយមូលបត្រកម្មសិទ្ធិជាលើកដំបូង ដូច្នេះហើយក្រុមយើងខ្ញុំបានជ្រើសរើសយកនូវប្រធានបទ នីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសារណៈជាលើកដំបូងនេះ មកធ្វើការស្រាវជ្រាវ ដើម្បីឲ្យនិស្សិត និងក្រុមហ៊ុនដែលមានបំណងបោះផ្សាយមូលបត្រ ឲ្យបានជ្រាបកាន់តែច្បាស់ និងដើម្បីរួមចំណែកក្នុងការអភិវឌ្ឍនូវវិស័យនេះឲ្យកាន់តែរីកចម្រើន។ ទាំងនោះក៏មានបញ្ហាចោទមួយចំនួនក្នុងកិច្ចការស្រាវជ្រាវនេះ៖

- តើគណៈកម្មការមូលបត្រកម្ពុជាដែលហៅកាត់ថា គ.ម.ក បានកំណត់នូវវិធានការណ៍ ឬគោលការណ៍ និងនីតិវិធីអ្វីខ្លះដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាលើកដំបូង?
- តើក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាលើកដំបូងជាប់នូវផ្តល់វិបាកអ្វីខ្លះនៅក្នុងដំណើរការបោះផ្សាយ?
- តើក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាលើកដំបូងទទួលបានផលប្រយោជន៍អ្វីខ្លះផងដែរ?
- មូលហេតុអ្វីខ្លះទើបជម្រុញ ធ្វើអោយក្រុមហ៊ុនសម្រេចចិត្តបោះផ្សាយលក់មូលបត្រជាលើកដំបូង?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺដើម្បីសិក្សាស្វែងយល់ឲ្យកាន់តែច្បាស់អំពីវិស័យមូលបត្រ ជាពិសេស សម្រាប់ទុកជាឯកសារមួយសម្រាប់ឲ្យសិស្សនិស្សិត និងក្រុមហ៊ុនទូទៅបានស្វែងយល់ឲ្យស៊ីជម្រៅអំពី នីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិសាធារណៈជាលើកដំបូង។

ម្យ៉ាងវិញទៀត យើងខ្ញុំក៏ចង់ស្វែងយល់បន្ថែមអំពីមូលបត្រ និងពីនីតិវិធីបោះផ្សាយមូលមត្រកម្មសិទ្ធិ ដើម្បីពង្រីកចំណេះដឹងផ្នែកមូលបត្រនេះផងដែរ។ ចំពោះការស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ចំពោះប្រធានបទមួយនេះ ក្រុមយើងខ្ញុំមានគោលបំណងដើម្បី៖

- យល់ច្បាស់ពីនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង
- ដឹងអំពីការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ
- ស្គាល់ពីយន្តការ ឬនីតិវិធីផ្តល់ព័ត៌មាន
- ស្គាល់ពីប្រភេទព័ត៌មានសាជីវកម្ម
- ស្គាល់ពីរចនាសម្ព័ន្ធនៃគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)
- ស្គាល់ពីប្រភេទមូលបត្រកម្មសិទ្ធិ
- ស្គាល់ពីរចនាសម្ព័ន្ធនៃផ្សារមូលបត្រកម្ពុជា (ផ.ម.ក)
- យល់ពីនិយមន័យភាគហ៊ុន
- ការបង្កើតក្រុមការងារ IPO។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដោយសារតែការសិក្សាទៅលើផ្នែកមូលបត្រ មានលក្ខណៈធំទូលាយ និងរយៈពេលសិក្សាស្រាវជ្រាវមានដែនកំណត់ ដូចនេះដើម្បីឲ្យកិច្ចការស្រាវជ្រាវនេះមានដំណើរការទៅបានល្អ និងមានភាពច្បាស់លាស់នោះក្រុមយើងខ្ញុំ បានផ្តោតការសិក្សាតែទៅលើ នីតិវិធីនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងតែប៉ុណ្ណោះ ហើយក្រុមរបស់យើងខ្ញុំ លើកយកករណីសិក្សារបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាធនាគារពាណិជ្ជធំជាងគេ នៅប្រទេសកម្ពុជា ដែលជាក្រុមហ៊ុនទី៦ ដែលចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជាផងដែរ។ ចំពោះប្រភពឯកសារដែល ក្រុមយើងខ្ញុំទទួលបាន គឺចាប់ពីឆ្នាំ២០១២ ដែលវិស័យមូលបត្រនៅកម្ពុជាមានការរីកលូតលាស់ រហូតដល់ខែឧសភា ឆ្នាំ២០២០។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទនេះ បានផ្តល់នូវសារៈសំខាន់ និងអត្ថប្រយោជន៍មិនត្រឹមតែចំពោះយើងខ្ញុំជាអ្នកស្រាវជាវប៉ុណ្ណោះទេ វាថែមទាំងមានសារៈសំខាន់សម្រាប់អ្នកវិនិយោគក្នុងវិស័យមូលបត្រ និងមជ្ឈដ្ឋានទូទៅដូចជា ក្រុមហ៊ុនអន្តរការីមូលបត្រសម្រាប់សាធារណជនទូទៅ សិស្សនិស្សិត និងអ្នកចង់សិក្សាយល់ដឹងបន្ថែមពីទីផ្សារមូលបត្រកម្ពុជា។ ការស្រាវជ្រាវនេះផ្តល់សារៈសំខាន់ដូចជា៖

- ➢ សារៈសំខាន់សម្រាប់អ្នកស្រាវជ្រាវ៖

- ធ្វើការសិក្សាស្វែងយល់ឡើងវិញនូវមេរៀនដែលបានសិក្សារួចមកហើយ
- ទទួលបានបទពិសោធន៍ក្នុងការធ្វើការសិក្សាស្រាវជ្រាវ
- ទទួលបានបទពិសោធន៍ក្នុងការចងក្រងជាសៀវភៅ
- ទទួលបានចំណេះដឹងកាន់តែស៊ីជម្រៅពីការបង្ហាញព័ត៌មានសាជីវកម្ម
- ចេះគ្រប់គ្រងពេលវេលា ការប្រមូលផ្តុំព័ត៌មាន រៀបចំឲ្យមានសណ្តាប់ធ្នាប់
- សារណាមានផលប្រយោជន៍ដល់ការសំភាសន៍សុំចូលបម្រើការងារផ្សេងៗ
- រំលឹកទ្រឹស្តីឡើងវិញ
- ស្គាល់នូវពាក្យបច្ចេកទេសជាច្រើនដែលពាក់ព័ន្ធនឹងវិស័យនេះ ដែលកន្លងមកពុំបានយល់ច្បាស់
- ចងក្រងជាសៀវភៅទុកឲ្យនិស្សិតជំនាន់ក្រោយ។

➢ សារៈសំខាន់សម្រាប់គណៈកម្មការមូលបត្រ៖

- លទ្ធផលនៃការស្រាវជ្រាវនេះនឹងជាជំនួយបន្ថែមដល់គណៈកម្មការមូលបត្រកម្ពុជាក្នុងការពិនិត្យមើលថា តើការបង្ហាញព័ត៌មានសាជីវកម្មក្នុងទីផ្សារមូលបត្រកម្ពុជាមានលក្ខណៈគ្រប់គ្រាន់ សមស្រប និងពេញលេញហើយឬនៅ? ហើយគួរបន្ថែម ឬបន្ថយនូវចំណុចណាខ្លះ?
- គណៈកម្មការមូលបត្រអាចពិចារណានូវចំណុចខ្វះខាត និងគុណវិបត្តិ ក៏ដូចជាបញ្ហាប្រឈមនានាដែលទីផ្សារជួបប្រទះ
- រកនូវដំណោះស្រាយដ៏ល្អសម្រាប់កែលម្អបញ្ហានេះ។

➢ សារៈសំខាន់ចំពោះក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយមូលបត្រកម្មសិទ្ធិជាលើកដំបូង៖

- ជួយឲ្យយល់អំពីនីតិវិធីនៃការបោះផ្សាយមូលបត្រ
- ពិចារណាទៅលើហានិភ័យដែលនឹងកើតឡើង
- យល់ដឹងពីព័ត៌មានសាជីវកម្មដែលត្រូវចុះផ្សាយ
- យល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិផ្សេងៗជ្រាបកាន់តែច្បាស់អំពីការធ្វើ IPO។

➢ សារៈសំខាន់សម្រាប់មជ្ឈដ្ឋានទូទៅ៖

- ឲ្យវិនិយោគិនគ្រប់រូបយល់ដឹងពីទីផ្សារមូលបត្រឲ្យបានកាន់តែច្បាស់
- ជាឯកសារសម្រាប់អ្នកអានទូទៅ ជាពិសេសក្រុមហ៊ុនមូលបត្រ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី នីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិសាធារណៈជាលើកដំបូងនេះ ត្រូវបានរៀបចំឡើងដោយអនុវត្តតាមវិធីសាស្ត្របន្ទាប់បន្សំក្នុងការប្រមូលទិន្នន័យដើម្បីចងក្រងជាសៀវភៅ។ វិធីសាស្ត្រទិន្នន័យបន្ទាប់បន្សំ រួមមានដូចខាងក្រោម៖

- ការស្វែងរកទិន្នន័យតាមប្រព័ន្ធអ៊ីនធឺណែត
- ឯកសារដែលមន្ត្រីបម្រើការងារនៅគណៈកម្មការមូលបត្រកម្ពុជាផ្តល់អោយដូចជាច្បាប់ បទប្បញ្ញត្តិជាដើម
- ស្វែងរកឯកសារណាដែលទាក់ទងនឹងប្រធានបទមានដូចជា ច្បាប់ អនុក្រឹត្យ ប្រកាស បទប្បញ្ញត្តិ និងអានសៀវភៅផ្សេងៗ ជាច្រើន
- សារណា និងរបាយការណ៍បញ្ចប់ការសិក្សារបស់និស្សិតរៀមច្បង
- ស្វែងរកសៀវភៅ និងឯកសារពាក់ព័ន្ធនានា តាមបណ្ណាល័យ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះចែកចេញជា ៣ ជំពូក រួមមានដូចខាងក្រោម៖

- សេចក្តីផ្តើម
- ជំពូកទី១៖ រំលឹកទ្រឹស្តី
- ជំពូកទី២៖ ស្ថានភាពទូទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- ជំពូកទី៣៖ នីតិវិធីនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

ខាងក្រោមនេះជារចនាសម្ព័ន្ធនៃកម្មសិក្សាស្រាវជ្រាវ៖



# ជំពូកទី១
# រំលឹកត្រីកោណមាត្រ

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. ប្រវត្តិនៃការកកើតទីផ្សារហ៊ុន

ផ្សារភាគហ៊ុនបានកកើតឡើងពីសកម្មភាពដោះដូរដើមដំបូង ក្នុងផលិតផលកសិកម្ម និងផលិតផលផ្សេងទៀត។ ពាណិជ្ជករនៅក្នុងផ្សារអឺរ៉ុប នៅក្នុងមជ្ឈឹមសម័យមានការងាយស្រួលក្នុងការប្រើប្រាស់ឥណទានដែលទាមទារឲ្យមាននូវឯកសារពង្រាងដោយមានការគាំទ្រដូចជា ប័ណ្ណ ឬលិខិតផ្លាស់ប្តូរ។ ផ្សារភាគហ៊ុនបារាំងត្រូវបានគេរកឃើញកាលពីសតវត្សទី១២ នៅពេលដែលការធ្វើជំនួញបានកកើតឡើងជារូបភាព និងជាលិខិតផ្លាស់ប្តូរពាណិជ្ជកម្ម។ ដើម្បីគ្រប់គ្រងនូវទីផ្សារដែលទើបតែចាប់ផ្តើមនេះ លោកហ្វីលីបឌឺហ្វៃរ (១២៦៨-១៣១៤) បានបង្កើតនូវជំនាញមួយនៃការផ្លាស់ប្តូរដូចជា អ្នកនាំមុខគេនៃអ្នកគួកជេរហ៊ុនបារាំងទំនើប ឬក៏អាចភ្នាក់ងារផ្លាស់ប្តូរ។ ប្រហែលជានៅពេលដូចគ្នានេះដែរ ពាណិជ្ជករបានចាប់ផ្តើមប្រមូលផ្តុំគ្នា នៅខាងមុខផ្ទះគ្រួសារ វ៉ាន់ឌែប៊ូអែស (Van der Buerse) ដើម្បីទំនាក់ទំនងក្នុងការធ្វើជំនួញ។ ចាប់តាំងពីទំនៀមទំលាប់នោះមក ឈ្មោះរបស់គ្រួសារនេះ ត្រូវបានគេបញ្ជាក់ភ្ជាប់ជាមួយនឹងការធ្វើជំនួញនេះ ហើយបណ្តើរៗ ត្រូវបានគេហៅថា «បួក្ស» (Buerse) មានន័យថាផ្សារភាគហ៊ុន (Stock Exchange)។ ចេញពីឬសគល់ស្រដៀងគ្នានេះក្នុងការធ្វើជំនួញ និងពាណិជ្ជកម្ម ការចាប់ផ្តើមស្ថាប័ននៃទីផ្សារហ៊ុនក៏បានកើតឡើងក្នុងអំឡុងសតវត្សទី១៦ និងសតវត្សទី១៧ នៅក្នុងមជ្ឈមណ្ឌលដ៏ធំផ្សេងទៀតនៅទូទាំងពិភពលោក ដូចជានៅ អាំស្ទ័រដាំ ចក្រភពអង់គ្លេស ដាណឺម៉ាក និងអាល្លឺម៉ង់ជាដើម។

ការរីកចម្រើននៃពាណិជ្ជកម្ម ក៏បានបង្កើតនូវសេចក្តីត្រូវការចំពោះធនាគារ និងក្រុមហ៊ុនធានារ៉ាប់រង។ ការវិវត្តន៍ក្នុងផ្នែកនយោបាយបានធ្វើឲ្យរដ្ឋាភិបាលស្វែងរកនូវប្រភពទុនថ្មីៗ។ ការរួមគ្នានៃសកម្មភាពកំពុងរីកចម្រើននេះ និងកង្វះខាតទុនពីកន្លែងមួយ បានជំរុញឲ្យមានការចេញផ្សព្វផ្សាយនូវមូលបត្រ ដូចជា ស្ថាប័នរដ្ឋាភិបាល ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង សហគ្រាស និងក្រុមហ៊ុនមួយចំនួនទៀត ជាពិសេសក្រុមហ៊ុនធំៗ។ ចាប់ពីការធ្វើជំនួញដែលមានស្រាប់ចំពោះវិក្កយបត្រ និងក្រដាសប្រាក់ វាគឺជាការផ្លាស់ប្តូរដែលស្របច្បាប់ និងងាយស្រួលចំពោះការបង្កើតនៅផ្សារភាគហ៊ុនសម្រាប់មូលបត្រ។ បើគិតមកដល់ទសវត្សឆ្នាំ ១៦០០ ភាគហ៊ុននៃក្រុមហ៊ុន Dutch East India (DEI) ត្រូវបានគេធ្វើជំនួញនៅអាំស្ទ័រដាំ។ នៅក្នុងឆ្នាំ ១៧៧៣ ឈ្មួញហ៊ុននៅទីក្រុងឡុងដ៍ដែលពីមុនមកបានជួបគ្នានៅតែក្នុងហាងកាហ្វេ ក៏បានរើចូលក្នុង គឺនៅក្នុងអាគារផ្ទាល់របស់គេ ហើយមកដល់សតវត្សទី១៩ ការធ្វើជំនួញមូលបត្រដោយឈរលើមូលដ្ឋានធម្មតា គឺជាទូទៅស្ថិតនៅក្នុងប្រទេសដែលមានឧស្សាហកម្មច្រើន។

បដិវត្តនៃផ្សារភាគហ៊ុនក៏បានបន្ត នៅចក្រភពអង់គ្លេស ការរីកចម្រើនក៏កើតមានឡើងសម្រាប់ផ្នែកជាច្រើនដូចជាផ្នែកផ្ទៃក្នុងរបស់គេ និងធ្វើឡើងដោយស្ម័គ្រចិត្ត។ ផ្ទុយមកវិញ ផ្សារភាគហ៊ុនបារាំងគឺតម្រូវឲ្យដំណើរការស្របទៅតាមច្បាប់ទាំងស្រុង ដូចដែលប្រតិបត្តិការនៃភ្នាក់ងារដោះដូរក៏ត្រូវបានគ្រប់គ្រងដោយក្រឹត្យច្បាប់របស់ជាតិ។ នៅក្នុងពេលតែមួយមានផ្សារចំនួន ៣ សម្រាប់មូលបត្រនៅទីក្រុងប៉ារីស ផ្សារជាផ្លូវការមួយត្រូវបានគេហៅថា Parquet "The Floor" ផ្សារពាក់កណ្តាលផ្លូវការ Coulisse "The Wing" និង Hors Cote "The Outside" ដែលជាទីផ្សារដែលមិនមានការគ្រប់គ្រងចំពោះមូលបត្រដែលមិនបានចុះបញ្ជី។ ក្នុងឆ្នាំ ១៩២៩ Hors Cote គឺស្របទៅនឹងបទប្បញ្ញត្តិជាផ្លូវការ ហើយនៅក្នុងទសវត្សក្រោយមកសកម្មភាពរបស់វាត្រូវបានជ្រៀតចូលទៅក្នុង Coulisse "The Wing" ហើយដែលក្នុងនោះទទួលបានមកវិញនូវការរួមបញ្ចូលគ្នាជាមួយ Parquet ក្នុងការចាត់ចែងជាថ្មីនៅឆ្នាំ ១៩៦១។ នៅប្រទេស ប៊ែលហ្សិច ផ្សារភាគហ៊ុនមាននូវប្រវត្តិចម្រុះគ្នា។ ការត្រួតពិនិត្យដោយរដ្ឋាភិបាលដ៏តឹងរឹងត្រូវបានដាក់នៅក្នុងឆ្នាំ ១៨០១ និងមិនត្រូវបានគេដកចេញរហូតដល់ឆ្នាំ ១៨៦៧។

ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ បានបន្សល់នូវសញ្ញាមួយចំនួនអាស្រ័យទៅលើការបង្កើតឡើងនូវផ្សារភាគហ៊ុននៅក្នុងប្រទេសខ្លះ។ ការជីកយករ៉ែនៅប្រទេសអាព្រិចខាងត្បូង និងកាណាដា គឺជាឥទ្ធិពលមួយដែលបង្ខំឲ្យមានការបង្កើតឡើងនូវផ្សារភាគហ៊ុនជាជាងការធ្វើជំនួញ និងពាណិជ្ជកម្ម។ នៅប្រទេសអាល្លឺម៉ង់ ផ្សារហ៊ុននៅទីក្រុង ប៊ែរឡាំង បានបាត់បង់នូវតួនាទីដ៏សម្បើមរបស់ខ្លួន បន្ទាប់ពីប្រទេសនេះបានចាញ់សង្គ្រាមលោកលើកទី២។ ចំណែកឯ ប្រទេសជប៉ុនវិញ ក្រោយសង្គ្រាមលោកលើកទី២ ចប់ផ្សារមូលបត្រជប៉ុន ត្រូវបានគេធ្វើឲ្យមានបម្លាស់ប្តូរទាំងស្រុងនៅពេលដែលច្បាប់ថ្មីត្រូវបានគេតាក់តែងឡើង ដែលបានយកគំរូតាមសហរដ្ឋអាមេរិក។

ផ្សារមូលបត្រនៅក្នុងសហរដ្ឋអាមេរិក បានចាប់ផ្តើមជាមួយនឹងការធ្វើជំនួញដែលមានការឡើងចុះឆាប់រហ័សក្នុងការចេញបោះផ្សាយថ្មីៗរបស់រដ្ឋាភិបាល។ ក្នុងឆ្នាំ ១៧៩១ ផ្សារភាគហ៊ុនដំបូងរបស់ប្រទេសអាមេរិកត្រូវបានបង្កើតនូវរដ្ឋហ្វីឡាដេល្ផា (Philadelphia) បន្ទាប់មកទីក្រុងដែលនាំមុខគេក្នុងពាណិជ្ជកម្មបរទេស និងក្នុងស្រុក។ ក្នុងឆ្នាំ ១៧៩២ ផ្សារភាគហ៊ុននៅទីក្រុងញ៉ូវយ៉ក ត្រូវបានបង្កើតឡើង គឺនៅពេលដែលពាណិជ្ជករ និងអ្នកគួកជេរចំនួន ២៤នាក់ បានសម្រេចចិត្តយកកំរៃជើងសារនៅពេលដើរតួជាភ្នាក់ងារសម្រាប់មនុស្សផ្សេងទៀត ហើយដើម្បីផ្តល់ការពេញចិត្តទៅឲ្យគ្នាទៅវិញទៅមកក្នុងការចរចាររបស់គេ។ ពួកគេបានធ្វើជំនួញរបស់គេច្រើនណាស់នៅក្រោមដើមឈើមួយនៅផ្លូវ វ៉ុលស្ទ្រីត (Wall Street) លេខ ៦៨។ មូលបត្ររបស់រដ្ឋាភិបាលបានបង្កើតនូវមូលដ្ឋានគ្រឹះនៃការធ្វើជំនួញជាលើកដំបូង។ ហ៊ុនរបស់ធនាគារ និងក្រុមហ៊ុនធានារ៉ាប់រង បានបន្ថែមលើបរិមាណនៃប្រតិបត្តិការនោះ។ ការកសាងផ្លូវ និងប្រលាយបាននាំមកនូវមូលបត្របន្ថែមទៀតទៅ

កាន់ទីផ្សារ។ ក្នុងឆ្នាំ ១៨១៧ អ្នកគួកជេរនៅទីក្រុង ញ៉ូវយ៉ក បានសម្រេចចិត្តចាត់ចែងជាផ្លូវការនៅក្រុមប្រឹក្សាផ្សារភាគហ៊ុនបន្ទាប់មកផ្សារភាគហ៊ុនបានរីកចម្រើនជាមួយនឹងឧស្សាហូបនីយកម្មរបស់ប្រទេសនេះ។ ក្នុងឆ្នាំ ១៨៦៣ ផ្សារហ៊ុន ញ៉ូវយ៉ក បានអនុម័តនូវឈ្មោះបច្ចុប្បន្នរបស់ខ្លួន។ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ផ្សារភាគហ៊ុនមួយចំនួនបន្ថែមទៀតត្រូវបានគេរៀបចំចាត់ចែងឡើង ហើយផ្សារហ៊ុនមួយចំនួនក្នុងចំណោមផ្សារភាគហ៊ុនទាំងនោះ ដែលចាត់ទុកជាអ្នកនាំមុខគេគឺទីផ្សារហ៊ុន អាមេរិក (American Stock Exchange)។[1]

## ១.២. ទីផ្សារមូលបត្រ

វិស័យមូលបត្រជាផ្នែកសំខាន់មួយក្នុងប្រព័ន្ធហិរញ្ញវត្ថុជាតិ តាមរយៈការផ្តល់យន្តការសម្រាប់គៀងគរប្រភពហិរញ្ញវត្ថុផ្សេងៗទាំងផ្នែកតូច និងមធ្យមព្រមទាំងរយៈពេលខ្លី មធ្យម និងវែងដើម្បីធ្វើហិរញ្ញប្បទានគម្រោងវិនិយោគនានា និងធ្វើឲ្យមានភាពសម្បូរបែបនៃប្រភពធនធានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមានការរីកចម្រើន។ ម៉្យាងវិញទៀត វត្តមាននៃទីផ្សារមូលបត្រនឹងផ្តល់នូវជម្រើសវិនិយោគថ្មីមួយបន្ថែមទៀតសម្រាប់ការវិនិយោគលើវិស័យហិរញ្ញវត្ថុ ក្រៅពីការដាក់បញ្ញើសន្សំនៅតាមបណ្តាធនាគារ និងធ្វើឲ្យលំហូរសាច់ប្រាក់ក្នុងស្រុកកាន់តែមានប្រសិទ្ធិភាព និងប្រសើរឡើង។ ដូចនេះ ទីផ្សារហ៊ុនគឺជាអង្គភាពស្ម័គ្រចិត្តមួយនៃបុគ្គលដែលបង្កើតឡើងដើម្បីផ្តល់ជាស្ថាប័នមួយដែលក្នុងនោះហ៊ុនត្រូវបានគេទិញ និងលក់។[2]

ផ្សារភាគហ៊ុនជាច្រើនគឺជាសាជីវកម្មមិនយកប្រាក់ចំណេញ ដែលត្រូវបានបង្កើតឡើងដើម្បីបម្រើសមាជិករបស់គេ។ ដើម្បីក្លាយជាសមាជិកមួយនៃទីផ្សារភាគហ៊ុន បុគ្គលមួយត្រូវតែទិញចំនួនមួយនៃចំនួនដែលមានកំណត់របស់សមាជិកភាពដែលហៅថា "អាសនៈ" នៅឯទីផ្សារភាគហ៊ុន។ បន្ថែមលើសពីនេះទៀតមានតែសមាជិកផ្សារហ៊ុនប៉ុណ្ណោះ ឬអ្នកតំណាងរបស់គេ ទើបអនុញ្ញាត្តិឲ្យជួញដូរនៅលើទីផ្សារភាគហ៊ុន។ ក្នុងន័យនេះ សមាជិកភាពមានសិទ្ធិផ្តាច់មុខ ពីព្រោះរាល់ការបញ្ជាទិញ លក់មូលបត្រទាំងអស់ តាមការជួញដូរដែលគេបានផ្តល់ឲ្យត្រូវតែធ្វើឡើងដោយឆ្លងកាត់តាមសមាជិកផ្សារមូលបត្រ។ សមាជិកភាពផ្សារមូលបត្រអាចត្រូវបានគេទិញ និងលក់ដូចជាទ្រព្យសកម្មផ្សេងទៀតដែរ។ ផ្សារហ៊ុននីមួយៗលែសម្រួលនូវទីកន្លែង និងពេលវេលានៅពេលដែលការជួញដូរអាចកើតមានឡើង។

ទីផ្សារមូលបត្រអាចដំណើរការទៅបានដោយស្ថិតក្រោមច្បាប់ និងបទបញ្ញត្តិនានាដែលរៀបចំឡើង និងអនុម័តដោយអាជ្ញាធរមូលបត្រនៃប្រទេសនោះ។ ជាការពិតណាស់ ច្បាប់ និងបទប្បញ្ញត្តិនោះ គឺមានគោលបំណងជួយការពារវិនិយោគិនទាំងអស់ ដោយឲ្យនូវភាពត្រឹមត្រូវ និងប្រសិទ្ធិភាពនៃទីផ្សារមូលបត្រ និងយន្តការ

[1] ហាស់ វាសនា,២០០៧, *ផ្សារភាគហ៊ុនគឺជាអ្វី?* ទំព័រទី៩

[2] http://csx.com.kh/news/faq/listPosts.do?MNCD=7060 គេហទំព័រផ្សារមូលបត្រកម្ពុជា (២០២០), សំនួរ-ចម្លើយ

គ្រប់គ្រងហានិភ័យ ព្រមទាំងជំរុញឲ្យមានតម្លាភាព និងគណនេយ្យភាពនៃរបាយការហិរញ្ញវត្ថុ និងអភិបាលកិច្ចសាជីវកម្មក្នុងក្រុមហ៊ុននីមួយៗ ឬសហគ្រាស។ រាល់ប្រតិបត្តិការទាំងអស់ពាក់ព័ន្ធក្នុងវិស័យមូលបត្រទាំងមូល គឺត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិយ៉ាងពិសេស ដោយតម្រូវឲ្យមានការដាក់បង្ហាញនូវព័ត៌មាននានាជាសាធារណៈ និងមិនមានលក្ខណៈក្លែងបន្លំណាមួយដែលខុសច្បាប់ និងបទប្បញ្ញត្តិនានានៃទីផ្សារមូលបត្រ។ ម្យ៉ាងវិញទៀត ច្បាប់ និងបទប្បញ្ញត្តិទាំងអស់នោះ គឺប្រើប្រាស់ក្នុងគោលបំណងដើម្បីគ្រប់គ្រងរាល់ព័ត៌មានទាំងឡាយ នៅលើទីផ្សារ ព្រមទាំងដំណើរការនានាក្នុងការទិញ និងលក់មូលបត្រ។ ការធ្វើដូច្នេះ គឺដើម្បីឲ្យវិនិយោគិនម្នាក់ៗអាចទទួលបានព័ត៌មានដូចគ្នានៅក្នុងពេលតែមួយ ហើយមានឱកាសដូចគ្នាក្នុងការជួញដូរមូលបត្រនៅលើទីផ្សារ ពោលគឺទទួលបានកម្រិតប្រកួតប្រជែងស្មើគ្នា។ កម្រិតប្រកួតប្រជែងស្មើភាពគ្នានេះ គឺជាកត្តាសំខាន់មួយដែលធ្វើឲ្យវិនិយោគិនទាំងអស់មានទំនុកចិត្តទៅលើទីផ្សារមូលបត្រទាំងមូល។ ដើម្បីទទួលបានកម្រិតប្រកួតប្រជែងស្មើគ្នាមួយ គឺតម្រូវឲ្យមានការផ្សព្វផ្សាយនូវរាល់ព្រឹត្តិការណ៍សំខាន់ៗទាំងឡាយនៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនីមួយៗ ឲ្យបានទូលំទូលាយព្រមទាំងទទួលបានព័ត៌មានផ្សព្វផ្សាយស្មើភាពគ្នាចំពោះវិនិយោគិនទាំងអស់។ ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ក៏ត្រូវកំណត់ និងតាមដានផងដែរពីអាកប្បកិរិយា អ្នកចូលរួមនៅក្នុងទីផ្សារទាំងអស់ ព្រមទាំងដាក់ការផាកពិន័យនានាចំពោះទង្វើទាំងឡាយណាដែលរំលោភសេចក្តីទុកចិត្តនៅលើទីផ្សារមូលបត្រ ដែលបានកំណត់ទុកសម្រាប់ការចុះបញ្ជីនៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រអន្តរការីមូលបត្រ និងមូលបត្របោះផ្សាយទាំងអស់។

ទីកន្លែងផ្សារភាគហ៊ុន គឺមានការរៀបចំដ៏ច្រើននូវឧបករណ៍អេឡិចត្រូនិច និងឧបករណ៍មួយចំនួនត្រូវបានគេប្រើប្រាស់ដើម្បីបញ្ជូននៅការទិញ និងលក់នៅទីនោះ និងដើម្បីបញ្ជាក់ពីការជួញដូរដែលគេបានដោះដូររួចហើយ។ សកម្មភាពព័ត៌មានខ្សែកាបដ៏ធំទូលំទូលាយ បានផ្តល់ឲ្យឈ្មួញភាគហ៊ុននូវព័ត៌មានដែលមានសារៈសំខាន់អំពីព្រឹត្តិការណ៍សំខាន់ទាំងជាតិ អន្តរជាតិ និងការវិវត្តនៃអាជីវកម្ម។ ការផ្លាស់ប្តូរណាមួយចំពោះកត្តាទាំងនេះនឹងត្រូវបានឆ្លុះបញ្ចាំងយ៉ាងឆាប់រហ័សនូវថ្លៃរបស់ភាគហ៊ុន។ បុគ្គលមួយចំនួនដែលធ្វើការនៅទីកន្លែងផ្សារភាគហ៊ុន ត្រូវបានគេជួលដោយផ្សារភាគហ៊ុន និងអ្នកផ្សេងទៀតជួញដូរហ៊ុនសម្រាប់ខ្លួនគេផ្ទាល់ ប៉ុន្តែភាគច្រើនអ្នកទាំងនោះដែលបានធ្វើការនៅទីកន្លែងផ្សារភាគហ៊ុន គឺជាអ្នកគួកជេរ (Broker)។ អ្នកគួកជេរទទួលការបញ្ជាទិញ និងលក់ពីសមាជិកដែលមិនមែនជាសមាជិកផ្សារហ៊ុន ហើយប្រតិបត្តិនូវការបញ្ជាទិញទាំងនោះ។ ជាការឆ្លើយតបមកវិញ អ្នកគួកជេរទទួលបាននូវកំរៃជើងសារ (Commission) ពីអ្នកដែលបានដាក់ការបញ្ជាទិញទាំងនោះ។

## ១.៣. ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រកម្ពុជា

### ១.៣.១ ប្រវត្តិទីផ្សារមូលបត្រកម្ពុជា

គោលបំណងចម្បងក្នុងការបង្កើតទីផ្សារមូលបត្រកម្ពុជា គឺដើម្បីគៀងគរមូលធន និងប្រភពហិរញ្ញវត្ថុនានា ឲ្យមានលំហូរក្នុងសេដ្ឋកិច្ចដើម្បីជួយបង្កើនកំណើនសេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើនបានលឿន។ ម៉្យាងទៀត រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជារៀបចំបង្កើតទីផ្សារមូលបត្រកម្ពុជានេះឡើង ដើម្បីអភិវឌ្ឍប្រទេសកម្ពុជាដោយឈរលើគោលដៅជម្រុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការជម្រុញនូវការវិនិយោគក៏ដូចជា ការបង្កើននូវជម្រើសវិនិយោគនានាក្នុងប្រទេសជាតិ។ ការបង្កើនជម្រើសវិនិយោគផ្តល់លក្ខណៈងាយស្រួលដល់ការសម្រេចចិត្តក្នុងការវិនិយោគក្រៅពីការវិនិយោគលើអចលនវត្ថុ សិប្បកម្ម ផលិតកម្ម ពាណិជ្ជកម្ម ឬវិស័យធនាគារជាដើម។ គំនិតផ្តួចផ្តើមនៃការបង្កើតទីផ្សារមូលបត្រកម្ពុជា ពុំមែនទើបតែចាប់ផ្តើមឡើងនៅប៉ុន្មានឆ្នាំចុងក្រោយនេះនោះទេ។ គម្រោងនេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាធ្វើការពិចារណាតាំងពីអណត្តិទី១ មកម្ល៉េះ។

ក្នុងឆ្នាំ ១៩៩៥ នោះរាជរដ្ឋាភិបាលប្រុងនឹងបង្កើតទីផ្សារភាគហ៊ុនក្នុងប្រទេសកម្ពុជាតែម្តង តែដោយមើលឃើញថា មានភាពខ្វះខាតខាងប្រព័ន្ធច្បាប់ និងប្រព័ន្ធហិរញ្ញវត្ថុមានលក្ខណៈទន់ខ្សោយដែលទាមទារការពន្យាពេល ដើម្បីរង់ចាំការអភិវឌ្ឍផ្នែកហិរញ្ញវត្ថុ និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធខាងផ្នែកច្បាប់។ មកដល់ឆ្នាំ២០០០ ក្នុងផែនការរយៈពេល ១០ឆ្នាំ រាជរដ្ឋាភិបាលបានបែងចែកការអភិវឌ្ឍទីផ្សារភាគហ៊ុនកម្ពុជាជា ៣ ដំណាក់កាល។

**ដំណាក់កាលទី ១** គឺគិតចាប់ពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៤។ ក្នុងដំណាក់កាលនេះ រាជរដ្ឋាភិបាលបានរៀបចំវិធានការ និងលក្ខណៈចាំបាច់មួយចំនួនដើម្បីបង្កើតនូវបរិយាកាសសម្រាប់ទីផ្សារភាគហ៊ុន។

**ដំណាក់កាលទី ២** ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៧ ជាដំណាក់កាលធ្វើឲ្យមាននូវមូលដ្ឋានសម្រាប់ផ្សារទុន ដោយបង្កើតឲ្យមានឡើងនូវផ្សារភាគហ៊ុន និងរចនាសម្ព័ន្ធចាំបាច់ដែលទាក់ទងនឹងការជួញដូរមូលបត្រ ព្រមទាំងអនុម័តនូវច្បាប់បទបញ្ញា និងនីតិវិធីលម្អិតផ្សេងៗ។ នៅខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពី «ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា»។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសបើកឲ្យដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជានៅថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០០៧ ។

ការរៀបចំនៅក្នុងដំណាក់កាលទី២ រហូតមកគឺជាការខិតខំប្រឹងប្រែងឲ្យមានលក្ខណៈជាប្រព័ន្ធ ដើម្បីឈានទៅអភិវឌ្ឍទីផ្សារទុននៅក្នុងប្រទេសកម្ពុជានៅក្នុង **ដំណាក់ទី ៣** ដែលគិតចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ

២០១០។ នៅឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីពី «ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា» ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ រាជរដ្ឋាភិបាលកម្ពុជាបានខ្នះខ្នែងធ្វើយ៉ាងណាឲ្យផ្សារភាគហ៊ុនអាចដំណើរការទៅបានតាមការគ្រោងទុក។ ប៉ុន្តែគម្រោងនេះមិនអាចមានដំណើរការទៅតាមការគ្រោងទុកនេះបានទេដោយសារការកើតមានវិបត្តិហិរញ្ញវត្ថុពិភពលោកនៅឆ្នាំ២០០៨។

នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះកិច្ចព្រមព្រៀងក្រុមហ៊ុនចម្រុះ (Join Venture) ដើម្បីបង្កើតផ្សារមូលបត្រកម្ពុជាស្របតាមច្បាប់ស្តីពីសហគ្រាសសាធារណៈ។ ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនចម្រុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។[3] នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ មានក្រុមហ៊ុនមួយចំនួន បានចុះបញ្ជីពាណិជ្ជកម្មដើម្បីដំណើរការទីផ្សារមូលបត្រកម្ពុជា។ មកដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាប័ណ្ណជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពី គ.ម.ក ស្របតាមច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ទីផ្សារមូលបត្រកម្ពុជាដែលបានពន្យារពេលម្តងហើយម្តងទៀតអស់រយៈពេលប្រមាណជា១៦ឆ្នាំនោះ បានចាប់ផ្តើមដំណើរការជាស្ថាពរ។

### ១.៣.២ ការគ្រប់គ្រងទីផ្សារ

រាល់ការជួញដូរមូលបត្រនៅលើទីផ្សារមានភាពងាយទទួលរងនូវការប្រើឧបាយកល និងការបោកបញ្ឆោតនានាដែលកើតឡើងដោយជនខិលខូចមួយចំនួន។ ទាំងនេះគឺទាមទារឲ្យ គ.ម.ក ត្រូវយកចិត្តទុកដាក់ជាខ្លាំងលើការរៀបចំច្បាប់ និងបទប្បញ្ញត្តិនានា ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងអំពើក្លែងបន្លំនានានៅលើទីផ្សារមូលបត្រ។ គណៈកម្មការមូលបត្រកម្ពុជាត្រូវធ្វើការត្រួតពិនិត្យលើរបាយការណ៍ និងឯកសារព័ត៌មានផ្សេងៗរបស់ក្រុមហ៊ុនបោះផ្សាយមុននឹងធ្វើការផ្សព្វផ្សាយជាសាធារណៈ។ បើព័ត៌មានដែលក្រុមហ៊ុនបោះផ្សាយមូលបត្រផ្តល់ឲ្យមិនពេញលេញ ឬមានចំណុចសង្ស័យ ឬធ្វើឲ្យយល់ច្រឡំដល់ការសម្រេចចិត្តវិនិយោគ គ.ម.ក ត្រូវផ្តល់ដំណឹងឲ្យក្រុមហ៊ុនបោះផ្សាយនេះវិញភ្លាមដើម្បីធ្វើការកែលម្អ និងផ្តល់ជាភស្តុតាងនានា។ ការធ្វើបែបនេះ

[3] http://csx.com.kh/kh/about/profile.jsp?MNCD=10301 គេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា (២០២០), ប្រវត្តិ ផ.ម.ក

ដើម្បីបញ្ជាក់ថារាល់ព័ត៌មានទាក់ទងនឹងសាជីវកម្មដែលបានផ្សព្វផ្សាយជាសាធារណៈគឺត្រឹមត្រូវ និងពិតប្រាកដ ដោយគ្មានការក្លែងបន្លំឡើយ។

ជាមួយគ្នានេះ ច្បាប់ និងបទប្បញ្ញត្តិទាំងអស់មិនត្រឹមតែយកទៅអនុវត្តចំពោះការប្រើឧបាយកលនៅលើទីផ្សារមូលបត្រប៉ុណ្ណោះទេ គឺថែមទាំងទប់ស្កាត់ផងដែរនូវការជួញដូរសន្លឹកហ៊ុនទាំងឡាយណាដែលប្រើប្រាស់ព័ត៌មានផ្ទៃក្នុងដែលមិនបានផ្សព្វផ្សាយជាសាធារណៈ ឬក៏ធ្វើសេចក្តីថ្លែងការណ៍មិនត្រឹមត្រូវនានាដែលធ្វើឡើងដោយ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនបោះផ្សាយ ឬស្ថាប័នពាក់ព័ន្ធដទៃទៀតក្នុងការបំភ័ន្តសាធារណជន ឬវិនិយោគិនក្នុងវិស័យមូលបត្រឲ្យមានការយល់ខុស។ ច្បាប់ និងបទប្បញ្ញត្តិទាំងនេះត្រូវកំណត់ពី ការដាក់ទោសទណ្ឌ និងការផ្តន្ទាទោសនៃប្រភេទការប្រព្រឹត្តខុសនីមួយៗឲ្យបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការចាប់កំហុសអ្នកប្រព្រឹត្តខុស និងការគ្រប់គ្រងទីផ្សារទាំងមូល។

## ១.៤ ទីផ្សារដំបូង និងទីផ្សារបន្ទាប់

### ១.៤.១ ទីផ្សារដំបូង

ការដាក់មូលបត្រជាលើកដំបូងដោយក្រុមហ៊ុនបោះផ្សាយទៅឲ្យវិនិយោគិនត្រូវបានហៅថា ជាការលក់ចែកចាយជាលើកដំបូង។ ទីផ្សារដំបូងគឺជាកន្លែងដែលមូលបត្រត្រូវបានលក់ជាលើកទីមួយទៅឲ្យសាធារណជន ហើយអ្នកទិញបានទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយដែលអាចជា ក្រុមហ៊ុនសាជីវកម្ម ឬអង្គភាពរដ្ឋាភិបាលមួយ ដែលបានបោះផ្សាយលក់មូលបត្រ។ សាច់ប្រាក់សម្រាប់ទូទាត់មូលបត្រ ត្រូវបង់ទៅឲ្យក្រុមហ៊ុនបោះផ្សាយ ហើយអ្នកទិញភាគហ៊ុនទាំងនេះក្លាយជាអ្នកកាន់កាប់ភាគហ៊ុនដំបូងគេ។ ភាគហ៊ុននិកដំបូងគេអាចកាន់កាប់ភាគហ៊ុនទាំងនេះ ឬក៏លក់ភាគហ៊ុនទាំងអស់ទៅឲ្យអ្នកដ៏ទៃ។ ដំណើរការលក់ភាគហ៊ុនទៅឲ្យសាធារណជនជាលើកដំបូងត្រូវបានគេស្គាល់ថាជា «ការនាំក្រុមហ៊ុនទៅកាន់សាធារណៈ»។ មានន័យថា ក្រុមហ៊ុនលែងកាន់កាប់ដោយវិនិយោគិនដំបូង ឬស្ថាបនិកទៀតហើយ។ ក្រុមហ៊ុនដែលលក់ភាគហ៊ុនរបស់ខ្លួនទៅកាន់សាធារណជន ត្រូវបានគេសន្មតថា «សំណើរលក់មូលបត្រជាសាធារណៈ» កើតមានឡើង។ ចំពោះដំណើរការនៃការលក់ភាគហ៊ុនជាលើកដំបូងរបស់ក្រុមហ៊ុនមួយត្រូវបានគេហៅថា សំណើរបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង «IPO»។[4]

### ១.៤.២ ទីផ្សារបន្ទាប់

ដោយសារតែវិនិយោគិនមួយចំនួនយល់ឃើញថា ការប្រើប្រាស់មូលធនរបស់ពួកគេមិនមានការកំណត់ជាក់លាក់ ដូចនេះហើយភាគច្រើននៃមូលបត្រ អាចចរចារទិញលក់បាន។ នេះមានន័យថា ភាគហ៊ុន

[4] បៀន សាំង,២០១១, *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ*, ទំព័រទី១៧

អាចផ្លាស់ប្តូរបានដោយសេរី ពីអ្នកលក់ម្នាក់ទៅអ្នកទិញម្នាក់ទៀត ដោយតម្លៃកំណត់មួយដោយមានការព្រមព្រៀង និងពេញចិត្តដោយភាគីទាំងពីរ តាមរយៈការផ្តល់ភាគហ៊ុនទៅឲ្យអ្នកទិញ។ ប័ណ្ណកម្មសិទ្ធិស្របច្បាប់របស់ភាគហ៊ុន នឹងត្រូវផ្ទេរទៅឲ្យអ្នកទិញនៅពេលដែលភាគហ៊ុនត្រូវគេបានផ្តល់មកឲ្យភាគីអ្នកទិញ។ ការកំណត់ថ្លៃ និងការផ្តល់កម្មសិទ្ធិលើមូលបត្រកើតឡើងនៅកន្លែងមួយដែលគេស្គាល់ថាទីផ្សារបន្ទាប់។ ទីផ្សារបន្ទាប់ ជាកន្លែងដែលការជួញដូរមូលបត្រត្រូវបានកើតឡើងជាប្រចាំរវាងអ្នកលក់ និងអ្នកទិញមូលបត្រ។ ទឹកប្រាក់ដែលកើតចេញពីសកម្មភាពនេះ ត្រូវបង់ឲ្យទៅភាគហ៊ុននិកដែលលក់ មិនមែនបង់ទៅឲ្យក្រុមហ៊ុនបោះផ្សាយដំបូងនោះទេ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រមិនទទួលបានផលចំណេញជាហិរញ្ញវត្ថុពីការជួញដូរមូលបត្រកើតឡើងនៅលើទីផ្សារបន្ទាប់នោះទេ ហើយមូលបត្រទាំងអស់ដែលជួញដូរនៅលើទីផ្សារបន្ទាប់អាចត្រូវបានជួញដូរនៅក្នុងទីផ្សារមូលបត្រ ឬនៅក្រៅទីផ្សារមូលបត្រដែលគេហៅថា ទីផ្សាររំលងបញ្ជរ (Over the Counter)។[5] យើងអាចនិយាយថា ទីផ្សារបន្ទាប់នេះជាទីផ្សារមួយដែលមានមុខងារនៃទីផ្សារមូលបត្រ និងទីផ្សាររំលងបញ្ជរ ក្នុងការផ្តល់ទីកន្លែងមួយក្នុងការកំណត់តម្លៃភាគហ៊ុនព្រមទាំងផ្តល់មូលបត្រទៅឲ្យអ្នកទិញ។

## ១.៥ មូលបត្រ

នៅលើទីផ្សារមូលបត្រ ទំនិញរបស់ទីផ្សាររួមមានច្រើនប្រភេទផ្សេងៗគ្នា ប៉ុន្តែបើពិនិត្យទៅតាមប្រវត្តិសាស្ត្រ និងតាមរបៀបហៅមានលក្ខណៈរួមគ្នា។ បណ្តាប្រភេទទំនិញនេះសុទ្ធតែមានឈ្មោះរួមហៅថា មូលបត្រ។ មូលបត្រ គឺជាទំនិញហិរញ្ញវត្ថុមួយប្រភេទដែលមានលក្ខណៈប្លែកពីគេ និងតម្លៃរបស់វាមិនមានទំនាក់ទំនងទៅនឹងទ្រង់ទ្រាយ ឬរូបរាងរបស់វាទេ ប៉ុន្តែអាស្រ័យទៅនឹងសិទ្ធិកាន់កាប់នូវផលប្រយោជន៍នាពេលអនាគត និងមិនមានតម្លៃប្រើប្រាស់ ដូចជា អង្ករ សាច់ ដែកថែប សាំង ឡាន ម៉ូតូ។ ដំណើរការប្រើប្រាស់មូលបត្រ គឺការរក្សាវាទុកនៅក្នុងដៃដូចជា មធ្យោបាយមួយដើម្បីបង្កើតជា តម្លៃថ្មី គឺប្រាក់ចំណេញ។ មូលបត្រជាទំនិញពិសេសម្យ៉ាងដែលប្រមូលនូវមូលធនពីកន្លែងលើសមកកន្លែងខ្វះ ពីអ្នកផ្គត់ផ្គង់មូលធន ដល់អ្នកត្រូវការមូលធន។ មូលបត្រ ជាក្រដាសបញ្ជាក់ពីសិទ្ធិរបស់ម្ចាស់កម្មសិទ្ធិមួយ ចំណែកនៅក្នុងសហគ្រាសណាមួយនោះត្រូវបានគេហៅថា ភាគហ៊ុន ចំណែកឯបញ្ជាក់ពីម្ចាស់បំណុលលើសញ្ញាប័ណ្ណ។

មូលបត្រមានចំណុចពិសេសដូចខាងក្រោម៖

- ជាក្រដាសបញ្ជាក់ពីតម្លៃទ្រព្យសម្បត្តិរបស់ម្ចាស់កម្មសិទ្ធិ
- ជាឧបករណ៍ហិរញ្ញវត្ថុរយៈពេលមធ្យម និងរយៈពេលវែង
- ត្រូវបានការពារពីច្បាប់មូលបត្រ

[5] បៀន សាំង,២០១១, *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ*, ទំព័រទី១៨

- ត្រូវបានអនុញ្ញាតិឲ្យដោះដូរផ្ទេរសិទ្ធិនៅលើទីផ្សារមូលបត្រ មានន័យថា ភាពដែលអាចដូរជាសាច់ប្រាក់ខ្ពស់ (សន្ទនីយភាព-Liquidity)។

រូបភាពទី១៖ ភាពខុសគ្នារវាងសញ្ញាបណ្ណ និងភាគហ៊ុន

ភាពខុសគ្នារវាងសញ្ញាបណ្ណ និងភាគហ៊ុន មានដូចក្នុងតារាងខាងក្រោម៖

| **សញ្ញាបណ្ណ** | **ភាគហ៊ុន** |
|---|---|
| ១. ក្លាយជាម្ចាស់បំណុល | ១. ក្លាយជាម្ចាស់កម្មសិទ្ធិ |
| ២. សិទ្ធិទាមទារទ្រព្យសម្បត្តិខ្ពស់ជាងភាគហ៊ុន | ២. សិទ្ធិទាមទារទ្រព្យសម្បត្តិទាបជាងសញ្ញាបណ្ណ |
| ៣. ការវិនិយោគមានរយៈពេលកំណត់ | ៣. ការវិនិយោគគ្មានកាលកំណត់ លើកលែងក្រុមហ៊ុនត្រូវបិទទ្វាជម្រះបញ្ជី |
| ៤. ចំណូលការប្រាក់ថេរ និងទៀងទាត់ បង់ដោយអ្នកបោះផ្សាយ | ៤. ការទូទាត់ភាគលាភផ្អែកលើគោលនយោបាយ និងទិន្នផលអាជីវកម្មរបស់ក្រុមហ៊ុន |
| ៥. ថ្លៃមានបម្រែបម្រួលតិចតួច | ៥. ថ្លៃមានបម្រែបម្រួលខ្ពស់ជាង |
| ៦. មិនសូវមានសន្ទនីយភាព | ៦. មានសន្ទនីយភាពខ្ពស់ជាង |
| ៧. ឯកតាបញ្ញោអប្បបរមាគឺ ១ ឯកតានៃសញ្ញាបណ្ណ (មានតម្លៃចារឹកស្តង់ដា ១00,000 រៀល) | ៧. ឯកតាបញ្ញោអប្បបរមា គឺ ១ ភាគហ៊ុន |

ប្រភព៖ គេហទំព័រ ផ.ម.ក (២០២០), សំនួរ-ចម្លើយ

### ១.៥.១ ប័ណ្ណភាគហ៊ុន

ចំពោះក្រុមហ៊ុនការបោះផ្សាយប័ណ្ណភាគហ៊ុន មានប្រយោជន៍ជាង គឺការបោះផ្សាយ បណ្ណាក្រដាសបញ្ជាក់បំណុលពីព្រោះ ក្រុមហ៊ុនរក្សាលុយដែលមិនចាំបាច់ត្រូវសងការប្រាក់តាមរយៈពេលកំណត់។ ចំពោះការទិញភាគហ៊ុន បណ្ដាម្ចាស់ភាគហ៊ុនត្រូវបានរក្សាភាគហ៊ុន របស់ក្រុមហ៊ុនមានន័យថា ម្ចាស់ភាគហ៊ុនថ្មីនឹងបានចែកសិទ្ធិកម្មសិទ្ធិពីម្ចាស់ភាគហ៊ុនដំបូង។ ប័ណ្ណភាគហ៊ុន គឺជាក្រដាសមួយប្រភេទដែលបញ្ជាក់ពីសិទ្ធិរបស់ម្ចាស់ភាគហ៊ុនចំពោះក្រុមហ៊ុន។ ប័ណ្ណភាគហ៊ុន ជាក្រដាសដែលបញ្ជាក់ពីការវិនិយោគមូលធនរបស់បុគ្គលម្នាក់ នៅក្នុងក្រុមហ៊ុនមួយ។ បណ្ដាម្ចាស់ភាគហ៊ុន អ្នកទិញភាគហ៊ុន របស់ក្រុមហ៊ុនដែលមិនមែនជាម្ចាស់បំណុលចំពោះក្រុមហ៊ុនទេ ប៉ុន្តែជាអ្នកចូលរួមមូលធនជាមួយនឹងក្រុមហ៊ុនធ្វើប្រតិបត្តិការ ពោលជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន។

នៅក្នុងប្រវត្តិសាស្ត្រ ប្រភេទភាគហ៊ុន កើតឡើងមុនដំបូង គឺជាប្រភេទភាគហ៊ុន មានសរសេរឈ្មោះម្ចាស់កម្មសិទ្ធិហៅថា Registered Stock។ ទម្រង់ភាគហ៊ុន នេះមានចំណុចខ្សោយ គឺការផ្ទេរសិទ្ធិមានការពិបាកនៅពេលមានការផ្ទេរសិទ្ធិឲ្យអ្នកផ្សេងត្រូវចុះបញ្ជីនៅឯស្ថាប័នបោះផ្សាយ និងត្រូវបានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនភាគហ៊ុនអនុញ្ញាតិ។ ដល់សតវត្សទី ១៨ Bearer Stock កើតឡើង ជាប្រភេទភាគហ៊ុន ដែលមិនសរសេរឈ្មោះម្ចាស់កម្មសិទ្ធិ។ នៅសតវត្សទី ១៩ ជាមួយនឹងផលប្រយោជន៍នៃការផ្ទេរកម្មសិទ្ធិ បានក្លាយជាងាយស្រួលតាមរបៀបដោះដូរដៃគូ ដែលមិនចាំបាច់ត្រូវមានសំណុំបែបបទតាមផ្លូវច្បាប់ស្មុគស្មាញ។

ប័ណ្ណភាគហ៊ុន គឺជាក្រដាសប្រាក់ដែលបញ្ជាក់ពីសិទ្ធិក្នុងកម្មសិទ្ធិរបស់ម្ចាស់ភាគហ៊ុនចំពោះក្រុមហ៊ុនមួយ ឬជាក្រដាសបញ្ជាក់ពីការវិនិយោគមូលធនរបស់បុគ្គលម្នាក់នៅក្នុងក្រុមហ៊ុនមួយ។ ដូចដែរ យើងធ្លាប់បានដឹងរួចមកហើយថាមូលបត្រមាន ២ប្រភេទធំៗ គឺមូលបត្របំណុល និងមូលបត្រកម្មសិទ្ធិ។ នៅក្នុងបរិបទប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានផ្តល់ការយកចិត្តទុកដាក់ជាអាទិភាពចំពោះទីផ្សារមូលបត្រកម្មសិទ្ធិ ក្នុងដំណាក់កាលដំបូងនៃការដាក់ឲ្យដំណើរការទីផ្សារមូលបត្រកម្ពុជា។

មូលបត្រកម្មសិទ្ធិ គឺជាប្រភេទមួយនៃមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយ។ នៅពេលដែលសាធារណជនសម្រេចចិត្តវិនិយោគលើមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយមានន័យថា អ្នកវិនិយោគទិញកម្មសិទ្ធិមួយផ្នែករបស់ក្រុមហ៊ុននោះដែលត្រូវបានគេស្គាល់ថាជា ភាគហ៊ុន។

ផលចំណេញ ដែលទទួលបានពីការវិនិយោគសាច់ប្រាក់នៅក្នុងការទិញមូលបត្ររបស់ក្រុមហ៊ុនមួយ គឺអាស្រ័យទៅលើភាពជោគជ័យ ឬបរាជ័យនៃក្រុមហ៊ុន។ ប្រសិនបើ ក្រុមហ៊ុនមានដំណើរការល្អ ឬអាចទទួលបានប្រាក់ចំណេញពីផលិតកម្ម ឬសេវាកម្មរបស់ខ្លួននោះអ្នកវិនិយោគដែលបានទិញភាគហ៊ុនរបស់ក្រុមហ៊ុននឹងទទួលបាននូវផលប្រយោជន៍ពីភាពជោគជ័យនេះ។

### ១.៥.២ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត និងភាគហ៊ុនបុរិមា

#### ១.៥.២.១ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត

ភាគហ៊ុនមានសិទ្ធិបោះឆ្នោតទាំងអស់ ដែលធ្វើការជួញដូរជាសាធារណៈ ត្រូវបោះផ្សាយដោយក្រុមហ៊ុនបោះផ្សាយ អនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្រនៃប្រទេសនីមួយៗ។ មូលបត្រកម្មសិទ្ធិ គឺជាមូលបត្រដែលមិនមានរយៈពេលកំណត់ គឺតាមការស្ថិតស្ថេររបស់ក្រុមហ៊ុន និងបែងចែកភាគលាភនៅចុងឆ្នាំ។

លក្ខណៈពិសេសរបស់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតមានដូចជា៖

- មានសិទ្ធិបោះឆ្នោត
- ជាម្ចាស់ភាគហ៊ុនពិតប្រាកដ

- ទទួលបានភាគលាភប្រែប្រួលទៅតាមប្រាក់ចំណេញរបស់ក្រុមហ៊ុន
- ជាមូលបត្រមិនមានរយៈពេលកំណត់
- មានការទូទាត់សំណងក្រោយ ភាគហ៊ុនបុរិមា នៅពេលក្រុមហ៊ុនក្ស័យធុន
- មានហានិភ័យខ្ពស់ជាង ភាគហ៊ុនបុរិមា
- ទទួលបានប្រយោជន៍ (ភាគលាភ) ក្រោយគេ។

### ១.៥.២.២ ភាគហ៊ុនបុរិមា

ក្រៅពីភាគហ៊ុនមានសិទ្ធិបោះឆ្នោត ក្រុមហ៊ុនខ្លះក៏អាចបោះផ្សាយភាគហ៊ុនបុរិមាផងដែរ ភាគហ៊ុនបុរិមាផ្តល់ឲ្យអ្នកវិនិយោគនូវហានិភ័យនៃការខាតបង់ប្រាក់វិនិយោគតិចជាងការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត ប៉ុន្តែក៏ផ្តល់នូវចំណូលសរុបមានកម្រិតផងដែរ ចំណូលដែលអាចទទួលបានពីការវិនិយោគភាគហ៊ុនបុរិមារួមមាន ចំណូលដែលទទួលបានពីការវិនិយោគជាភាគលាភបូកជាមួយការប្រែប្រួលតម្លៃណាមួយរបស់ភាគហ៊ុននៅលើទីផ្សារ។[6]

ជាទូទៅ អ្នកកាន់កាប់ភាគហ៊ុនបុរិមាត្រូវបានធានាថានឹងទទួលបាននូវការទូទាត់ភាគលាភដែលភាគលាភនោះតែងតែបង់ទៅឲ្យភាគហ៊ុនិកកាន់កាប់ភាគហ៊ុនបុរិមា មុនភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត។

លក្ខណៈពិសេសរបស់ភាគហ៊ុនបុរិមាមានដូចជា៖

- ទទួលបានភាគលាភថេរ
- មិនមានសិទ្ធិបោះឆ្នោត
- មានហានិភ័យទាបជាង ភាគហ៊ុនមានសិទ្ធិបោះឆ្នោត
- មានការទូទាត់សំណងក្រោយសញ្ញាប័ណ្ណនៅពេលក្រុមហ៊ុនក្ស័យធុន
- ជាមូលបត្រមិនមានរយៈពេលកំណត់
- ជាម្ចាស់ភាគហ៊ុនពិតប្រាកដ
- ទទួលបានភាគលាភបន្ទាប់ពីសញ្ញាប័ណ្ណ។

## ១.៥.៣ ផលចំណេញដែលទទួលបានពីការវិនិយោគលើមូលបត្រ

ផលចំណេញដែលទទួលបានពីការវិនិយោគលើមូលបត្ររបស់ក្រុមហ៊ុនឯកជនដែលបានបោះផ្សាយលក់នៅលើទីផ្សារមូលបត្រមានពីរ ប្រភេទសំខាន់ៗ៖

- ភាគលាភ

[6] សួន ចំរើន,២០១៨-២០១៩, ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១

- ប្រាក់ចំណេញមូលធន

**១.៥.៣.១ ភាគលាភ**

នៅពេលក្រុមហ៊ុនបោះផ្សាយ ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ហើយទទួលបានប្រាក់ចំណេញ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន អាចប្រកាសបែងចែកចំណែកណាមួយនៃប្រាក់ចំណេញ ឬវិនិយោគជាថ្មីទៅតាមកម្រិតភាគលាភដែលទទួលបានដើម្បីទិញមូលបត្រថ្មីបន្ថែមទៀតនៅក្នុងក្រុមហ៊ុន។

គោលនយោបាយបែងចែកភាគលាភរបស់ក្រុមហ៊ុនមួយ គឺអាស្រ័យទៅលើកត្តាមួយចំនួនដូចជាស្ថានភាពសាច់ប្រាក់របស់ក្រុមហ៊ុន ឬស្ថានភាពកំណើននៃប្រាក់ចំណេញរបស់ក្រុមហ៊ុនផ្ទាល់ សេចក្តីត្រូវការលើការចំណាយមូលធន ព្រមទាំងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនជាដើម។ ភាគលាភដែលក្រុមហ៊ុនផ្តល់ឲ្យវិនិយោគិនមានទម្រង់ជា២ប្រភេទ គឺសាច់ប្រាក់ និងសន្លឹកហ៊ុនដែលសមមូលទៅនឹងភាគលាភដែលទទួលបាន។[7]

**១.៥.៣.២ ប្រាក់ចំណេញមូលធន**

មូលបត្រកម្មសិទ្ធិ ឬភាគហ៊ុនត្រូវបានទិញ និងលក់ជារៀងរាល់ថ្ងៃក្នុងអំឡុងពេលជួញដូរប្រចាំថ្ងៃដែលនាំឲ្យតម្លៃរបស់មូលបត្រតែងតែប្រែប្រួលគ្រប់ពេលវេលា។ នៅពេលដែលតម្លៃមូលបត្រកើនឡើងខ្ពស់ជាងតម្លៃដែលអ្នកវិនិយោគបានទិញនោះ អ្នកវិនិយោគអាចលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួនដើម្បីទទួលបានប្រាក់ចំណេញ ហើយប្រាក់ចំណេញនេះជាប្រាក់ចំណេញមូលធន។ ផ្ទុយមកវិញ ប្រសិនបើអ្នកវិនិយោគលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួនក្នុងកម្រិតមួយទាបជាងតម្លៃដែលគាត់បានទិញ នោះគាត់ត្រូវប្រឈមនឹងការខាតបង់មូលធន។

ផលចំណេញដែលបានមកពីការវិនិយោគលើមូលបត្រកម្មសិទ្ធិ ទាំងភាគលាភ និងប្រាក់ចំណេញមូលធនជួនកាលគឺអាស្រ័យទៅលើដំណើរការពាណិជ្ជកម្មរបស់ក្រុមហ៊ុន ពោលគឺ ភាគលាភដែលកើតចេញពីប្រាក់ចំណេញ ដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុន ចំណែកឯប្រាក់ចណេញមូលធន គឺអាស្រ័យទៅលើតម្រូវការវិនិយោគទិញមូលបត្រកម្មសិទ្ធិរបស់អ្នកវិនិយោគនៅលើទីផ្សារមូលបត្រជាទូទៅ តម្រូវការមូលបត្របានឆ្លុះបញ្ចាំងតាមរយៈទិដ្ឋភាពនានាពាក់ព័ន្ធនឹងប្រតិបត្តិការនាពេលបច្ចុប្បន្ន និងអនាគតរបស់ក្រុមហ៊ុន។ តម្រូវការមូលបត្រភាគច្រើន កើតឡើងគឺដោយសារតែអ្នកវិនិយោគជាច្រើនមានបំណងចង់ទិញមូលបត្រណាមួយ ដែលធ្វើឲ្យតម្លៃរបស់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនឡើងថ្លៃ។ ផ្ទុយមកវិញ ប្រសិនបើក្រុមហ៊ុនមិនទទួល

[7] បៀន សាំង,២០១១, *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ*, ទំព័រទី៣៩

បានប្រាក់ចំណេញនៅក្នុងអាជីវកម្មរបស់ខ្លួន ឬការលក់ច្រើនជាងការទិញមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុន នោះតម្លៃមូលបត្រកម្មសិទ្ធិអាចធ្លាក់ចុះទាបជាងតម្លៃដែលបានទិញ។

## ១.៦ គុណសម្បត្តិ និងគុណវិបត្តិរបស់ទីផ្សារមូលបត្រដល់សេដ្ឋកិច្ចជាតិ

ទីផ្សារមូលបត្រ គឺជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ គេតែងតែនិយាយថា ទីផ្សារមូលបត្រ គឺជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំងមូល។ ជាការពិតណាស់រាល់ការប្រែប្រួលនៃបរិបទជាតិ និងអន្តរជាតិទាក់ទងនឹងសេដ្ឋកិច្ច សង្គម និងនយោបាយ វានឹងធ្វើឲ្យមានផលប៉ះពាល់ទៅដល់ទីផ្សារមូលបត្រផងដែរ ពីព្រោះសន្ទស្សន៍ក្រុមហ៊ុនរបស់ផ្សារមូលបត្រ វាបានឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចជាតិ។ យ៉ាងណាមិញ ទីផ្សារមូលបត្រ គឺមានតាំងគុណសម្បត្តិ និងគុណវិបត្តិចំពោះសេដ្ឋកិច្ចជាតិ។

### ១.៦.១. គុណសម្បត្តិរបស់ទីផ្សារមូលបត្រ

ទីផ្សារមូលបត្របានដើរតួនាទីយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិ៖[8]

- ទីផ្សារមូលបត្រជួយជំរុញឲ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធន ដែលនៅសេសសល់មិនមានតម្រូវការប្រើប្រាស់ យកទៅវិនិយោគក្នុងវិស័យសេដ្ឋកិច្ច។
- ទីផ្សារមូលបត្រ គឺជាមធ្យោបាយជួយប្រមែប្រមូលកៀរគរនូវប្រភពមូលធនដែលនៅទំនេរតូចៗ មិនទាន់មានតម្រូវការប្រើប្រាស់ ប្រមូលផ្តុំជាមូលធនធំមួយ ដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ច។
- ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តនូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឲ្យរីកចម្រើន។
- ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយ ដើម្បីទាក់ទាញនិងស្រូបយកនូវមូលធនពីបរទេស។
- ទីផ្សារមូលបត្រជួយជំរុញឲ្យបណ្តាក្រុមហ៊ុននានា ធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងអភិបាលកិច្ចល្អ។
- ទីផ្សារមូលបត្រ ជួយជំរុញឲ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក។
- ទីផ្សារមូលបត្រជួយបង្កើតនូវទម្លាប់នៃការវិនិយោគ។
- ជំរុញអោយមានចលនាសាច់ប្រាក់ មានឱកាស ហើយបង្កើតប្រាក់កាន់តែច្រើន នៅក្នុងរយៈពេលខ្លី។
- ចំពោះអ្នកវិនិយោគទៅលើមូលបត្រកម្មសិទ្ធិ គឺទទួលបានភាគលាភជាប្រចាំ។
- ជម្រុញអោយមានការវិនិយោគ ទាក់ទាញវិនិយោគិន អោយមកវិនិយោគនៅប្រទេសកម្ពុជា ដូច្នេះក៏ធ្វើអោយមានការបង្កើតការងារ អោយអ្នកគ្មានការងារធ្វើ។ វិនិយោគិន ក៏អាចយកប្រាក់ដែលបានមកពី

[8] http://www.secc.gov.kh/khmer/faq.php?pn=2 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០), សំនួរ-ចម្លើយ

ការវិនិយោគលើវិស័យមូលបត្រ ទៅវិនិយោគលើវិស័យផ្សេងទៀត ដើម្បីជម្រុញអោយសេដ្ឋកិច្ចកម្ពុជាកាន់តែរីកចម្រើនទៅមុខ។

### ១.៦.២. គុណវិបត្តិរបស់ទីផ្សារមូលបត្រ

ទីផ្សារមូលបត្រមានគុណវិបត្តិមួយចំនួន ដែលគេតែងតែជួបប្រទះនូវបញ្ហាដូចខាងក្រោម[9]៖

- ការឆក់ឱកាសកេងចំណេញក្នុងការជួញដូរ (Speculation) គឺជាការទិញ-លក់មួយ ដែលមានការគិតគូរយ៉ាងហ្មត់ចត់ ដើម្បីទទួលបានផលចំណេញ ដោយប្រឈមនឹងហានិភ័យ។ អ្នកឆក់ឱកាសកេងចំណេញក្នុងការជួញដូរ នេះអាចធ្វើការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្ន ដោយរំពឹងថានាពេលអនាគត នឹងទទួលបានប្រាក់ចំណេញ ទៅតាមការជួញដូរមួយលើកៗ។ ការឆក់ឱកាសកេងចំណេញក្នុងការជួញដូររបៀបនេះ វានឹងបង្ករឲ្យមានឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ព្រឹត្តិការណ៍នេះ ធ្វើឲ្យមានភាពងាយស្រួលនៅពេលពួកគេព្រមព្រៀងគ្នាក្នុងការជួញដូរ ដែលនាំឲ្យស្ថានភាពនៅលើទីផ្សារមានពេលខ្លះធ្វើឲ្យភាគហ៊ុនខ្វះ ឬ លើស ហើយធ្វើឲ្យមានចលនាឡើងចុះតម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ។
- ការជួញដូរផ្ទៃក្នុង គឺមានបុគ្គលជាបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជី ឆ្លៀតឱកាសយកព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន ដើម្បីធ្វើការជួញដូរភាគហ៊ុន ដើម្បីស្វែងរកចំណេញរបស់ខ្លួន ដែលមានឥទ្ធិពលដល់តម្លៃភាគហ៊ុនរបស់ទីផ្សារមូលបត្រ ដែលព័ត៌មាននោះមិនមែនព័ត៌មានសាធារណៈ (ព័ត៌មានសម្ងាត់)។
- ការជួញដូរក្លែងក្លាយនិងការប្រើឧបាយកលក្នុងទីផ្សារ គឺជាការធ្វើសកម្មភាពណាមួយ ឬគេចវេះមិនធ្វើសកម្មភាពដែលបណ្តាលឲ្យ ឬអាចបណ្តាលឲ្យលក្ខណៈក្លែងបន្លំ ឬនាំឲ្យមានការយល់ខុសចំពោះការជួញដូរមូលបត្រ ឬធ្វើប្រតិបត្តិការធ្វើផែនការជួញដូរដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រនៅលើទីផ្សារមូលបត្រ។
- សេចក្តីថ្លែងការណ៍ ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឲ្យមានការយល់ខុសធ្ងន់ធ្ងរដែលបណ្តាលឲ្យមានសារធារណជនទិញលក់មូលបត្រ ឬបណ្តាលឲ្យមានការកើនឡើង ឬការថយចុះ ឬ នៅថេរចំពោះតម្លៃនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រ។
- ក្រុមហ៊ុនដែលបោះពុម្ពផ្សាយលក់មូលត្រ តម្រូវឲ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាពនិងអភិបាលកិច្ចអាជីវកម្មល្អ ដែលទាំងនេះជាបន្ទុកមួយសម្រាប់ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនបានផ្លែផ្កាមកវិញនូវទុនរយៈពេលវែងក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។

[9] http://www.secc.gov.kh/khmer/faq.php?pn=2 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០). សំនួរ.ចម្លើយ

- អាចប៉ះពាល់ដល់សតិអារម្មណ៍ ហើយត្រូវបានប្រើពេលច្រើនដើម្បីគិត និងសិក្សាពីទីផ្សារមូលបត្រនោះ វាក៏អាចប៉ះពាល់ទៅដល់សេដ្ឋកិច្ចជាតិផងដែរ។

ដូចនេះយោងតាមការរៀបរាប់ គុណសម្បត្តិ និងគុណវិបត្តិរបស់ទីផ្សារមូលបត្រដល់សេដ្ឋកិច្ច យើងឃើញថា អ្វីក៏មានល្អ និងអាក្រក់ ប៉ុន្តែយើងត្រូវរួមគ្នាលុបបំបាត់អាក្រក់អោយកាន់តែតិចទៅៗ ដើម្បីអោយមានតែភាពល្អហើយអោយទីផ្សារមូលបត្រផ្តល់ផលកាន់តែល្អទៅថ្ងៃអនាគត។

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ គណៈកម្មការមូលបត្រ កម្ពុជា

# ជំពូកទី២

# ស្ថានភាពទូទៅរបស់គណៈកម្មការមូលបត្រកម្ពុជា

## ២.១. ប្រវត្តិសង្ខេបរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាដែលត្រូវបានហៅកាត់ថា គ.ម.ក ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧។[10] ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.ក ត្រូវបានធ្វើឡើងដោយអនុលោមទៅតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជាដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០៨។ ជាចុងក្រោយ គណៈកម្មការមូលបត្រកម្ពុជាត្រូវបានសម្ពោធជាផ្លូវការក្រោមអធិបតីភាពរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជាអាណត្តិទី១ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩។ គណៈកម្មការមូលបត្រកម្ពុជា គឺជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឲ្យមានឲ្យមានការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងភាពត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។

## ២.២. ទីស្នាក់ការរបស់គណៈកម្មការមូលបត្រកម្ពុជា




រូបភាពទី២៖ ផែនទីទៅកាន់ ទីស្នាក់ការរបស់គណៈកម្មការមូលបត្រកម្ពុជា

[10] http://www.secc.gov.kh/khmer/faq.php?pn=2 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០). សំនួរ-ចម្លើយ

គណៈកម្មការមូលបត្រកម្ពុជា មានទីតាំងនៅ ផ្ទះលេខ ៩៩ ផ្លូវលេខ ៥៩៨ សង្កាត់ ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។[11]

## ២.៣. រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា

### ២.៣.១. រូបសញ្ញា




រូបភាពទី៣៖ រូបសញ្ញារបស់គណៈកម្មការមូលបត្រ

- រូបហង្សពណ៌មាស
- រូបស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្តាំរំលេចស្រមោលពណ៌ប្រផេះ
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា" គណៈកម្មការមូលបត្រកម្ពុជា" ព័ទ្ធជុំវិញនៅផ្នែកខាងក្រោមដោយអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE COMMISSION OF CAMBODIA"។[12]

[11] http://www.secc.gov.kh/khmer/m19.php?pn=1 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០), ទំនាក់ទំនង គ.ម.ក

[12] http://www.secc.gov.kh/khmer/m17.php?pn=1 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០), រូបសញ្ញា គ.ម.ក

### ២.៣.២. អត្ថន័យនៃរូបសញ្ញា

រូបសញ្ញារបស់ គ.ម.ក មានអត្ថន័យដូចតទៅ៖[13]

- រូបហង្សពណ៌មាស តំណាងឲ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការមូលបត្រ និងធានាឲ្យមានការដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធិភាព ភាពមានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ តំណាងឲ្យភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។
- រូបហង្សពណ៌មាសដែលឈរលើរង្វង់ថាស ដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងម្ខាងទៀតជាន់លើផ្ទៃពណ៌ប្រផេះ ចង់បង្ហាញថាភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធិភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបស្លឹកឈើ តំណាងឲ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ២.៣.៣. មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា

មូលហេតុដែល គ.ម.ក រើសយករូបហង្សពណ៌មាសធ្វើជារូបសញ្ញាដោយសារ៖[14]

- រូបហង្សពណ៌មាសជាប់ពាក់ព័ន្ធទៅនឹងដំណើរការវិវឌ្ឍនៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ជាលើកដំបូងនៅលើ ប្រាក់ប្រាសាទ ក្នុងរជ្ជកាលព្រះបាទអង្គដួងដើម្បីរំលឹកដល់លោក សំអាងហង្ស ដែលព្រះបាទអង្គឌួងបញ្ជូនឲ្យទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស ហើយលោកក៏បានរួមចំណែកយ៉ាងខ្លាំងក្នុងការធ្វើឲ្យរូបិយវត្ថុខ្មែរមានអត្តសញ្ញាណច្បាស់លាស់ និងដាក់ឲ្យចរាចរក្នុងសេដ្ឋកិច្ច។
- រូបហង្សពណ៌មាសនេះ ជារូបសញ្ញាតំណាងឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាសម័យសង្គមរាស្ត្រនិយម សម័យសាធារណរដ្ឋ និងក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ ដែលហេតុការណ៍នេះ ត្រូវគ្នា

[13] http://www.secc.gov.kh/khmer/m17.php?pn=1 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០), អត្ថន័យរូបសញ្ញា

[14] http://www.secc.gov.kh/khmer/m17.php?pn=1 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០), មូលហេតុ

នឹងគណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុមួយ ហើយមានប្រធានជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់។

### ២.៣.៤. ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា

ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា «ព្រះរាជាណាចក្រកម្ពុជា» ផ្នែកកណ្តាលមានសញ្ញា ប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា «គណៈកម្មការមូលបត្រកម្ពុជា»។[15]



រូបភាពទី៤៖ ត្រារបស់គណៈកម្មការមូលបត្រ

## ២.៤. ចក្ខុវិស័យ និងបេសកកម្ម

### ២.៤.១. ចក្ខុវិស័យ

គណៈកម្មការមូលបត្រកម្ពុជាហៅកាត់ថា គ.ម.ក ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ គ.ម.ក មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពី សាធារណជន ឬអ្នកវិនិយោគមូលបត្រដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅ កម្ពុជា។[16]

[15] http://www.secc.gov.kh/khmer/m17.php?pn=1 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០), ត្រារបស់ គ.ម.ក

[16] http://www.secc.gov.kh/khmer/m11.php?pn=1 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០), ចក្ខុវិស័យ

### ២.៤.២. បេសកកម្ម

គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងបំពេញនូវបេសកកម្មដូចខាងក្រោម៖[17]

- ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធិភាព និងជំរុញឲ្យមានការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ។
- ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.៥. គោលដៅ និងគោលបំណងទូទៅរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាមានគោលដៅ និងគោលបំណងដូចជា៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្ររួមទាំងទីផ្សារមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតិជូនប្រតិបត្តិករទីផ្សារមូលបត្រ និងប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ។
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា។
- បង្កើត និងរក្សាទំនុកចិត្តអ្នកវិនិយោគដោយការពារសិទ្ធិរបស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- ជម្រុញការអភិវឌ្ឍន៍ទីផ្សារមូលបត្រ។
- ដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ។
- បង្ការ និងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

[17] http://www.secc.gov.kh/khmer/m11.php?pn=1 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០), បេសកកម្ម

## ២.៦. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាមានមុខងារដូចជា៖[18]

- ដាក់ឲ្យអនុវត្តនូវគោលនយោបាយដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ។
- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅកម្ពុជា រួមទាំងទីផ្សារមូលបត្ររដ្ឋ។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់។
- ដើរតួនាទីជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណដែលប៉ះពាល់ដល់ប្រយោជន៍របស់សមាជិកអ្នកចូលរួម និងវិនិយោគិន។
- ពិគ្រោះយោបល់ជាមួយបុគ្គល ដែលមានលក្ខណៈសម្បត្តិសមស្របដើម្បីបង្កើតការគោរពនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រ។
- បំពេញលក្ខខណ្ឌផ្សេងៗទៀតដែលមានចែងក្នុងអនុក្រឹត្យ។

## ២.៧. សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា

សមាជិករបស់ គ.ម.ក មានអាណត្តិរយៈពេល ៥ឆ្នាំ និងអាចត្រូវបានតែងតាំងសារជាថ្មី ឬក៏អាចផ្ទេរភារកិច្ចតាមសំណើររបស់ប្រធាន គ.ម.ក នៅពេលផុតអាណត្តិ។[19] ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកអាចត្រូវបានដកហូត ឬផ្លាស់ប្តូរភារកិច្ចមុនពេលអស់អាណត្តិ។

គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនដែលមានប្រធាន ១រូប ជាមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុព្រមទាំងមានសមាជិក ៨រូប ដែលមានដូចជា៖[20]

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ ១រូប
- តំណាងធនាគារជាតិនៃកម្ពុជា៖ ១រូប
- តំណាងក្រសួងពាណិជ្ជកម្ម៖ ១រូប
- តំណាងក្រសួងយុត្តិធម៌៖ ១រូប

---

[18] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ០៧ កញ្ញា ២០០៧, មាត្រា៧

[19] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ០៧ កញ្ញា ២០០៧, មាត្រា៥

[20] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ០៧ កញ្ញា ២០០៧, មាត្រា៦

- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី៖ ១រូប
- អគ្គនាយកនៃ គ.ម.ក៖ ១រូប
- អ្នកជំនាញដែលមានបទពិសោធន៍ក្នុងវិស័យមូលបត្រ ២រូប។

## ២.៨. អង្គការចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា

### ២.៨.១. រចនាសម្ព័ន្ធចាត់តាំង

គណៈកម្មការមូលបត្រកម្ពុជាមានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម៖[21]




រូបភាពទី៥៖ រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មការមូលបត្រ

### ២.៨.២. នាយកដ្ឋាននីមួយៗ

#### ២.៨.២.១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំផែនការ និងថវិការបស់ គ.ម.ក
- គ្រប់គ្រងកិច្ចការរដ្ឋបាល
- ផ្គត់ផ្គង់ និងជួសជុលសំភារៈបរិក្ខារការិយាល័យ
- ចាត់ចែងការងារពិធីការ
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជននានា
- រៀបចំគោលនយោបាយគ្រប់គ្រង និងជ្រើសរើសបុគ្គលិក

[21] http://www.secc.gov.kh/khmer/m14.php?pn=1 គេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា (២០២០),អង្គការចាត់តាំង

- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ គ.ម.ក
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន។

**២.៨.២.២. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ**

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រមានមុខងារ និងតួនាទីដូចជា៖

- រៀបចំលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុននានាបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំលក្ខខណ្ឌតម្រូវនានាទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ
- ត្រួតពិនិត្យលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈជាប្រចាំ
- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដារគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យ និងផ្តល់យោបល់លើការស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ
- ចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានា ដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិច និង/ឬតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ឬ/និង របាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រលក់ជាសាធារណៈ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងរបស់ ក្រុមហ៊ុនស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈប្រសិនបើមានការចាំបាច់ស្របតាមក្របខ័ណ្ឌការងារ
- គ្រប់គ្រងយន្តការបោះផ្សាយមូលបត្រជាសាធារណៈ

- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ ទៅនាយកដ្ឋានកិច្ចការគតិយុត្តដើម្បីធ្វើការស៊ើបអង្កេតបន្ត។

**២.៨.២.៣. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**

នាយកដ្ឋានអន្តរការីមូលបត្រមានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃនៅក្នុងទីផ្សារដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក
- ពិនិត្យ និងផ្តល់យោបល់ដល់ការស្នើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ
- ត្រួតពិនិត្យ និងតាមដាននូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ
- ត្រួតពិនិត្យជាក់ស្តែង ដល់ទីកន្លែងតាមការចាំបាច់នូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតនៅក្នុងទីផ្សារ។

**២.៨.២.៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានមុខងារ និងតួនាទីដូចតទៅ៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឲ្យធ្វើប្រតិបត្តិការជាមួយប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាតដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ

- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃបរតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងទៅតាមភាពចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រទៅនាយកដ្ឋានកិច្ចការគតិយុត្តដើម្បីធ្វើការស៊ើបអង្កេតបន្ត។

**២.៨.២.៥. នាយកដ្ឋានកិច្ចការគតិយុត្ត**

នាយកដ្ឋានកិច្ចការគតិយុត្តមានមុខងារ និងតួនាទីដូចតទៅ៖

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការរបស់ប្រតិបត្តិការទីផ្សារមូលបត្រ ប្រតិបត្តិការប្រព័ន្ធផាត់ទាត់និងទូទាត់ និងប្រតិបត្តិការរក្សាទុកមូលបត្រ ដើម្បីដាក់សុំការត្រួតពិនិត្យ និងសម្រេចពីអគ្គនាយកនៃ គ.ម.ក
- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការដែលស្នើដោយស្ថាប័ននិយ័តករ
- រៀបចំបទបញ្ញត្តិចាំបាច់នានា និងលើកសំណើធ្វើវិសោធនកម្មច្បាប់ នោងបទបញ្ញត្តិផ្សេងៗដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យមូលបត្រ
- ពង្រឹងការអនុវត្តច្បាប់ ឬបទបញ្ញត្តិពាក់ព័ន្ធវិស័យមូលបត្រ
- ទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែលល្មើសច្បាប់ ឬមិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូង និងនៅក្នុងទីផ្សារបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យនានាពាក់ព័ន្ធនឹងបុគ្គល ប្រព្រឹត្តល្មើសច្បាប់ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធទៅនឹងវិស័យមូលបត្រ
- សម្រុះសម្រួលដោះស្រាយវិវាទរវាងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ
- ចាត់វិធានការជាកពិន័យអន្តរការណ៍លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- រៀបចំសំណុំរឿងពាក់ព័ន្ធដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកនៃ គ.ម.ក។

### ២.៨.២.៦. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិមានមុខងារ និងតួនាទីដូចតទៅ៖

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានា ដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រង និងអភិវឌ្ឍវិស័យមូលបត្រ រៀបចំយុទ្ធសាស្ត្រដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ សិក្សាវាយតម្លៃ និងផ្តល់យោបល់
- សិក្សាស្រាវជ្រាវលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធច្បាប់ និងបទបញ្ញត្តិនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យមូលបត្រ
- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មីមុននឹងអនុញ្ញាតឲ្យបោះផ្សាយនៅលើទីផ្សារ
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ
- ធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់និងនៅក្នុងពិភពលោក
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា។

### ២.៨.៣. អង្គភាពសវនកម្មផ្ទៃក្នុង

គ.ម.ក មានអង្គភាពសវនកម្មផ្ទៃក្នុងមួយដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ប្រធាន គ.ម.ក ។ អង្គភាពសវនកម្មផ្ទៃក្នុងមានមុខងារ និងតួនាទី៖

- ត្រួតពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និងប្រតិបត្តិការនានារបស់ គ.ម.ក ក្នុងការិយបរិច្ឆេទសមស្រប ដើម្បីកំណត់ដល់ការអនុវត្តឲ្យបានសមស្របទៅតាមការរៀបចំផែនការ ការចេញបទបញ្ជា និងបទប្បញ្ញត្តិផ្សេងៗ ការចាត់តាំងការងារ និងការត្រួតពិនិត្យដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និងនីតិវិធីជាធរមាន និងស្របតាមគោលដៅរបស់ គ.ម.ក
- កំណត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋបាល និងប្រតិបត្តិការនានារបស់ គ.ម.ក
- ពិនិត្យភាពដែលអាចជឿជាក់បាន និងភាពពេញលេញនៃព័ត៌មាន ទិន្នន័យ និងវិធីសាស្ត្រនៃការរៀបចំរបាយការណ៍អំពីព័ត៌មាន និងទិន្នន័យទាំងនេះក្នុងការិយបរិច្ឆេទសមស្រប
- ពិនិត្យលើប្រព័ន្ធដែលបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ និងបទបញ្ញត្តិនានា ហើយលើកសំណើកែតម្រូវ និងកែលម្អ ប្រសិនបើមានកំហុស

- ពិនិត្យលើមធ្យោបាយក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ គ.ម.ក
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ធនធានរបស់ គ.ម.ក ហើយលើកសំណើដោះស្រាយ និងកែលំអការអនុវត្តន៍ប្រតិបត្តិការ
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការការចំណាយ ចំណូលថវិការបស់ គ.ម.ក ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីផ្ញើជូនប្រធាន និងសមាជិកនៃ គ.ម.ក ពិនិត្យ និងផ្តល់ការណែនាំ
- ធ្វើរបាយការណ៍សវនកម្មជូនដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក អំពីការប្រព្រឹត្តទៅរបស់នាយកដ្ឋាន ឬអង្គភាពដែលបានធ្វើសវនកម្មរួចហើយ
- ធ្វើសវនកម្មផ្ទៃក្នុង នៅពេលដែលមានការណែនាំរបស់រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំដើម្បីដាក់ជូនប្រធាន និងសមាជិកនៃ គ.ម.ក ពិនិត្យ និងសម្រេច
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុងជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការឲ្យបានគ្រប់គ្រាន់ និងសមស្រប ជាពិសេសកាត់បន្ថយការងារស្ទួនគ្នា។

# ជំពូកទី៣

# នីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

# ជំពូកទី៣
# នីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

## ៣.១. និយមន័យទីផ្សារដំបូង

ទីផ្សារដំបូង គឺជាទីផ្សារទ្រព្យសកម្ម ដែលនៅទីនោះមូលបត្រត្រូវបានបោះផ្សាយ និងលក់ជាលើកដំបូង តាមរយៈការធ្វើសំណើទិញ ឬដំណើរការដេញថ្លៃ។ ទីផ្សារដំបូង ត្រូវបានជួយសម្រួលដោយសម្ព័ន្ធក្រុមហ៊ុនធានាទិញមូលបត្រ ដែលនឹងដាក់តម្លៃដេញថ្លៃដំបូងក្នុងចន្លោះថ្លៃណាមួយសម្រាប់មូលបត្រណាមួយ។

## ៣.២. តើអ្វីទៅជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO)?

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គឺសំដៅដល់ការលក់ភាគហ៊ុនជាលើកដំបូង ឬបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតទៅកាន់សាធារណជន។[22]

## ៣.៣. មូលហេតុដែលក្រុមហ៊ុនធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO)

នាពេលបច្ចុប្បន្ន យើងសង្កេតឃើញថាវិស័យមូលបត្ររីកចម្រើននៅមានកម្រិតនៅឡើយ ទោះជាយ៉ាងណាមិញ រាជរដ្ឋាភិបាលកម្ពុជា ក៏ខិតខំជម្រុញវិស័យនេះអោយឈានទៅមុខកាន់តែខ្លាំង។ តើអ្នកទាំងអស់គ្នាមានឆ្ងល់ដែរឬទេ ថាតើហេតុអ្វីបានជាក្រុមហ៊ុនធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង?

មូលហេតុទាំងនោះរួមមាន ដូចខាងក្រោម៖

- បង្កើនមូលធនដើម្បីពង្រីកអាជីវកម្មរបស់ខ្លួនអោយកាន់តែធំទៅមុខទៀត
- ក្រុមហ៊ុនអាចប្រកបអាជីវកម្មដោយប្រសិទ្ធិភាព និងមានតម្លាភាព
- ផ្តល់នូវភាពងាយស្រួលក្នុងការស្វែងរកហិរញ្ញប្បទាន និងកាលានុវត្តភាពនៃការធ្វើហិរញ្ញប្បទាន
- ជម្រុញអោយសាធារណជនស្គាល់ពីក្រុមហ៊ុនកាន់តែច្បាស់ ដោយមិនចាំបាច់ធ្វើការផ្សព្វផ្សាយពីក្រុមហ៊ុនច្រើន
- ក្លាយជាក្រុមហ៊ុនមហាជនដោយមានម្ចាស់ភាគហ៊ុនច្រើន និងមានភាពច្បាស់លាស់
- ការបង្កើនសន្ទីយភាពមូលបត្រនៅលើទីផ្សារ ដោយមានភាពងាយស្រួលបម្លែងទៅជាសាច់ប្រាក់ និងមានចរាចរណ៍សាច់ប្រាក់លឿន

[22] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ ២

- ការពង្រីកមូលដ្ឋានភាគហ៊ុនិក
- រក្សាបុគ្គលិកខ្លួន និងទាក់ទាញអ្នកមានសមត្ថភាព
- បង្កើនកម្លាំងចិត្តរបស់បុគ្គល និងផលិតភាព
- ការលើកទឹកចិត្តផ្នែកពន្ធដារ

## ៣.៤. ហានិភ័យនៃការជួញដូរមូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន

ការជួញដូរភាគហ៊ុនអាចជួបនូវហានិភ័យមួយចំនួនដែលធ្វើឱ្យថ្លៃនៃភាគហ៊ុនធ្លាក់ចុះ ឬមានការប្រែប្រួលខ្លាំង។ ដូចនេះ គេអាចចាត់ថ្នាក់ហានិភ័យទាំងនោះ ជា ៣ប្រភេទចម្បងៗ ដូចតទៅ៖[23]

- ហានិភ័យជាប្រព័ន្ធ ឬហានិភ័យទីផ្សារ៖ គឺជាភាពមិនច្បាស់លាស់ដែលកើតមានឡើងចំពោះទីផ្សារទាំងមូល និងមិនអាចចៀសវាងបានតាមការធ្វើពិពិធកម្ម ដូចជា ហានិភ័យនៃការធ្លាក់ចុះសេដ្ឋកិច្ច ហានិភ័យអតិផរណា ហានិភ័យអស្ថេរភាពនយោបាយ ហានិភ័យនៃការកើនឡើងអត្រាការប្រាក់ ជាដើម។
- ហានិភ័យមិនមែនជាប្រព័ន្ធ៖ គឺជាភាពមិនច្បាស់លាស់ដែលកើតមានចំពោះក្រុមហ៊ុន ឬវិស័យណាមួយ ដែលអាចកាត់បន្ថយបានដោយការធ្វើពិពិធកម្ម។ ហានិភ័យទាំងនោះរួមមាន អសាធនីយភាពនៃក្រុមហ៊ុន ការកេងបន្លំផ្ទៃក្នុងនៃបញ្ជីគណនេយ្យ សកម្មភាពជួញដូរផ្ទៃក្នុង ជាដើម។
- ហានិភ័យសន្ទនីយភាព៖ សំដៅដល់ហានិភ័យដែលអ្នកទិញនិងអ្នកលក់មិនអាចរកគ្នាឃើញ ដើម្បីជួញដូរនៅពេលត្រូវការ និងនៅថ្លៃសមស្របមួយ ដោយសារកង្វះសន្ទនីយភាពក្នុងទីផ្សារ។

## ៣.៥. ការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ

### ៣.៥.១. គោលបំណង និងវិសាលភាពនៃអនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

ដើម្បីជម្រុញអោយវិស័យមូលបត្រនៅប្រទេសកម្ពុជាកាន់តែរីកចម្រើនទៅមុន ដោយសារវិស័យនេះជាវិស័យក្មេងខ្ចី និងថ្មីមួយដែលពុំទាន់សូវមានភាពទូលំទូលាយ ហើយប្រជាជនខ្មែរពុំសូវដឹងពីវិស័យមូលបត្រច្រើន រាជរដ្ឋាភិបាលបានខិតខំផ្សព្វផ្សាយអំពីវិស័យមូលបត្រនេះ ហើយក៏បានចេញអនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងគោលបំណងអភិវឌ្ឍវិស័យមូលបត្រអោយកាន់តែរីកចម្រើនទៅមុខ។[24]

អនុក្រឹត្យនេះផងដែរ មានវិសាលភាពអនុវត្តនូវក្នុងប្រទេសកម្ពុជា រួមមានចំពោះ៖[25]

[23] http://csx.com.kh/news/faq/listPosts.do?MNCD=7060 គេហទំព័រផ្សារមូលបត្រកម្ពុជា (២០២០), សំនួរ-ចម្លើយ

[24] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ០១អនក្រ.បក, 04 មករា ២០១៩, ទំព័រទី២

[25] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ០១អនក្រ.បក, 04 មករា ២០១៩, មាត្រា៣, ទំព័រទី២

- ក្រុមហ៊ុន ឬសហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។
- អ្នកវិនិយោគសាធារណៈរួមមានទាំងអ្នកវិនិយោគនិវាសនជន និងអនិវាសជន ដែលកាន់កាប់ និង/ឬ ទិញ-លក់ មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ មូលបត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

### ៣.៥.២. ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល

ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល គឺចំពោះក្រុមហ៊ុន និងសហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ គឺក្រុមហ៊ុនទាំងអស់ដែលទទួលបានការអនុញ្ញាតពី គ.ម.ក និងចុះបញ្ជីលក់នៅ ផ.ម.ក នឹងត្រូវទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ។ ក្រុមហ៊ុនត្រូវបានបន្ធូរបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ ភាគរយ ក្នុងរយៈពេលបីឆ្នាំដំបូង ហើយការលើកទឹកចិត្តនេះ នឹងត្រូវផ្តល់ជូនចំពោះការចុះបញ្ជីមុនខែមករា ឆ្នាំ២០២១។ ការលើកទឹកចិត្តពន្ធដារមានរយៈពេល បីឆ្នាំ និងត្រូវគិតចាប់ពី[26]៖

- ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ខែ ដើមឆ្នាំជាប់ពន្ធនោះ បានន័យថា ពីខែមករា ដល់ ខែមិថុនា នៃឆ្នាំជាប់ពន្ធ។
- ដើមឆ្នាំជាប់ពន្ធ បន្ទាប់ពីឆ្នាំជាប់ពន្ធ ដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ខែ ចុងឆ្នាំជាប់ពន្ធនោះ បានន័យថា ពីខែកក្កដា ដល់ខែធ្នូ នៃឆ្នាំជាប់ពន្ធ។
- អំឡុងពេលណាមួយដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បន្ថែមលើសពីនេះទៅទៀត ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ១ ភាគរយ ប្រចាំខែត្រូវបានព្យួរជាបណ្ដោះអាសន្នរយៈពេល ៣ឆ្នាំ[27] គិតចាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ។

[26] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ០១អនក្រ.បក, ០៤ មករា ២០១៩, មាត្រា៤, ទំព័រទី៣

[27] គណៈកម្មការមូលបត្រកម្ពុជា, ២០២០, *ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ*, ទំព័រទី៤

#### ៣.៥.៣. ការលើកទឹកចិត្តពន្ធកាត់ទុក

ចំពោះការលើកទឹកចិត្តពន្ធកាត់ទុក អ្នកវិនិយោគសាធារណៈត្រូវបានទទួលការបន្ថយពន្ធកាត់ទុក ៥០ ភាគរយ លើការប្រាក់ និងភាគលាភ ដែលបានមកពីការកាន់កាប់ និងការទិញ និងលក់មូលបត្រកម្មសិទ្ធិ សម្រាប់រយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៩ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១។[28]

### ៣.៦. តួអង្គសំខាន់ៗដែលចូលរួមក្នុងនីតិវិធីនៃការធ្វើ IPO

តួអង្គសំខាន់ៗដែលចូលរួម ក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង មានដូចជា និយ័តករមូលបត្រ (គណៈកម្មការមូលបត្រកម្ពុជា SECC), ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX), ក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter), ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ (Issuers), និងវិនិយោគិន សាធារណៈ (Investors)។ ក្នុងនោះដែរ ក៏មានតួអង្គដទៃផ្សេងច្រើនទៀតដូចជា ក្រុមហ៊ុនជួញដូរមូលបត្រ (Dealer), ក្រុមហ៊ុនជើងសារមូលបត្រ (Broker), ក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគ (Advisory Company) ជាដើមដែលចូលរួមក្នុងនីតិវិធីនៃការធ្វើ IPO នេះដែរ។ ដោយសារតែដំណើរការ និងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូងមានច្រើនដំហាន ទម្រាំតែបានបញ្ចប់ ដូចនេះទើបត្រូវមានការចូលរួមពីសំណាក់តួអង្គសំខាន់ៗដែលខ្វះមិនបាន។

#### ៣.៦.១. និយ័តករមូលបត្រ

និយ័តករមូលបត្រ គឺជានីតិបុគ្គលដែលបង្កើតឡើង ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការមូលបត្រ។ និយ័តករមូលបត្រនៅប្រទេសកម្ពុជា គឺគណៈកម្មការមូលបត្រកម្ពុជា ដែលមានតួនាទីសំខាន់ណាស់ ក្នុងការធ្វើការគ្រប់គ្រងចាត់ចែង នៅក្នុងនីតិវិធីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង។

#### ៣.៦.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺជាទីផ្សារមូលបត្រតែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលគេស្គាល់ថាជាកន្លែងសម្រាប់ជួញដូរ ទិញលក់មូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬស្នើការទិញលក់មូលបត្រ ហើយក៏ជាកន្លែងត្រួតពិនិត្យមូលបត្រខាងអ្នកលក់ និងសាច់ប្រាក់ខាងអ្នកទិញ ដើម្បីបង្ការហានិភ័យផ្សេងៗដែលអាចកើតមាន។ ម្យ៉ាងវិញទៀត ផ្សារមូលបត្រកម្ពុជា ក៏ជាកន្លែងសម្រាប់រក្សាទុកមូលបត្រ

[28] ប្រកាសស្តីពីការណែនាំអនុវត្តការលើកទឹកចិត្តពន្ធកាត់ទុកដល់អ្នកវិនិយោគមូលបត្រ, លេខ៤៧១សហវ.ប្រក, ០៥ ឧសភា ២០២០, ប្រការ ៤

និងធ្វើការផ្លាស់ប្តូរកម្មសិទ្ធិករ តម្កល់មូលបត្រ និងដកចេញមូលបត្រ។ ទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជាមានឈ្មោះថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange)។

### ៣.៦.៣. ក្រុមហ៊ុនធានាទិញមូលបត្រ

មានតែបុគ្គលដែលទទួលអាជ្ញាប័ណ្ណពីអគ្គនាយកនៃ គ.ម.ក ទើបអាចជាភ្នាក់ងារ ឬតាំងខ្លួនជាភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រប្រតិស្រុតដើម្បីធ្វើអាជីវកម្មមូលបត្របាន។[29]

ក្រុមហ៊ុនធានាទិញមូលបត្រ ឬអាជីវកម្មធានាទិញមូលបត្ររួមមាន៖[30]

- ក្រុមហ៊ុនធានាទិញមូលបត្រផ្តល់ប្រឹក្សាសំខាន់ លើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដូចជាការដាក់តម្លៃមូលបត្រ (Pricing) ការកំណត់ទំហំទឹកប្រាក់ (Issue Amount) និងចំនួនមូលបត្រនៃសំណើបោះផ្សាយលក់មូលបត្រ និងការកំណត់ពេលវេលានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈជាដើម។
- ក្រុមហ៊ុនធានាទិញមូលបត្រ ធានាទិញមូលបត្រទាំងអស់ ឬមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រក្នុងគោលដៅចែកចាយ ឬលក់បន្ត។
- ក្រុមហ៊ុនធានាទិញមូលបត្រ គឺទិញមូលបត្រដែលលក់មិនអស់ ឬតាមការព្រមព្រៀងនៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។
- ក្រុមហ៊ុនធានាទិញមូលបត្រ ជួយរៀបចំ ត្រួតពិនិត្យលើការបំពេញកាតព្វកិច្ចតាមច្បាប់ និងបញ្ជាក់លើឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសំណើលក់មូលបត្រជាសាធារណៈ ឬសំណើលក់មូលបត្រជាឯកជន និងការចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ អោយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ឬចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

➢ ក្រុមហ៊ុនធានាទិញមូលបត្រនៅកម្ពុជា ដែលទទួលបានអាជ្ញាប័ណ្ណពី គ.ម.ក មានដូចជា៖[31]

- យាន់តា ស៊ីឃ្យួរីធី (ខេមបូឌា) ភីអិលស៊ី (Yuanta Securities (Cambodia) Plc.)
- អ អេច ប៊ី ស៊ីឃ្យួរីធី (ខេមបូឌា) ភីអិលស៊ី (RHB Securities (Cambodia) Plc.)
- កាណា ស៊ីឃ្យួរីធី អិលធីឌី (Cana Securities Ltd.)

---

[29] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ០៧ កញ្ញា ២០០៧, មាត្រា៣១

[30] ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ, លេខ០០១/១៨គ.ម.ក/ប្រ.ក, ២០ មីនា ២០១៨, ប្រការ៥

[31] http://www.csx.com.kh/kh/member/members.jsp?MNCD=10511 គេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា (២០២០), សមាជិក

- កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី (Campu Securities Plc.)
- អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី (SBI Royal Securities Plc.)
- ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (Phnom Penh Securities Plc.)

### ៣.៦.៤. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ គឺជាក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណពី គ.ម.ក ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្នុងវត្ថុបំណងដើម្បីកៀរគរមូលធននានាដែលមាននៅក្នុងទីផ្សារ។ ក្រុមហ៊ុនបោះផ្សាយទទួលភារកិច្ចលើដំណើរការទាំងមូល ជាមួយនឹងក្រុមហ៊ុនធានាទិញមូលបត្រក្នុងដំណើរការនៃការចុះបញ្ជី។[32]

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ គឺជាអង្គភាពដែលបោះផ្សាយលក់មូលបត្រដែលមានតម្លៃតំណាងអោយអត្រាភាគរយនៃភាគហ៊ុននៅក្នុងអង្គភាពនោះ ឬជាការសន្យាមួយថានឹងបង់ភាគលាភ។ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ អាចជាស្ថាប័នសាធារណៈ ឬក្រុមហ៊ុនឯកជនដែលស្វែងរកទុននៅលើទីផ្សារមូលបត្រតាមរយៈការលក់ភាគហ៊ុនរបស់ខ្លួន។[33]

មកដល់បច្ចុប្បន្នគិតត្រឹមខែឧសភា ឆ្នាំ២០២០ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ដែលទទួលបានអាជ្ញាប័ណ្ណពី គ.ម.ក គឺមានចំនួន ៦ ក្រុមហ៊ុន មានដូចជា៖[34]

- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ចុះបញ្ជីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២)
- ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (ចុះបញ្ជីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤)
- កំពង់ផែស្វយ័តភ្នំពេញ (ចុះបញ្ជីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥)
- ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) (ចុះបញ្ជីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦)
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) (ចុះបញ្ជីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧)
- ធនាគារ អេស៊ីលីដា ភីអិលស៊ី (ចុះបញ្ជីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០)

[32] ថៃ សង្វារៀម,២០១៩, *ទីផ្សារមូលបត្រកម្ពុជា*

[33] បៀន សាំង,២០១១, *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ*,ទំព័រ ១៥-១៦

[34] http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 គេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា (២០២០),បញ្ជីឈ្មោះក្រុមហ៊ុន

### ៣.៦.៥. វិនិយោគិនសាធារណៈ

វិនិយោគិនសាធារណៈ គឺជាអ្នកទិញ និងអ្នកលក់មូលបត្រដែលស្វែងរកប្រាក់ចំណេញទៅលើការវិនិយោគរបស់ខ្លួន។[35] វិនិយោគិន គឺជាអ្នកបែងចែកទុនរបស់ខ្លួន ដោយរំពឹងថានឹងទទួលបានចំណូលហិរញ្ញវត្ថុនាថ្ងៃអនាគត។ នៅក្នុងវិស័យមូលបត្រ វិនិយោគិនសំដៅដល់បុគ្គល ឬសាធារណជន ដែលបានទិញ កាន់កាប់ និងជួញដូរមូលបត្រ ដើម្បីទទួលបានប្រាក់ចំណេញជាភាគលាភ និងការចំណេញមូលធន ឬការប្រាក់។

វិនិយោគិននៅលើទីផ្សារមូលបត្រ ចែកចេញជា ពីរប្រភេទគឺ៖

- វិនិយោគិនជាបុគ្គល (Individual Investors)
- វិនិយោគិនជាស្ថាប័ន (Institutional Investors)។

## ៣.៧. លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

ការពិនិត្យលទ្ធភាពចុះបញ្ជីលក់មូលបត្រ គឺបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវឆ្លងកាត់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងមានលទ្ធភាពអាចបំពេញលក្ខខណ្ឌនៃការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ជ.ម.ក។

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោមមក ជ.ម.ក៖[36]

១. ព័ត៌មានទូទៅ៖

- ឈ្មោះរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រជាភាសាខ្មែរ និងជាអក្សរឡាតាំង
- អាសយដ្ឋានរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ
- កាលបរិច្ឆេទបង្កើតបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ
- កម្មវត្ថុអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ

២. ព័ត៌មានអំពីបុគ្គលតំណាងអោយបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ គឺអត្តសញ្ញាណបុគ្គលតំណាងនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

៣. ព័ត៌មានអំពីភាគហ៊ុនិក គឺអត្តសញ្ញាណភាគហ៊ុនិក។

---

[35] បឿន សាំង,២០១១, *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ*,ទំព័រ ១៦

[36] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ ៤

៤. ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមានៈ

- ប្រភេទមូលបត្រកម្មសិទ្ធិទាំងអស់របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ
- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញ
- ការវាយតម្លៃទ្រព្យសកម្ម និងការវាយតម្លៃទ្រព្យសកម្មឡើងវិញ (ប្រសិនបើមាន)។
- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម និងដែលស្របតាមលក្ខខណ្ឌតម្រូវរបស់ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៥. ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមានៈ

- ព័ត៌មានអំពីធុរកិច្ច និងអភិបាលកិច្ច
- ព័ត៌មានអំពីហានិភ័យ

៦. ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់បានមកពីការបោះផ្សាយលក់មូលបត្រ។

៧. ព័ត៌មានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។

## ៣.៨. លក្ខខណ្ឌតម្រូវនៃការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

នៅពេលដែលបុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួន ដោយលក្ខខណ្ឌទាំងនោះ រួមមានដូចខាងក្រោមៈ[37]

- ត្រូវអនុវត្តតាមលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្ម ដែលកំណត់ដោយ គ.ម.ក។[38]
- ត្រូវមានសកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តភាពប្រតិបត្តិការធុរកិច្ច។
- ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុ រយៈពេល ២ឆ្នាំ ចុងក្រោយសម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោល និងរយៈពេល ១ឆ្នាំ ចុងក្រោយសម្រាប់ក្រុមហ៊ុនសក្តានុពល ដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើន ដោយត្រូវធ្វើសវនកម្មសមស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ករណីក្រុមហ៊ុន ដាក់ពាក្យស្នើសុំបោះផ្សាយ នៅក្រោយរយៈពេល ៤៥ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។
- ត្រូវទទួលបានការបញ្ជាក់ជាមុន ពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

[37] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ ៤

[38] ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ, លេខ០០២គ.ម.ក, ១៥ មករា ២០១០

- ត្រូវមានឯកសារផ្តល់ព័ត៌មានដូចមានចែង ក្នុងប្រកាសលេខ ០០៥/១៥ ចេញដោយគណៈកម្មការមូលបត្រកម្ពុជា ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រង់ប្រការលេខ៧។[39]

នៅប្រទេសកម្ពុជា លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបានបែងចែកជា ២ គឺ៖

- លក្ខខណ្ឌបរិមាណ
- លក្ខខណ្ឌគុណភាព។

### ៣.៨.១. លក្ខខណ្ឌបរិមាណ[40]

- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០,០០០,០០០,០០០ សាមសិបពាន់លានរៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក។
- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២,០០០,០០០,០០០ ពីរពាន់លានរៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣,០០០,០០០,០០០ បីពាន់លានរៀល សម្រាប់រយៈពេល ២ ឆ្នាំចុងក្រោយ។
- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី១០ ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយ ផ.ម.ក។
- ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយ ផ.ម.ក។

### ៣.៨.២. លក្ខខណ្ឌគុណភាព

- ត្រូវជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។
- មានសកម្មភាពធុរកិច្ច ត្រូវតែមានស្ថេរភាព និងធានាបានកំណើនក្នុងរយៈពេលវែង។
- មានស្ថេរភាពហិរញ្ញវត្ថុល្អ និងមានមូលធនបង្វិលគ្រប់គ្រាន់។
- មានរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ។

---

[39] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ ៧

[40] ប្រកាសស្តីពីការដាក់អោយអនុវត្តនូវការកែប្រែវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៩/១៨គ.ម.ក/ប្រ.ក, ១៩ ធ្នូ ២០១៨ ប្រការ ៨ ថ្មី

- មាននីតិវិធីក្នុងការដោះស្រាយទំនាស់ផលប្រយោជន៍ របាយការណ៍ហិរញ្ញវត្ថុធ្វើសវនកម្មដោយឯករាជ្យរយៈពេល ៣ឆ្នាំចុងក្រោយ។
- ត្រូវមានកិច្ចសន្យាធានាទិញជាមួយក្រុមហ៊ុនមូលបត្រ។
- ត្រូវទទួលបានការបញ្ជាក់ជាមុនពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ពីភាពអាចចុះបញ្ជីលក់មូលបត្របានភាពអាចជួញដូរមូលបត្រនៃតម្លៃមូលបត្រដែលធ្វើសំណើលក់។
- ត្រូវរៀបចំអោយបានពេញនូវឯកសារផ្តល់ព័ត៌មានដើម្បីទទួលបានការអនុញ្ញាត និងចុះបញ្ជីដោយ គ.ម.ក។

## ៣.៩. នីតិវិធីនៃការធ្វើ IPO

បន្ទាប់ពីពិនិត្យថាក្រុមហ៊ុន អាចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលមានបំណងបោះផ្សាយត្រូវ៖[41]

- ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ គ.ម.ក
- ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ គ.ម.ក
- ដាក់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

### ៣.៩.១. ការដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ គ.ម.ក

ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ទម្រង់កំណត់ដោយ គ.ម.ក នូវពាក្យស្នើសុំចែកចេញជា ១៣ផ្នែកធំៗ។

បុគ្គលដាក់ពាក្យស្នើសុំដែលទទួលបានការអនុញ្ញាត ជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈអាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបានបន្ទាប់ពី៖[42]

- បានរៀបចំលក្ខខណ្ឌនៃសំណើលក់រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។
- បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។
- បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ គ.ម.ក។

បន្ទាប់ពីទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព។ នៅពេលការធ្វើបរិសកម្មត្រូវបានបញ្ចប់ពេញ

[41] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ ៥

[42] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ ៣៣

លេញក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មនោះភ្លាមមក គ.ម.ក។ ការធ្វើបរិវិសកម្ម ត្រូវកំណត់ដូចខាងក្រោម៖[43]

- ២០% នៃសំណើលក់ជាសាធារណៈសរុបត្រូវបានបម្រុងទុកសម្រាប់វិនិយោគសញ្ជាតិខ្មែរ។
- ៨០% ដែលនៅសល់ត្រូវបើកចំហចំពោះវិនិយោគិនសញ្ជាតិខ្មែរ និងវិនិយោគិនបរទេសដែលមិនមែន សញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ គ.ម.ក. អាចធ្វើការ កំណត់នូវការបែងចែកឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជា សាធារណៈ។

ក្រុមហ៊ុនបោះផ្សាយ ភ្នាក់ងារបញ្ជីកាមូលបត្រ ឬក្រុមហ៊ុនមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិ ឬ វិញ្ញាបនបត្រមូលបត្រកម្មសិទ្ធិទៅអោយអ្នកធ្វើបរិវិសកម្មក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីពេលធ្វើបរិវិសកម្ម បានបញ្ចប់។

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងការលក់មូលបត្រកម្មសិទ្ធិជា សាធារណៈក្នុងទម្រង់ដែលកំណត់ដោយ គ.ម.ក។

ក្រុមហ៊ុនបោះផ្សាយ ត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រកម្ពុជាដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ នៅទីផ្សារមូលបត្រកម្ពុជា។

### ៣.៩.២. ការដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ គ.ម.ក

ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ គ.ម.ក មានដូចជា៖[44]

- ព័ត៌មានទូទៅពាក់ព័ន្ធនឹងសំណើបោះផ្សាយ
- ព័ត៌មានស្តីពីកត្តាហានិភ័យ
- ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- ផែនការវិនិយោគ
- ការពិពណ៌នាអំពីធុរកិច្ច
- ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ
- ការពិពណ៌នាអំពីអចលកម្មរូបីរបស់ក្រុមហ៊ុនបោះផ្សាយ

[43] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ ៣៦

[44] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ ៧

- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ
- ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក
- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់
- ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ
- ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់
- សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅអោយអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត
- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក
- ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ
- កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ
- ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់
- សិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់
- ព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម។

### ៣.៩.៣. ការដាក់ឯកសារភ្ជាប់

បុគ្គលដែលស្នើសុំធ្វើសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវភ្ជាប់មកជាមួយនឹងពាក្យស្នើសុំនូវឯកសារដូចខាងក្រោម៖[45]

- ឯកសារផ្តល់ព័ត៌មាន ដែលរៀបចំឡើងដោយអនុលោមតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។
- វិញ្ញាបនបត្របញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិពីទីផ្សារមូលបត្រប្រតិស្រុត។
- លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។
- លិខិតប្រគល់សិទ្ធិដោយមានបញ្ជាក់ពីតួនាទី និងភារកិច្ចជាអភិបាល ឬនាយកប្រតិបត្តិ ក្នុងការបម្រើការងារនៅក្នុងក្រុមហ៊ុនបោះផ្សាយ ដោយមានការចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

[45] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ ២៩

- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗ (ប្រសិនបើមាន)។
- កិច្ចសន្យាដែលត្រូវប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ប្រសិនបើមាន)។
- ផែនការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយសម្រាប់រយៈពេលយ៉ាងតិច មួយឆ្នាំ។
- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។
- កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។
- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។
- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។
- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។
- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។
- កិច្ចព្រមព្រៀងវិនិយោគចម្រុះសំខាន់ៗ (ប្រសិនបើមាន)។
- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជ ឬលិខិតបញ្ជាក់ពីសវនករនូវចំនួនទឹកប្រាក់តម្កល់សម្រាប់ធ្វើជាមូលធន។
- របាយការណ៍អនុសាសន៍ ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់សវនករឯករាជ្យ ដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ គ.ម.ក។
- របាយការណ៍បញ្ជាក់ ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនគណនេយ្យជំនាញដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ គ.ម.ក។
- របាយការណ៍បញ្ជាក់ ពីការបំពេញកាតព្វកិច្ចតាមច្បាប់ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ គ.ម.ក។
- បញ្ជីរាយនាមអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនដែលមានលក្ខណៈបច្ចុប្បន្នភាពដោយមកជាមួយប្រវត្តិរូបសង្ខេបរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដោយបញ្ជាក់ពីរយៈពេលបំពេញការងារ និងបទពិសោធន៍ការងារ។
- លិខិតផ្ទេរសិទ្ធិជូនបុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន។

- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លង របស់បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន។
- ប្រវត្តិរូបសង្ខេបរបស់បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន ដោយបញ្ជាក់ពីរយៈពេលបំពេញការងារ និងបទពិសោធន៍ការងារ។
- បញ្ជីរាយនាម និងអត្តសញ្ញាណរបស់ភាគហ៊ុនិកដែលមានលក្ខណៈបច្ចុប្បន្នភាព។
- ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។
- ឯកសារភ្ជាប់ផ្សេងៗទៀត តាមការស្នើសុំរបស់អគ្គនាយកនៃ គ.ម.ក។

## ៣.១០. យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

យោងតាម គោលការណ៍ណែនាំ លេខ ០០១ គ.ម.ក/គ.ណ.ន ចេញដោយ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១១ ស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលគោលការណ៍ក្នុងគោលការណ៍ណែនាំនោះរួមមានដូចខាងក្រោម៖[46]

### ៣.១០.១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក គ.ម.ក ដែលលិខិតមានខ្លឹមសារ ៣ ចំណុចដូចខាងក្រោម៖

1. គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)
2. គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)
3. ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញមេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

### ៣.១០.២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ

[46] គណៈកម្មការមូលបត្រកម្ពុជា,២០១១,*គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង*

ជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពី គ.ម.ក។

### ៣.១០.៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការតែងតាំង បុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈស្របតាមបទបញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញមេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញមេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

### ៣.១០.៤. ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះ ត្រូវធ្វើដោយ ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញមេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ។

### ៣.១០.៥. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពិក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

### ៣.១០.៦. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងទទួលបានការអនុញ្ញាតជាគោលការណ៍សំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពី ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះ

ផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក។ គ.ម.ក ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេស ឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយ។

**៣.១០.៧. ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង**

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍ លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**៣.១០.៨. ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងនឹងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើទីផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

**៣.១០.៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់និងការទទួលបានការអនុញ្ញាតនិងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងនឹងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជារួចដាក់ជូន គ.ម.ក ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**៣.១០.១០. ការធ្វើបរិវិសកម្មមូលបត្រ**

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូក៣ និងជំពូក៤ នៃប្រកាស ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

### ៣.១០.១១. ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្លាមជូន គ.ម.ក។

### ៣.១០.១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិទៅឲ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ៣.១១. ករណីសិក្សារបស់ធនាគារអេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាធនាគារពាណិជ្ជធំជាងគេនៅប្រទេសកម្ពុជា ក្លាយជាធនាគារពាណិជ្ជទី១ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ជាផ្លូវការនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។[47] ក្នុងនាមជាធនាគារពាណិជ្ជទីមួយ ដែលនឹងត្រូវចុះបញ្ជីក្នុង ផ.ម.ក. ធនាគារ អេស៊ីលីដា ភីអិលស៊ី នឹងក្លាយជាធនាគារគំរូមួយ សម្រាប់ធនាគារផ្សេងៗទៀត នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ក្នុងការប្រើប្រាស់ទីផ្សារមូលធនកម្ពុជា ដើម្បីប្រមូលទុន។[48]

### ៣.១១.១. ទស្សនៈវិស័យ

ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារពាណិជ្ជនាំមុខក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុល្អបំផុត ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍។[49]

### ៣.១១.២. បេសកកម្ម

បេសកកម្មរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺផ្តល់ជូនសហគ្រិនខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងសាធារណជន នូវមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់

[47] https://www.acledabank.com.kh/kh/khm/md_ln20200521 គេហទំព័ររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី (២០២០), ព័ត៌មានថ្មីៗ

[48] ប្រសាសន៍របស់ បណ្ឌិត អ៊ិន ចាន់នី, ស្រង់មកពីគេហទំព័រ: https://www.acledabank.com.kh/kh/khm/md_ln20200226

[49] https://www.acledabank.com.kh/kh/khm/ff_vision_mission គេហទំព័ររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី (២០២០), ទស្សនៈ

ដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយកាន់តែប្រសើរឡើង ដោយអនុវត្តឱ្យបាននូវនិរន្តរភាព និងបង្កើននូវអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនិយោជិត ព្រមទាំងសហគមន៍ទាំងអស់។ ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌វិជ្ជាជីវៈ សង្គម ច្បាប់ និង បរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត។[50]

### ៣.១១.៣. ព័ត៌មានទូទៅទាក់ទងនឹងមូលបត្រកម្មសិទ្ធិ

ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាអ្នកផ្តល់ជូនសហគ្រិនខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងសាធារណជននូវមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឲ្យមានប្រសិទ្ធិភាពខ្ពស់ និងបង្កើននូវអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនយោជិត ព្រមទាំងសហគមន៍ទាំងអស់វិញ បានបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងរបស់ខ្លួនដោយមានតម្លៃចារឹក ៤,០០០រៀល ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ និងថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិមានតម្លៃ ១៦,២០០រៀល។ ធនាគារ អេស៊ីលីដា អនុវត្តបានយ៉ាងត្រឹមត្រូវទៅតាមគោលការណ៍ និងបទបញ្ញត្តិក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងដែលតម្រូវដោយ គ.ម.ក និងបានបញ្ចប់នូវការធ្វើបរិវិសកម្មមូលបត្ររបស់ខ្លួននៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០។ តាមរយៈការបោះផ្សាយមូលបត្រជាសាធារណៈនេះ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានគម្រោងប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការលក់មូលបត្រនេះសម្រាប់គោលបំណងសាជីវកម្មទូទៅ ពោលគឺដើម្បីបំពេញតម្រូវការទូទៅនៃទុនបង្វិល ពង្រីកអាជីវកម្មថ្មីជាដើម។ ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នឹងត្រូវបានចាត់ទុកថាជា "ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជូនប្រជាជន" ដែលលើកទឹកចិត្តដល់វិនិយោគិនរូបវន្តបុគ្គល និងសាធារណជនទូទៅអោយចូលរួមក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនេះ ទៅតាមសមត្ថភាពហិរញ្ញវត្ថុរបស់ខ្លួន។ "ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈជូនប្រជាពលរដ្ឋ" របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាការចែករំលែកផលដែលបានមកពីវិបុលភាពផ្នែកហិរញ្ញវត្ថុជាមួយនឹងវិនិយោគិនរូបវន្តបុគ្គល និង ក្លាយជាធនាគារដែលទទួលបាននូវទំនុកចិត្តពីសាធារណជនបន្ថែមទៀត។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងភាគហ៊ុនិករបស់ធនាគារ បានសម្រេចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីចំនួន ២% ដែលស្មើនឹង ៨.៧៥១.៣៩១ ភាគហ៊ុន និងមូលបត្រកម្មសិទ្ធិបច្ចុប្បន្នរហូតដល់ ៣%

---

[50] https://www.acledabank.com.kh/kh/khm/ff_vision_mission គេហទំព័ររបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី (២០២០), បេសកកម្ម

ដែលស្មើនឹង ១៣.១២៧.០៨៦ ភាគហ៊ុន ដល់សាធារណជនផ្អែកតាមលទ្ធផលនៃប៊ុកបៀលឌីង និងបរិវិសកម្ម ដែលមានតម្លៃចារឹក ៤,០០០ រៀលក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។[51]

ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី រួមមានដូចជា៖[52]

- ក្រុមហ៊ុនធានាទិញមូលបត្រ មានឈ្មោះថា ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី ដែលមានអាសយដ្ឋាន អាគារ Emerald ជាន់ទី៤ លេខ ៦៤ (កែងផ្លូវ ១៧៨) មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលមានលេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ០០០១៤៥៥២ និងលេខអាជ្ញាបណ្ណអាជីវកម្ម ០០៧ គ.ម.ក./ក.ត។ សម្រាប់ការបោះផ្សាយ គឺមិនមានការធានាទិញមូលបត្រពីក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី ឬបុគ្គលណាមួយឡើយ។ ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី គឺជាទីប្រឹក្សាហិរញ្ញវត្ថុតែមួយគត់ នៅក្នុងសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនេះ។ ក្រុមហ៊ុន យាន់តា និងធនាគារ បានចុះកិច្ចព្រមព្រៀងដោយ អនុញ្ញាតអោយ ក្រុមហ៊ុន យាន់តា ខិតខំអស់ពីលទ្ធភាពក្នុងការលក់មូលបត្រកម្មសិទ្ធិទៅសាធារណជន។
- ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ មានឈ្មោះថា ការិយាល័យមេធាវី សិទ្ធិស័ក្តិ ដែលមានមេធាវីតំណាងឈ្មោះ លោក សុន សុខកេង, លោក តាន់ ម៉េងស្រួយ និងលោកស្រី ប៉េង ម៉ាណែត ដែលមានអាសយដ្ឋាន អាគារ Millennium លេខ ៦៨ ជាន់ទី៣ ផ្លូវ ៥៧ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលមានលេខវិញ្ញាបនបត្រចុះបញ្ជីចេញដោយគណៈមេធាវីកម្ពុជា L00៧៨/១៩ និងលេខចុះបញ្ជីទទួលស្គាល់ដោយ គ.ម.ក ០០៣ គ.ម.ក. កា.ម។
- ក្រុមហ៊ុនផ្តល់សេវាសវនកម្ម មានឈ្មោះថា ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា ដែលមានសវនករឈ្មោះ លោក ង៉ៃ ហ៊ុយ ដែលមានប្រអប់សំបុត្រ ២៣៥២ អាសយដ្ឋាន អាគារ Delano ជាន់ទី៤ លេខ ១៤៤ ផ្លូវ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលមានលេខចុះបញ្ជីជាសមាជិក វ.គ.ស.ក I-0000៥ និងលេខចុះបញ្ជីទទួលស្គាល់ដោយ គ.ម.ក ០០៨ គ.ម.ក/ ស.ឯ។

### ៣.១១.៤. លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

លទ្ធផលនៃការបោះផ្សាយរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី មានដូចខាងក្រោម៖[53]

[51] ធនាគារ អេស៊ីលីដា ភីអិលស៊ី,២០២០,*ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*,ទំព័រ១៨

[52] ធនាគារ អេស៊ីលីដា ភីអិលស៊ី,២០២០,*ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*,ទំព័រ១៥-១៦

- ឈ្មោះក្រុមហ៊ុន៖ ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ប្រភេទភាគហ៊ុន៖ ភាគហ៊ុនមានសិទ្ធិបោះឆ្នោត
- ចំនួនមូលបត្រកម្មសិទ្ធិថ្មីដែលធ្វើសំណើលក់៖ ៨,៧៥១,៣៩១ ភាគហ៊ុន
- កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង៖ ថ្ងៃទី០៣ ដល់ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០
- ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង៖ ១៥,០០០ រៀល ដល់ ១៧,៤០០ រៀល
- កាលបរិច្ឆេទធ្វើបរិវិសកម្ម៖ ថ្ងៃទី២៤ ខែមីនា ដល់ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០
- តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង៖ ១៦,២០០ រៀល
- ក្រុមហ៊ុនធានាទិញមូលបត្រ៖ យាន់តា ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី

### ៣.១១.៥. គោលនយោបាយភាគលាភរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្តេជ្ញាបែងចែកភាគលាភអោយបានត្រឹមត្រូវ និងមានប្រសិទ្ធភាពដល់ភាគហ៊ុនិកដោយដាក់គោលនយោបាយបែងចែកភាគលាភដើម្បីបែងចែកភាគលាភដល់ភាគហ៊ុនិក ហើយធ្វើអោយមានកំណើនដើមទុនផងដែរ។[54]

ធនាគារកំណត់ប្រភេទភាគលាភដូចជា៖

- ភាគលាភជាសាច់ប្រាក់
- ភាគលាភជាភាគហ៊ុន
- ទម្រង់ផ្សេងទៀត ដលកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិកដែលត្រូវបានអនុញ្ញាតដោយច្បាប់ បទបញ្ញត្តិ និងការអនុវត្តអន្តរជាតិ។

### ៣.១១.៦. លក្ខខណ្ឌនៃការបែងចែកភាគលាភ

ធនាគារ អេស៊ីលីដា ភីអិលស៊ី នឹងធ្វើការបែងចែកភាគលាភជូន ភាគហ៊ុនិកយ៉ាងតិចមួយដងក្នុងមួយឆ្នាំ។ ភាគលាភនឹងបែងចែកនៅពេលមានចំណេញពីប្រតិបត្តិការរបស់ធនាគារ និងត្រូវបានទទួលស្គាល់ជាក់ស្តែងដោយសវនករឯករាជ្យ។ ភាគលាភនឹងត្រូវធ្វើការបែងចែក និងស្របតាមផែនការអាជីវកម្ម។ ករណីមានការចាំបាច់ ដើម្បីរក្សាទុកប្រាក់ចំណេញសម្រាប់គោលបំណងវិនិយោគ ឬគោលបំណងណាមួយតាមរយៈការ

[53] http://csx.com.kh/data/ipo/viewPost.do?MNCD=5020&postId=89 គេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា (២០២០), សង្ខេបព័ត៌មានការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង

[54] ធនាគារ អេស៊ីលីដា ភីអិលស៊ី, ២០២០, *ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*, ទំព័រ១៤

ពិភាក្សាយ៉ាងហ្មត់ចត់ជាមួយក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា ភីអិលស៊ី នឹងស្នើសុំការអនុញ្ញាតពី គ.ម.ក និងផ្សព្វផ្សាយជាសាធារណៈ។[55]

### ៣.១១.៧. ចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូង

ចំណាយពាក់ព័ន្ធទៅនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី មានចំនួនប្រហែល ៤ ពាន់លានរៀល ដែលមានបង្ហាញដូចខាងក្រោម៖[56]

រូបភាពទី៦៖ ចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូង

| ចំណាយពាក់ព័ន្ធ | គិតជាដុល្លារអាមេរិក | គិតជាប្រាក់រៀល |
|---|---|---|
| ចំណាយពាក់ព័ន្ធនឹងការធានាទិញមូលបត្រ | ៥៦៧,០៩០ ដុល្លារអាមេរិក | ២,២៦៨,៣៦០,០០០ រៀល |
| ចំណាយពាក់ព័ន្ធនឹងទីប្រឹក្សាច្បាប់ | ៦១,៤៤០ ដុល្លារអាមេរិក | ២៤៥,៧៦០,០០០ រៀល |
| ចំណាយទៅលើក្រុមហ៊ុនផ្តល់សេវាសវនកម្ម | ៩៣,១៥០ ដុល្លារអាមេរិក | ៣៧២,៦០០,០០០ រៀល |
| ចំណាយទៅលើការបោះពុម្ព និងផ្សព្វផ្សាយ | ៦៨,៨៦៨ ដុល្លារអាមេរិក | ២៧៥,៤៧២,០០០ រៀល |
| ចំណាយទៅលើការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ៣,០០០ ដុល្លារអាមេរិក | ១២,០០០,០០០ រៀល |
| ចំណាយទៅលើការពិនិត្យលទ្ធភាពចុះបញ្ជី | ១,០០០ ដុល្លារអាមេរិក | ៤,០០០,០០០ រៀល |
| ចំណាយថ្លៃចុះបញ្ជីមាន | ១៨៩,៣១៦ ដុល្លារអាមេរិក | ៧៥៧,២៦៤,០០០ រៀល |
| ចំណាយផ្សេងៗទៀត | ១៦,១៣៦ ដុល្លារអាមេរិក | ៦៤៥,៤៤០,០០០ រៀល |

ដោយការទូទាត់ជាក់ស្តែងជាប្រាក់រៀល។ សន្មត់ថាអត្រាប្តូរប្រាក់ស្មើ ៤,០០០ រៀល/ដុល្លារអាមេរិក។

### ៣.១១.៨. សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូង

ធនាគារ អេស៊ីលីដា ភីអិលស៊ីបានបោះផ្សាយមូលបត្រកម្មសិទ្ធិថ្មីចំនួន ៨,៧៥១,៣៩១ ភាគហ៊ុន (ភាគហ៊ុនមានសិទ្ធិបោះឆ្នោត) ដែលមានតម្លៃស្មើនឹង ១៦,២០០ រៀល ហើយធនាគារ នឹងទទួលបានសាច់ប្រាក់សុទ្ធពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈចំនួនប្រហែល ១៣៧,៨ ពាន់លានរៀល។

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានបំណងនឹងប្រើប្រាស់សាច់ប្រាក់សុទ្ធដែលទទួលបានពីការបោះផ្សាយលក់នេះ សម្រាប់គោលបំណងសាជីវកម្មទូទៅ។[57]

[55] ធនាគារ អេស៊ីលីដា ភីអិលស៊ី,២០២០, *ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*, ទំព័រ២៦

[56] ធនាគារ អេស៊ីលីដា ភីអិលស៊ី,២០២០, *ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*, ទំព័រ១៦

## ៣.១២. ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានសិក្សាស្រាវជ្រាវរួចមក ក្រុមយើងខ្ញុំបានឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនពាក់ព័ន្ធទៅនឹងប្រធានបទដែលបានស្រាវជ្រាវ គឺនីតិវិធីនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនៅប្រទេសកម្ពុជា។ ចំណុចខ្លាំង និងចំណុចខ្សោយនោះរួមមានដូចខាងក្រោម។

### ៣.១២.១. ចំណុចខ្លាំង

- គ.ម.ក យកចិត្តទុកដាក់ចំពោះក្រុមហ៊ុនដែលមានបំណងបោះផ្សាយមូលបត្រកម្មសិទ្ធិ ដោយក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយត្រូវគោរពតាមនីតិវិធីដែល គ.ម.ក បានកំណត់។ យ៉ាងណាមិញចំពោះក្រុមហ៊ុនដែលបោះផ្សាយលក់បានសុទ្ធតែជាក្រុមហ៊ុនដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលអាចចូលរួមបាននៅក្នុងវិស័យមូលបត្រ។
- ក្រុមហ៊ុនមូលបត្រដែលអាចចូលរួមបាននៅក្នុងវិស័យមូលបត្រសុទ្ធតែជាក្រុមហ៊ុនដែលទទួលស្គាល់និងទទួលបានអាជ្ញាបណ្ណពី គ.ម.ក។
- គ.ម.ក ក៏បានចេញជា ច្បាប់ និងបទប្បញ្ញត្តិ អនុក្រឹត្យ ប្រកាសនានាដែលទាក់ទងនឹងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនេះច្រើនផងដែរ ដែលអាចជួយសម្រួលដល់ក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយលក់នូវមូលបត្រកម្មសិទ្ធិ។
- រាជរដ្ឋាភិបាលក៏បានចូលរួមយ៉ាងសំខាន់នូវក្នុងវិស័យមូលបត្រមួយនេះ ដោយមានការលើកទឹកចិត្តពន្ធដារជាដើម ដើម្បីជម្រុញអោយមានអ្នកចូលរួមក្នុងការវិនិយោគលើវិស័យមូលបត្រនេះច្រើនឡើង។
- គ.ម.ក ផ្តល់ការគាំទ្រ និងចូលរួមដែលជាខ្នងបង្អែកមួយលើការអនុវត្តនីតិវិធីរបស់ក្រុមហ៊ុនបោះផ្សាយតាំងពីដើមរហូតដល់បានសម្រេចចប់សព្វគ្រប់ ជាពិសេសជួយសម្រួលដល់ក្រុមហ៊ុនបោះផ្សាយដែលមានបទពិសោធន៍ថ្មីពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូងនៅប្រទេសកម្ពុជា។
- ការធ្វើប៊ុកបៀលឌីង គឺមានការបើកទូលាយចំពោះសាធារណជនទាំងអស់ ដោយពួកគេអាចចូលរួមទិញ ក៏ជាចំណែកមួយនៃការលើកតម្កើងនូវវិស័យមូលបត្រផងដែរ មិនត្រឹមតែប៉ុណ្ណោះសាធារណជនក៏អាចមានចំណេះដឹង និងការស្វែងយល់មួយកម្រិតទៀតអំពីវិស័យមូលបត្រនេះ។

---

[57] ធនាគារ អេស៊ីលីដា ភីអិលស៊ី,២០២០, *ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*, ទំព័រ២២

### ៣.១២.២. ចំណុចខ្សោយ

- ថ្វីត្បិតតែនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមាននីតិវិធី និងយន្តការច្បាស់លាស់ ប៉ុន្តែនីតិវិធីមានលក្ខណស្មុគស្មាញច្រើន និងប្រើពេលយូរក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាន និងត្រៀមខ្លួនអោយត្រូវតាមលក្ខខណ្ឌដែល គ.ម.ក បានកំណត់។
- ទីផ្សារមូលបត្រនៅកម្ពុជា ពុំទាន់សូវមានភាពទូលំទូលាយនៅឡើយទេ សាធារណជនភាគច្រើនពុំសូវមានចំណេះជំនាញខាងផ្នែកវិស័យមូលបត្រ និងមានការយល់ដឹងច្រើននៅឡើយ ដែលជាកត្តាមួយធ្វើអោយចំនួននូវក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនៅតិចនៅឡើយ។
- ក្រុមហ៊ុនបោះផ្សាយ ក៏ដូចជាវិនិយោគិនមូលបត្រ ពុំទាន់មានជំនឿជាក់យ៉ាងពេញទំហឹងទៅលើក្រុមហ៊ុនផ្សារមូលបត្រកម្ពុជានៅឡើយទេ។
- នៅលើទីផ្សារមូលបត្រកម្ពុជា មិនទាន់ឃើញមានការជួញដូរមូលបត្រច្រើនប្រភេទ ឬច្រើនបែបនៅឡើយ ជាហេតុនាំអោយមិនសូវទាក់ទាញវិនិយោគិន ក៏ដូចជាក្រុមហ៊ុនមួយចំនួនដែលមានបំណងចង់បង្កើនដើមទុន ឬមូលធនតាមរយៈការបោះផ្សាយលក់មូលបត្រ។

# សេចក្ដីសន្និដ្ឋាន
# និងការផ្ដល់អនុសាសន៍

# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

## ១. សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមក ក្រុមយើងខ្ញុំទទួលបាននូវចំណេះដឹងយ៉ាងច្រើនទាក់ទងនឹងវិស័យមូលបត្រ ជាពិសេសការដាក់បង្ហាញព័ត៌មានសាជីវកម្មដែល គ.ម.ក ប្រើប្រាស់ និងនីតិវិធីនៃការធ្វើ IPO មានលក្ខណៈល្អប្រសើរ និងច្បាស់លាស់ល្អ។ ម៉្យាងទៀត ចំពោះព័ត៌មានដែល គ.ម.ក តម្រូវឲ្យក្រុមហ៊ុនបោះផ្សាយទាំងឡាយផ្ដល់ជូនមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់សម្រាប់វិនិយោគិន និងសាធារណជនក្នុងការពិចារណា និងធ្វើការសម្រេចចិត្តបានត្រឹមត្រូវមុនពេលធ្វើការជួញដូរមូលបត្រ។ សរុបមកវិញ យើងសង្កេតឃើញថា ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនៅកម្ពុជា គឺជាយន្តការមួយដែលឆ្លងកាត់នូវដំណាក់កាលច្រើន និងមានភាពស្មុគស្មាញផងដែរ ព្រោះ គ.ម.ក បានបង្កើតជាបទប្បញ្ញត្តិ និងច្បាប់មួយចំនួនដើម្បីធ្វើឲ្យការបង្ហាញព័ត៌មានសាជីវកម្ម កាន់តែមានតម្លាភាព និងសុក្រឹត្យភាព ហើយធ្វើឲ្យវិនិយោគិនកាន់តែទុកចិត្តចំពោះការជួញដូរក្នុងវិស័យមូលបត្រ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវគោរពទៅតាមបទបញ្ញត្តិនៃការបោះផ្សាយដែលតម្រូវដោយគណៈកម្មការមូលបត្រកម្ពុជា ដែលជាស្ថាប័នមានមុខងារក្នុងការគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្ដាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឲ្យមានការជួញដូរមូលបត្រប្រកបដោយភាពត្រឹមត្រូវនៅកម្ពុជា។ ដើម្បីការពារផលប្រយោជន៍ដល់វិនិយោគិន និងសាធារណជនដែលជួញដូរក្នុងវិស័យមូលបត្រ គ.ម.ក ក៏បានបង្កើតជាបទប្បញ្ញត្តិ និងច្បាប់ ស្ដីពីការផ្ដន្ទាទោសចំពោះបុគ្គលដែលផ្ដល់ព័ត៌មានមិនត្រឹមត្រូវ ក្លែងបន្លំ និងបោកប្រាស់ជាដើម។ ជាងនេះទៅទៀត បន្ទាប់ពីបានបញ្ចប់ការស្រាវជ្រាវនេះ យើងខ្ញុំយល់ឃើញថា ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងប្រៀបបានដូចជាអាវុធមុខពីរ ដែលផ្ដល់ទាំងគុណសម្បត្តិ និងគុណវិបត្តិដល់ក្រុមហ៊ុនបោះផ្សាយ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏ការបោះផ្សាយលក់មូលបត្របានជួយជំរុញដល់ផ្នែកសេដ្ឋកិច្ចជាតិឲ្យមានភាពរីកចម្រើនដែរ ព្រោះវាជួយសម្រួលនូវលំហូរមូលធនពីបុគ្គលដែលមានមូលធនលើសទៅបុគ្គល ឬក្រុមហ៊ុនដែលត្រូវការមូលធនក្នុងកិច្ចដំណើរការអាជីវកម្មរបស់ខ្លួន។

## ២. ការផ្ដល់អនុសាសន៍

ដើម្បីឲ្យទីផ្សារមូលបត្រកម្ពុជាមានដំណើរការទៅកាន់តែមានប្រសិទ្ធិភាព និងតម្លាភាព ជាពិសេសពាក់ព័ន្ធនឹងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនៅកម្ពុជា ក្រុមយើងខ្ញុំសូមចូលរួមលើកជាមតិយោបល់មួយចំនួនដូចខាងក្រោម៖

- បង្កើតអោយមានក្រុមហ៊ុនផ្សារមូលបត្របន្ថែមទៀត ដែលមានលក្ខខណ្ឌសមស្របដែលអាចផ្តល់ឱកាសអោយក្រុមហ៊ុនដែលមានទុនល្អម ដែលមានប្រតិបត្តិការអាជីវកម្មល្អ អាចចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជាដើម្បីពង្រីកអាជីវកម្មរបស់ពួកគេ។
- គណៈកម្មការមូលបត្រកម្ពុជា គួរបន្តផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាយល់ដឹងឲ្យបានកាន់តែច្បាស់អំពីវិស័យមូលបត្រនៅកម្ពុជា ដើម្បីជួយជំរុញឲ្យពួកគេចូលរួមឲ្យបានកាន់តែច្រើន។ ជាពិសេស គឺការធ្វើយុទ្ធនាការទៅតាមបណ្តាក្រុមហ៊ុនធំៗ ក្រុមហ៊ុនមូលបត្រ និងសាកលវិទ្យាល័យជាដើម។ ម្យ៉ាងវិញទៀតក៏អាចផ្សព្វផ្សាយទៅតាមប្រព័ន្ធផ្សព្វផ្សាយនានា ពង្រីក និងពង្រឹងស្ថាប័នអប់រំស្តីពីវិស័យមូលបត្រ។
- ជាមួយនឹងមានការជំរុញឲ្យមានកំណើននៃតម្រូវការមូលបត្រ ពីសំណាក់វិនិយោគិននានា គណៈកម្មការមូលបត្រកម្ពុជា ក៏គួរលើកទឹកចិត្តដល់ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រឲ្យចូលរួមសហការដើម្បីឲ្យមានកំណើននៃការផ្គត់ផ្គង់មូលបត្រផងដែរ។
- គណៈកម្មការមូលបត្រកម្ពុជា គួររៀបចំបង្កើនការអនុញ្ញាតលើការបោះផ្សាយលក់មូលបត្របំណុល និងប្រភេទមូលបត្រផ្សេងៗទៀត ដើម្បីបំពេញតាមតម្រូវការខុសៗគ្នារបស់ក្រុមហ៊ុន។

សរុបមក ដើម្បីអោយការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងមានដំណើរការទៅមុខយ៉ាងរលូន ប្រកបដោយភាពជោគជ័យ គឺត្រូវមានការចូលរួមសហការគ្នាពីសំណាក់តួអង្គដ៏សំខាន់ៗទាំងអស់ដែលពាក់ព័ន្ធទៅនឹងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនេះ និងមានការគ្រប់គ្រងល្អទៅលើរាល់ប្រតិបត្តិការនៃដំណើរការនៃការបោះផ្សាយលក់។

# ឯកសារយោង

# ឯកសារយោង


## ច្បាប់ និងបទប្បញ្ញត្តិផ្សេងដែលទាក់ទងនឹងវិស័យមូលបត្រ

១. ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ០៧ កញ្ញា ២០០៧

២. អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ០១អនក្រ.បក, ០៤ មករា ២០១៩

៣. ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ, លេខ០០២ គ.ម.ក, ១៥ មករា ២០១០

៤. ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥

៥. ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥

៦. ប្រកាសស្តីពីការដាក់អោយអនុវត្តនូវការកែប្រែវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៩/១៨គ.ម.ក/ប្រ.ក, ១៩ ធ្នូ ២០១៨

៧. ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មមូលបត្រ, លេខ០០១/១៨គ.ម.ក/ ប្រ.ក, ២០ មីនា ២០១៨

៨. ប្រកាសស្តីពីការណែនាំអនុវត្តការលើកទឹកចិត្តពន្ធកាត់ទុកដល់អ្នកវិនិយោគមូលបត្រ, លេខ៤៧១សហវ.ប្រក, ០៥ ឧសភា ២០២០

៩. គណៈកម្មការមូលបត្រកម្ពុជា, ២០១១, "គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង"

១០. គណៈកម្មការមូលបត្រកម្ពុជា, ២០២០, "ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ"

១១. ឧបសម្ព័ន្ធប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥

## សៀវភៅ និងអត្ថបទផ្សេងៗ និងឯកសាររៀបរៀង

១២. ធនាគារ អេស៊ីលីដា ភីអិលស៊ី, ២០២០, "ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ"

១៣. ថៃ សង្វារៀម, "ទីផ្សារមូលបត្រកម្ពុជា", សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

១៤. បៀន សាំង, ២០១១, "មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ"

១៥. សួន ចំរើន, ២០១៨-២០១៩, "ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១", សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

១៦. ហាស់ វាសនា, ២០០៧, "ផ្សារភាគហ៊ុនគឺជាអ្វី?"

**ឯកសារដកស្រង់ពីគេហទំព័រ**

១៧. ផ្សារមូលបត្រកម្ពុជា (២០២០), ប្រវត្តិ ផ.ម.ក។ ដកស្រង់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ពីគេហទំព័រ: http://csx.com.kh/kh/about/profile.jsp?MNCD=10301

១៨. ផ្សារមូលបត្រកម្ពុជា (២០២០), សំនួរ-ចម្លើយ។ ដកស្រង់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ពីគេហទំព័រ: http://csx.com.kh/news/faq/listPosts.do?MNCD=7060

១៩. គណៈកម្មការមូលបត្រកម្ពុជា (២០២០), សំនួរ-ចម្លើយ។ ដកស្រង់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://www.secc.gov.kh/khmer/faq.php?pn=2

២០. គណៈកម្មការមូលបត្រកម្ពុជា (២០២០), អត្ថន័យរូបសញ្ញា។ ដកស្រង់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://www.secc.gov.kh/khmer/m17.php?pn=1

២១. គណៈកម្មការមូលបត្រកម្ពុជា (២០២០), រូបសញ្ញា គ.ម.ក។ ដកស្រង់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://www.secc.gov.kh/khmer/m17.php?pn=1

២២. គណៈកម្មការមូលបត្រកម្ពុជា (២០២០), ទំនាក់ទំនងមក គ.ម.ក។ ដកស្រង់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://www.secc.gov.kh/khmer/m19.php?pn=1

២៣. គណៈកម្មការមូលបត្រកម្ពុជា (២០២០), មូលហេតុជ្រើសរើសរូបសញ្ញា។ ដកស្រង់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://www.secc.gov.kh/khmer/m17.php?pn=1

២៤. គណៈកម្មការមូលបត្រកម្ពុជា (២០២០), ត្រារបស់ គ.ម.ក។ ដកស្រង់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://www.secc.gov.kh/khmer/m17.php?pn=1

២៥. គណៈកម្មការមូលបត្រកម្ពុជា (២០២០), ចក្ខុវិស័យ។ ដកស្រង់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://www.secc.gov.kh/khmer/m11.php?pn=1

២៦. គណៈកម្មការមូលបត្រកម្ពុជា (២០២០), បេសកកម្ម។ ដកស្រង់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://www.secc.gov.kh/khmer/m11.php?pn=1

២៧. គណៈកម្មការមូលបត្រកម្ពុជា (២០២០), អង្គការចាត់តាំង។ ដកស្រង់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://www.secc.gov.kh/khmer/m14.php?pn=1

២៨. ផ្សារមូលបត្រកម្ពុជា (២០២០), សមាជិក។ ដកស្រង់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://www.csx.com.kh/kh/member/members.jsp?MNCD=10511

២៩. ផ្សារមូលបត្រកម្ពុជា (២០២០), បញ្ជីឈ្មោះក្រុមហ៊ុន។ ដកស្រង់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://csx.com.kh/data/lstcom/listPosts.do?MNCD=50101

៣០. ធនាគារ អេស៊ីលីដា ភីអិលស៊ី (២០២០), ព័ត៌មានថ្មីៗ។ ដកស្រង់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ពីគេហទំព័រ: https://www.acledabank.com.kh/kh/khm/md_ln20200521

៣១. ប្រសាសន៍របស់ បណ្ឌិត អ៊ិន ចាន់នី (២០២០)។ ដកស្រង់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ពីគេហទំព័រ: https://www.acledabank.com.kh/kh/khm/md_ln20200226

៣២. ធនាគារ អេស៊ីលីដា ភីអិលស៊ី (២០២០), ទស្សនៈ។ ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ពីគេហទំព័រ: https://www.acledabank.com.kh/kh/khm/ff_vision_mission

៣៣. ធនាគារ អេស៊ីលីដា ភីអិលស៊ី (២០២០), បេសកកម្ម។ ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ពីគេហទំព័រ: https://www.acledabank.com.kh/kh/khm/ff_vision_mission

៣៤. ផ្សារមូលបត្រកម្ពុជា (២០២០), សង្ខេបព័ត៌មានការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ ដកស្រង់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ពីគេហទំព័រ: http://csx.com.kh/data/ipo/viewPost.do?MNCD=5020&postId=89

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី២៖

# អនុក្រឹត្យស្តីពីការលើកទឹកចិត្ត

# ពន្ធដារក្នុងវិស័យមូលបត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-** គោលបំណង

អនុក្រឹត្យនេះមានគោលបំណងលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-** គោលដៅ

អនុក្រឹត្យនេះមានគោលដៅកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩។

**មាត្រា៣.-** វិសាលភាព

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះ÷

១. ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

២. អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ឬ ទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជន និងអនិវាសនជន។

## ជំពូកទី២
## សកម្មភាព និងលក្ខខណ្ឌនៃការលើកទឹកចិត្តពន្ធដារ

**មាត្រា៤.-** ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារតាមរយៈ **គ.ម.ក.** នៅរាល់មុនការិយបរិច្ឆេទបង់ពន្ធសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណូលត្រូវបង់ក្នុងរយៈពេលនៃការទទួលបានការលើកទឹកចិត្តពន្ធដារ ដូចមានកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា៤ នៃអនុក្រឹត្យនេះ។

ការលើកទឹកចិត្តពន្ធដារមានរយៈពេល ៣ (បី) ឆ្នាំ និងត្រូវគិតចាប់ផ្ដើមពី÷

១- ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើមឆ្នាំជាប់ពន្ធនោះ។

២- ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចុងឆ្នាំជាប់ពន្ធ។

៣- អំឡុងពេលណាមួយដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៥.-** ការអនុគ្រោះបំណុលពន្ធចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវទទួលបានការអនុគ្រោះបំណុលពន្ធដែលរួមបញ្ចូលពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ។ ការអនុគ្រោះបំណុលពន្ធទាំងស្រុងត្រូវអនុវត្តដូចខាងក្រោម÷

១- បំណុលពន្ធចាប់ពីកាលបរិច្ឆេទN-3 ដល់N-10 សម្រាប់ក្រុមហ៊ុន/ សហគ្រាសដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារគោល។

២- បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-2 ដល់ N-10 សម្រាប់សហគ្រាសធុនតូច និងមធ្យមដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារកំណើន។ (ឆ្នាំ N គឺជាឆ្នាំដែលក្រុមហ៊ុន/ សហគ្រាសធ្វើការបោះ-ផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលជាសាធារណៈជាលើកដំបូង។)

ការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនតម្រូវឱ្យមានការធ្វើសវនកម្មពេញលេញជាមុនពីអគ្គនាយកដ្ឋានពន្ធដារនោះទេ។ សម្រាប់ការស្នើសុំបោះផ្សាយ ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ត្រូវផ្តល់ជូន **គ.ម.ក.** នូវវិញ្ញាបនបត្របញ្ជាក់កាតព្វកិច្ចពន្ធ ចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដែលជាលិខិតសម្រាប់បញ្ជាក់ពីការប្រកាស និងបង់ពន្ធជាប្រចាំដោយមិនទាន់រងការធ្វើសវនកម្មពីអគ្គនាយកដ្ឋានពន្ធដារ។

**មាត្រា៦.- ការលើកទឹកចិត្តពន្ធកាត់ទុកដល់អ្នកវិនិយោគមូលបត្រ**

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយ លើការប្រាក់ និង/ ឬ ភាគលាភ ដែលបានមកពីការកាន់កាប់ និង/ ឬ ការទិញ- លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលសម្រាប់រយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ ឬ ភាគលាភ ត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ (ម្ភៃ) នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

**គ.ម.ក.** និងអគ្គនាយកដ្ឋានពន្ធដារ ត្រូវពិនិត្យជាមួយគ្នាលើអត្រាពន្ធកំណត់លើការប្រាក់នៃមូលបត្របំណុលនេះ និងស្នើសុំការពិនិត្យសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៧.- ក្រុមហ៊ុន/ សហគ្រាសដែលមិនត្រូវបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល**

ក្រុមហ៊ុន/ សហគ្រាសមិនត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងច្បាប់ និងបទ-ប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨.- ការបញ្ឈប់ការលើកទឹកចិត្តពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈ **គ.ម.ក.** ដើម្បីបញ្ឈប់ការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងមាត្រា៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា៥ នៃអនុ-ក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត÷

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ និងបង់ប្រាក់ពន្ធ តាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធ និងបង់ប្រាក់ពន្ធតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។ លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ រួមមាន តារាងតុល្យការ គណនីលទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ដោយមិនឱ្យហួសពីរយៈពេល ៣ (បី) ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។
- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ។
- មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ។

ក្នុងករណីក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះ មិនបានអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ **គ.ម.ក.** អាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីបញ្ឈប់ការលើកទឹកចិត្ត ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនត្រូវទទួលបាននូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុន/ សហគ្រាសនោះបានដកខ្លួនចេញពីការចុះបញ្ជីជួញដូរមូលបត្រ ឬត្រូវបានដកពីការចុះបញ្ជីជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៩.-** ការលើកទឹកចិត្តពន្ធដារចំពោះក្រុមហ៊ុន/ សហគ្រាសដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈរួច

ក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** ធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងដែលបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតរួចហើយ តែមិនទាន់ទទួលបាននូវការលើកទឹកចិត្តពន្ធដារនោះ ត្រូវបានផ្តល់ការលើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ។

**មាត្រា១០.-** ការជំនួស

បញ្ញត្តិទាំងឡាយដែលចេញឡើងស្របតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៥ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ នឹងត្រូវបន្តអនុវត្តអនុលោមតាមអនុក្រឹត្យនេះ។

**មាត្រា១១.-** ការអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអគ្គនាយកដ្ឋានពន្ធដារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមករា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ១១ "ដើម្បីអនុវត្ត"
- គ្រប់ក្រសួង-ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣៖

# ប្រកាសស្តីពីការបោះផ្សាយលក់

# មូលបត្រកម្មសិទ្ធិជាសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០០៥/១៥ គ.ម.ក/ប្រ.ក

# ប្រកាស
## ស្តីពី
## ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh,
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh,

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងចែងអំពីបែបបទ យន្តការ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

១-ច្បាប់ សំដៅដល់ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៣-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ÷

ក-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មី ឬលើកដំបូងជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

ខ-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលធ្វើឡើងដោយក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

៤-ក្រុមហ៊ុនសក្ដានុពល សំដៅដល់ក្រុមហ៊ុនដែលមានលទ្ធភាពអាចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចជាសហគ្រាសធុនតូចនិងមធ្យម ក្រុមហ៊ុនដែលទើបបង្កើតថ្មី និងក្រុមហ៊ុនដែលមានកំណើនខ្ពស់ ឬអាចមានកំណើនខ្ពស់។

៥-ក្រុមហ៊ុនហូលឌីង (Holding Company) សំដៅដល់ក្រុមហ៊ុនដែលកាន់កាប់បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ឬក្រុមហ៊ុនសម្ព័ន្ធ ដោយមានភាពជាម្ចាស់កម្មសិទ្ធិដោយកាន់កាប់ភាគហ៊ុនចំនួនច្រើន

ឬចំនួនតិចដែលមានសិទ្ធិបោះឆ្នោតគ្រប់គ្រាន់លើក្រុមហ៊ុនដែលកាន់កាប់។

៦-ភាគហ៊ុនបុរិមា (Preference share) សំដៅដល់ភាគហ៊ុនដែលអ្នកកាន់កាប់គ្មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិជាអាទិភាពក្នុងការទទួលភាគលាភ។

៧-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការកត់ត្រាមូលបត្រដែលបានបោះផ្សាយលក់ជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ។

៨-ភ្នាក់ងារវាយតម្លៃ សំដៅដល់ក្រុមហ៊ុនដែលមានសកម្មភាពធុរកិច្ចក្នុងការវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការផ្ទេរមូលបត្រ។

១០-ភ្នាក់ងារទូទាត់ (Paying Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការទូទាត់ជំនួសឱ្យក្រុមហ៊ុនបោះផ្សាយ។

១១-មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត រួមទាំងនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

១២-សិទ្ធិបរិវត្តន៍ (Conversion Rights) សំដៅដល់សិទ្ធិក្នុងការផ្ទេរពីភាគហ៊ុនបុរិមាទៅជាមូលបត្រកម្មសិទ្ធិធម្មតា។

**ប្រការ ៣.-**

សំណើលក់មូលបត្រកម្មសិទ្ធិ អាចជាសំណើលក់ជាឯកជន ឬសំណើលក់ជាសាធារណៈ។

សំណើលក់មូលបត្រកម្មសិទ្ធិដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូល-បត្រកម្មសិទ្ធិជាឯកជន÷

១-សំណើលក់មូលបត្រដែលធ្វើឡើងចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប និង

២-សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមមធ្យោបាយណាក៏ដោយ រួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្រ។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្រជាឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះមក **គ.ម.ក.** ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលត្រូវរាយការណ៍ពីលទ្ធផល

ឱ្យបានឆាប់ជូន **គ.ម.ក.**។ ចំពោះបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានសំណើធ្វើប្រតិបត្តិការដាក់លក់ជាឯកជន បុគ្គលត្រូវរាយការណ៍ពីលទ្ធផលភ្លាមជូន **គ.ម.ក.**។

សំណើលក់មូលបត្រកម្មសិទ្ធិទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ អនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

### ប្រការ ៤.-

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១- ត្រូវអនុវត្តតាមលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មដែលកំណត់ដោយ **គ.ម.ក.**។

២- ត្រូវមានសកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច។

៣- ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Statements) និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Statements) រយៈពេល ២ (ពីរ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត និងរយៈពេល ១ (មួយ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំនោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុត្រីមាស។

៤- ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៥- ត្រូវមានឯកសារផ្តល់ព័ត៌មានដូចមានកំណត់ក្នុងប្រការ ៧ នៃប្រកាសនេះ។

### ប្រការ ៥.-

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវ÷

១- ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២- ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣- ដាក់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រកាសនេះ។

**ប្រការ ៦.-**

ក្រុមហ៊ុនបោះផ្សាយត្រូវសុំការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.** ដោយអនុលោមតាមមាត្រា១២ នៃច្បាប់ និងមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១៣ នៃអនុក្រឹត្យ។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចមានកំណត់ពីប្រការ ៧ ដល់ប្រការ ២៦ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិរបស់ក្រុមហ៊ុនបោះផ្សាយ និងនាយកហិរញ្ញវត្ថុ។

**ប្រការ ៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចខាងក្រោម÷

១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងសំណើបោះផ្សាយ

២- ព័ត៌មានស្តីពីកត្តាហានិភ័យ

៣- ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៤- ផែនការវិនិយោគ

៥- ការពិពណ៌នាអំពីធុរកិច្ច

៦- ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ

៧- ការពិពណ៌នាអំពីអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

៨- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

៩- ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក

១០- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

១១- ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១២- ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

១៣- សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

១៤- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥- ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦- កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧- ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

១៨- សិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩- ព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម។

**ប្រការ ៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវពណ៌នាអំពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ រួមទាំងព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយដូចខាងក្រោម÷

១- ឈ្មោះក្រុមហ៊ុនបោះផ្សាយ

២- ចំនួន និងប្រភេទមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយ

៣- តម្លៃលក់មូលបត្រកម្មសិទ្ធិក្នុងមួយឯកតា និងតម្លៃសរុប

៤- ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញ

៥- ថ្ងៃបើក និងថ្ងៃបិទការធ្វើបរិវិសកម្ម

៦- កាលបរិច្ឆេទចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

៧- សេចក្តីបញ្ជាក់ថា "ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ"។

**ប្រការ ៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីកត្តាហានិភ័យដូចខាងក្រោម÷

១- ហានិភ័យហិរញ្ញវត្ថុ

២- ហានិភ័យសេដ្ឋកិច្ច

៣- ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

៤- ហានិភ័យផ្សេងៗតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១០.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវប្រើប្រាស់សម្រាប់ធានាចំណាយលើកិច្ចសន្យានៃសកម្មភាពណាមួយរបស់ក្រុមហ៊ុនបោះផ្សាយ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ។

**ប្រការ ១១.-**

ករណីសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពាក់ព័ន្ធនឹងផែនការវិនិយោគ ឬមានពាក់ព័ន្ធនឹងផែនការវិនិយោគលើសពី ១ (មួយ) ផែនការនីមួយៗត្រូវបង្ហាញដាច់ពីគ្នាជាទម្រង់ពេញលេញក្នុងឯកសារផ្តល់ព័ត៌មាន។

**ប្រការ ១២.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការពិពណ៌នាអំពីធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ ដូចជា÷

១-កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម និងកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខណៈនៃធុរកិច្ចដែលក្រុមហ៊ុនបោះផ្សាយ និងសាខាក្រុមហ៊ុនបោះផ្សាយបានចូលរួម ឬនឹងចូលរួម។

២-ផលិតផលដែលជាទំនិញ ឬសេវាស្នូលរបស់ក្រុមហ៊ុនបោះផ្សាយ និងទីផ្សាររបស់ផលិតផលទាំងនោះនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៣-ទំហំនៃការលក់ផលិតផលផ្សេងទៀតដែលមិនមែនជាផលិតផលស្នូល ហើយទទួលបានប្រាក់ចំណូលលើសពី ១០ (ដប់) ភាគរយនៃប្រាក់ចំណូលសរុបរបស់ក្រុមហ៊ុនបោះផ្សាយ។

៤-ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងធុរកិច្ចស្នូលរបស់ក្រុមហ៊ុនទាំងនោះ។

៥-វិធីសាស្ត្រចែកចាយផលិតផល។

៦-ស្ថានភាពប្រកួតប្រជែងនៃធុរកិច្ចក្នុងទីផ្សារ។

៧-វត្ថុធាតុដើម ឬធាតុចូលផ្សេងៗដែលធានាដល់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងប្រភព និងអ្នកផ្គត់ផ្គង់។

៨-តម្រូវការថាមពល ឧស្ម័ន ទឹក ឬសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដែលចាំបាច់សម្រាប់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុន ដោយបញ្ជាក់ពីប្រភព។

៩-ឈ្មោះអតិថិជនដែលទិញផលិតផល ឬសេវារបស់ក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុប ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើរួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១០-ឈ្មោះអ្នកផ្គត់ផ្គង់ដែលលក់ផលិតផល ឬសេវាឱ្យក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃចំនួនទឹកប្រាក់សរុបលើផលិតផល ឬសេវាទាំងអស់ដែលបានទិញដោយក្រុមហ៊ុនបោះផ្សាយ ដោយ

បញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១១- ការពិពណ៌នាពីប្រកាសនីយបត្រតក្កកម្ម ម៉ាក ពាណិជ្ជនាម សិទ្ធិអាជីវកម្ម ឬកិច្ចព្រមព្រៀងផ្សេងទៀតពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា។

១២- ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិកធ្វើការពេញម៉ោង។

១៣- សក្តានុពលនៃសមត្ថភាពផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងបញ្ជាក់ពីកម្រិតសមត្ថភាពដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

១៤- ប្រសិនបើក្រុមហ៊ុនបោះផ្សាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពេញលេញស្តីពីប្រតិបត្តិការសំខាន់រវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង ដោយបញ្ជាក់ពីលក្ខណៈនៃប្រតិបត្តិការ និងចំនួនទឹកប្រាក់ដែលបានធ្វើក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ ១៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវពិពណ៌នាអំពីការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១- លទ្ធផលប្រតិបត្តិការ។

២- សន្ទនីយភាព និងប្រភពទុន។

៣- ការស្រាវជ្រាវ និងការអភិវឌ្ឍ។

៤- ព័ត៌មាននិន្នាការ និងការព្យាករណ៍ប្រាក់ចំណេញ និងលំហូរសាច់ប្រាក់ សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

**ប្រការ ១៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ពាក់ព័ន្ធនឹងអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម÷

១- ទីតាំងប្រតិបត្តិការ និងទីតាំងអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខខណ្ឌនៃអចលកម្មវត្ថុទាំងនោះ។

២- សេចក្តីបញ្ជាក់អំពីកម្មសិទ្ធិលើអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ។ ប្រសិនបើអចលកម្មវត្ថុទាំងនោះទទួលបានមកតាមរយៈការជួល ត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់នៃការជួល ព្រមទាំងឈ្មោះម្ចាស់អចលកម្មវត្ថុ។

៣- ការវាយតម្លៃលើអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយធ្វើឡើងដោយភ្នាក់ងារវាយតម្លៃដែលទទួល

បានការទទួលស្គាល់ពី **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ ប្រសិនមាន។

៤-ប្រសិនបើអចលកម្មរូបីដែលក្រុមហ៊ុនបោះផ្សាយកំពុងប្រើប្រាស់ជាប់នូវប្រាតិភោគភណ្ឌិក ក្រុមហ៊ុនបោះផ្សាយត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់ម្ចាស់ទ្រព្យនោះ ព្រមទាំងតម្លៃដើម និងតម្លៃបច្ចុប្បន្នរបស់ប្រាតិភោគភណ្ឌិក។

**ប្រការ ១៥.-**

ករណីមានការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ស្តីពីការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ដោយបង្ហាញនូវ÷

១-ព័ត៌មានសង្ខេបពីការវាយតម្លៃ ឬការវាយតម្លៃឡើងវិញ រួមមានតម្លៃទ្រព្យសកម្មមុនពេលធ្វើការវាយតម្លៃឡើងវិញ សមាសធាតុនៃទ្រព្យដែលបានវាយតម្លៃឡើងវិញ ដោយត្រូវដាក់ដោយឡែកក្នុងលក្ខណៈមួយដែលជួយសម្រួលដល់ការប្រៀបធៀបរវាងតម្លៃចារឹក និងតម្លៃដែលបង្ហាញក្រោយពីបានវាយតម្លៃឡើងវិញ និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

២-ហេតុផលនៃការវាយតម្លៃ ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ។

៣-អត្តសញ្ញាណ និងគុណវុឌ្ឍិរបស់ភ្នាក់ងារវាយតម្លៃ។

**ប្រការ ១៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក ដូចខាងក្រោម÷

១-ជីវប្រវត្តិសង្ខេប ដោយមានបញ្ជាក់ពីឈ្មោះ អាយុ គុណវុឌ្ឍិ បទពិសោធន៍ និងតំណែងរបស់អភិបាលម្នាក់ៗរបស់ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលដែលត្រូវបានតែងតាំងជាអភិបាល ដោយបង្ហាញពីអណត្តិនៃការតែងតាំង និងស្ថាប័នដែលបានតែងតាំងអភិបាលនោះ។

២-កាលបរិច្ឆេទក្លាយជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយជាលើកដំបូង និងកាលបរិច្ឆេទបញ្ចប់អណត្តិបច្ចុប្បន្ន។

៣-ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត ត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ។

៤-ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល និងបុគ្គលិកជាន់ខ្ពស់។

៥-ឈ្មោះ រួមទាំងតំណែង គុណវុឌ្ឍិអប់រំ កាលបរិច្ឆេទចូលរួមជាមួយក្រុមហ៊ុនបោះផ្សាយ បទពិសោធន៍ ៥ (ប្រាំ) ឆ្នាំចុងក្រោយរបស់អគ្គនាយក អគ្គនាយករង នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ លេខាធិការក្រុមហ៊ុន អ្នកប្រឹក្សាយោបល់ និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

៦-សេចក្ដីបញ្ជាក់អំពីអសាធនភាពរបស់ភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ភាគហ៊ុន ចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ។

ឯកសារផ្ដល់ព័ត៌មានត្រូវភ្ជាប់នូវឯកសារដូចខាងក្រោម÷

១-ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ។

២-របាយការណ៍របស់អភិបាលស្ដីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៧.-**

ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញអំពីការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ដែលបានកើតឡើងនៅក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំចុងក្រោយ ដូចខាងក្រោម÷

១-បណ្ដឹងពាក់ព័ន្ធនឹងក្ស័យធនធ្វើឡើងចំពោះក្រុមហ៊ុនដែលបុគ្គលិកជាន់ខ្ពស់ ឬអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់ជាអភិបាល បុគ្គលិក ឬជាសហកម្មសិទ្ធិករ។

២-ការផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៣-ការសម្រេចជាស្ថាពរ ឬជាបណ្ដោះអាសន្នរបស់តុលាការមានសមត្ថកិច្ចចំពោះអភិបាល បុគ្គលិកជាន់ខ្ពស់ ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

៤-ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

**ប្រការ ១៨.-**

ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញអំពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ ដោយពិពណ៌នាអំពីប្រតិបត្តិការសំខាន់ៗក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយផ្ដល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងបុគ្គលជាប់ពាក់-ព័ន្ធ ដូចខាងក្រោម÷

១-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ រួមទាំងអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត ក្រៅពីក្រុមហ៊ុនបោះ-ផ្សាយ និងអភិបាលដែលទទួលបានផលប្រយោជន៍ពីក្រុមហ៊ុនបោះផ្សាយ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

២-បុគ្គលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរនៅក្នុងទីផ្សារ។

៣-សមាជិកគ្រួសារផ្ទាល់របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤-បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ។

៥-បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុនបោះ-ផ្សាយ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម÷

១-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបានបើកឱ្យបុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូបរបស់ក្រុមហ៊ុនបោះផ្សាយ នៅឆ្នាំសារពើពន្ធចុងក្រោយ ដោយមានរាយនាម និងមុខតំណែងរបស់បុគ្គលិកជាន់ខ្ពស់បំផុតនោះ។

២-ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៣-ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៤-ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៥-ប្រសិនបើក្រុមហ៊ុនបោះផ្សាយមានបំណងបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុន នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធក្នុងការបង្កើននោះ។

**ប្រការ ២០.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិទិញមូលបត្រកម្មសិទ្ធិរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ដោយត្រូវបញ្ជាក់នូវ÷

១-កាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

២-ថ្លៃនៃមូលបត្រដែលត្រូវអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៣-ចំនួនមូលបត្រកម្មសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៤-ថ្លៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនៅកាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

៥-កាលបរិច្ឆេទអស់សុពលភាពនៃសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

**ប្រការ ២១.-**

ករណីក្រុមហ៊ុនបោះផ្សាយមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក ក្រុមហ៊ុនបោះផ្សាយត្រូវពិពណ៌នាក្នុងឯកសារផ្តល់ព័ត៌មាននូវឈ្មោះរបស់អភិបាល និងភាគហ៊ុនិក ប្រភេទ និងតម្លៃនៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យក្រុមហ៊ុនបោះផ្សាយ ដោយផ្ទាល់ ឬដោយប្រយោលក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

ប្រសិនបើក្រុមហ៊ុនបោះផ្សាយបានទិញ ឬនឹងទិញចលនទ្រព្យ និងអចលនទ្រព្យពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

**ប្រការ ២២.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមុន និងក្រោយការបោះផ្សាយ និងប្រាក់ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ នៅកាលបរិច្ឆេទនៃតារាងតុល្យការចុងក្រោយ។

**ប្រការ ២៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីកម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ក្រោមទម្រង់ជាតារាង នូវឈ្មោះរបស់បុគ្គលដែលកាន់កាប់ចាប់ពី ៥ (ប្រាំ) ភាគរយនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ដោយត្រូវបញ្ជាក់ពីចំនួន និងភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់។

ឯកសារផ្តល់ព័ត៌មានត្រូវមានតារាងដែលបង្ហាញពីចំនួនមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ដោយអភិបាលម្នាក់ៗ បុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូប ដោយបញ្ជាក់ឈ្មោះ និងអាសយដ្ឋាន ព្រមទាំងបុគ្គលិកផ្សេងទៀត ក្រោមរូបភាពជាសរុប ដោយត្រូវបញ្ជាក់ជាភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់ធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរនៅលើទីផ្សារ។

**ប្រការ ២៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការកំណត់នូវកត្តាដែលយកមកប្រើប្រាស់ ក្នុងការដាក់តម្លៃមូលបត្រកម្មសិទ្ធិ ដើម្បីធ្វើសំណើលក់។

**ប្រការ ២៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីសិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើ

លក់ ដូចខាងក្រោម÷

១-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ និងសិទ្ធិបោះឆ្នោតនៃមូលបត្រកម្មសិទ្ធិដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

២-ពិពណ៌នាសិទ្ធិទទួលភាគលាភ សិទ្ធិបោះឆ្នោត សិទ្ធិបរិវត្តន៍ និងសិទ្ធិជិរះបញ្ជី ព្រមទាំងមូលនិធិសម្រាប់ទូទាត់សងភាគហ៊ុនបុរិមាដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

៣-ប្រសិនបើមានការដាក់កំហិតណាមួយលើការបង់ភាគលាភទៅឱ្យអ្នកកាន់កាប់មូលបត្រកម្មសិទ្ធិដោយសារកិច្ចសន្យាបំណុលពាក់ព័ន្ធ ត្រូវពន្យល់ពីការដាក់កំហិតនោះ។

៤-ពិពណ៌នាពីសិទ្ធិសំខាន់ផ្សេងៗទៀតរបស់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Information) និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Information) ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្មស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២៧.-**

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្តីថ្លែង ឬរបាយការណ៍ ឬយោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្តីថ្លែង របាយការណ៍ ឬយោបល់ដែលបានផ្តល់ឱ្យនោះ។

**ប្រការ ២៨.-**

ក្រុមហ៊ុនបោះផ្សាយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្តល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

**ប្រការ ២៩ .-**

ក្រុមហ៊ុនបោះផ្សាយត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ នូវឯកសារដូចខាងក្រោម÷

១-លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៣- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៤- លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃក្រុមហ៊ុនបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៥- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន។

៦- កិច្ចសន្យាដែលត្រូវប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ប្រសិនមាន។

៧- ផែនការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយសម្រាប់រយៈពេលយ៉ាងតិច ១ (មួយ) ឆ្នាំ។

៨- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៩- កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១០- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence Report) ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១១- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១២- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១៣- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។

១៤- កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនមាន។

១៥- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ ចេញដោយក្រុមហ៊ុនគណនេយ្យជំនាញដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ករណីរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ ៤ ខាងលើ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនគណនេយ្យដែលមិនមានការទទួលស្គាល់ពី **គ.ម.ក.** ។

១៦- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់បំពេញ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.** ។

១៧- ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

**ប្រការ ៣០.-**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយផ្តល់ឯកសារផ្តល់ព័ត៌មានបន្ថែម ឬឯកសារផ្តល់ព័ត៌មានជំនួស ឬសេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ។ ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញតាមសំណើនេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ

**គ.ម.ក.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីក្រុមហ៊ុនបោះផ្សាយមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៣១.-**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយ ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

១-ក្រុមហ៊ុនបោះផ្សាយមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

២-ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៣-ក្រុមហ៊ុនបោះផ្សាយស្ថិតនៅក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤-ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយទូទាត់សងបំណុល។

៥-ក្រុមហ៊ុនបោះផ្សាយ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ៖

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមអនុក្រឹត្យ។

ខ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលត្រូវបានប្រកាសក្ស័យធន នៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-ស្ថានភាពហិរញ្ញវត្ថុឬវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមិនទាន់មានលក្ខណៈគ្រប់គ្រាន់

ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨-នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ÷

ក-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយមិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ-មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩-ការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនបោះផ្សាយ នឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

**ប្រការ ៣២.-**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនបោះផ្សាយ ពីការមិនយល់ព្រម ឬការយល់ព្រមជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្នុងរយៈពេល ២(ពីរ) ខែគិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

## ជំពូកទី ៣
## ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**ប្រការ ៣៣.-**

ក្រុមហ៊ុនបោះផ្សាយដែលទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបាន បន្ទាប់ពី÷

១-បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។

២-បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

៣-បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយពី **គ.ម.ក.**។

**ប្រការ ៣៤.-**

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព សម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មនោះភ្លាមមក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យ។ ចំនួន និងបញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្ម បានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤"ខ" នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣៨ និងប្រការ ៣៩ នៃប្រកាសនេះ។

**ប្រការ ៣៥.-**

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចដែលមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ឱ្យក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់មក **គ.ម.ក.** ភ្លាម។

**ប្រការ ៣៦.-**

ការធ្វើបរិវិសកម្មត្រូវបានកំណត់ដូចខាងក្រោម÷

១-២០ (ម្ភៃ) ភាគរយនៃសំណើលក់ជាសាធារណៈសរុប ត្រូវបានបម្រុងសម្រាប់អ្នកវិនិយោគសញ្ជាតិខ្មែរ។

២-៨០ (ប៉ែតសិប) ភាគរយដែលនៅសល់ត្រូវបើកចំហចំពោះអ្នកវិនិយោគសញ្ជាតិខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចធ្វើការកំណត់នូវការបែងចែកឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៣៧.-**

ក្រុមហ៊ុនមូលបត្រត្រូវចែកចាយលក់មូលបត្រកម្មសិទ្ធិក្នុងថ្លៃដែលបានកំណត់នៅក្នុងឯកសារផ្តល់-

ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។

ក្រុមហ៊ុនបោះផ្សាយ ឬភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្ម។

**ប្រការ ៣៨.-**

អនុលោមតាមមាត្រា ២១ នៃច្បាប់ ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីនេះក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រ និងជូនដំណឹងអំពីការព្យួរនេះភ្លាមដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មថាអាចមានសិទ្ធិដកស្ទីការដែលបានធ្វើចំពោះសំណើលក់មូលបត្រជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មឡើងវិញ បន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៩.-**

ក្រុមហ៊ុនបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមៗអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មានដល់សាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម÷

១-លេខស៊េរី និងកាលបរិច្ឆេទនៃការសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀបទូទាត់នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះត្រូវធ្វើឡើងយ៉ាងយូរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤០.-**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មានអាចត្រូវបានលុបចោលផងដែរ ក្នុងករណីដែលការធ្វើបរិវិសកម្មមិនបានជោគជ័យ។

**ប្រការ ៤១.-**

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារ-

ណៈដែលត្រូវធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែក ដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ នៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ៤២.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤៣.-**

ក្រុមហ៊ុនបោះផ្សាយត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់ និងអនុក្រឹត្យ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី ៤
## ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៤៤.-**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

មុននឹងទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចធ្វើសកម្មភាពទំនាក់ទំនងជាមួយអ្នកវិនិយោគសក្តានុពលដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ អំពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវភ្ជាប់មកជាមួយបញ្ជីឈ្មោះអ្នកវិនិយោគទាំងនោះ ព្រមទាំងឯកសារពាក់ព័ន្ធ។

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយព័ត៌មាន រួមទាំងរ៉ូដសូ (Road Show) និងប្រកាសផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការកំណត់ថ្លៃលក់មូលបត្រ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

ក្រុមហ៊ុនបោះផ្សាយត្រូវត្រៀមឯកសារផ្តល់ព័ត៌មានសម្រាប់ផ្តល់ឱ្យសាធារណជន នៅក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ប្រតិបត្តិករទីផ្សារមូលបត្រ និងនៅ **គ.ម.ក.** ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤៥.-**

រយៈពេលយ៉ាងតិច ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការតាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម÷

១- ឈ្មោះ និងប្រទេស ឬស្ថាប័នដទៃទៀត របស់ក្រុមហ៊ុនបោះផ្សាយ។

២- ចំនួន និងឈ្មោះមូលបត្រកម្មសិទ្ធិដែលនឹងត្រូវធ្វើសំណើលក់។

៣- ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

៤- កាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសាធារណៈនៃការជូនដំណឹងអំពីការធ្វើបរិវិសកម្មជាផ្លូវការ។

៥- សេចក្តីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិត្រូវបានទទួលការអនុញ្ញាតពី **គ.ម.ក.** រួចហើយ។

៦- សេចក្តីថ្លែងដើម្បីឱ្យសាធារណជនដឹងថា ការជូនដំណឹងជាផ្លូវការនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិឡើយ។

៧- កាលបរិច្ឆេទដែលការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនឹងចាប់ផ្តើម។

៨- សេចក្តីថ្លែងដែលបញ្ជាក់ថា អ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវពិចារណាដោយផ្អែកទៅលើឯកសារផ្តល់ព័ត៌មាន។

ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមពីនេះក្រុមហ៊ុនបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិច ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិចឱ្យដូចគ្នានឹងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៥
## កម្រៃសេវាក្នុងការចុះបញ្ជី

**ប្រការ ៤៦.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១- ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១២.០០០.០០០

(ដប់ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤.០០០.០០០(បួនលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៧**.-

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែមត្រូវបង់ប្រាក់ចំនួន ៨០០.០០០ (ប្រាំបីរយពាន់) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤០០.០០០ (បួនរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៨**.-

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំពិនិត្យឡើងវិញលើឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៩.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាដូចមានចែងក្នុងប្រការ ៤៦ ប្រការ ៤៧ និងប្រការ ៤៨ នៃប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យក្រុមហ៊ុនបោះផ្សាយវិញឡើយ ទោះជាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជី ឬត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**ប្រការ ៥០.-**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលពីអគ្គនាយកនៃ **គ.ម.ក.** ដូចខាងក្រោម÷

១- ការស្នើឱ្យដាក់អនុស្សារណៈ។

២- ការព្រមាន ឬដាស់តឿន។

៣- ការកត់សម្គាល់ជាសាធារណៈហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤- ការដាក់កំហិតលើការបោះផ្សាយមូលបត្រកម្មសិទ្ធិ។

៥- ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦- ការប្រកាសជាសាធារណៈនូវទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧- ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬការចែកចាយបន្ទាប់។

**ប្រការ ៥១.-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀលដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ ៥២.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួល

ដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធអ្នកចូលរួមក្នុងទីផ្សារមូលបត្រប្រតិស្រុត និងសាធារណជន។

**ប្រការ ៥៣.-**

ប្រកាសនេះត្រូវជំនួសប្រកាសលេខ ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៥៤.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤៖

# គោលការណ៍ណែនាំស្តីពីយន្តការ
# នៃការបោះផ្សាយលក់មូលបត្រ
# កម្មសិទ្ធិជាសាធារណៈលើកដំបូង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:......០០១..........គ.ម.ក/ស.ណ.ន

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១១*

# គោលការណ៍ណែនាំ

# ស្តីពី

# យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០១ គ.ម.ក.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក)** សូមធ្វើការណែនាំនូវយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមាន ដូចខាងក្រោម÷

**១-** *ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក **គ.ម.ក.** ដែលលិខិតមានខ្លឹមសារ ០៣ ចំណុច ដូចខាងក្រោម:

១- គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)

២- គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)

៣- ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

*២- ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ*

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

*៣- ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO Team)*

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការតែងតាំង បុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

*៤- ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)*

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះ ត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ ។

*៥- ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារ ស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ។

*៦- ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក.*

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក.។ គ.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជូនក្រុមហ៊ុនបោះផ្សាយ។

*៧- ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង (Book Building)*

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

*៨- ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

*៩- ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ (Term of Offer) និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក.*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូនគ.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**១០**- *ការធ្វើបរិវិសកម្មមូលបត្រ (Subscription)*

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី **គ.ម.ក.** ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៣ និង ជំពូកទី ៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**១១**- *ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះ ភ្លាមជូន **គ.ម.ក.**។

**១២**- *ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិ ទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**គណៈកម្មការមូលបត្រកម្ពុជា**

# ឧបសម្ព័ន្ធទី៥៖

# ទម្រង់ពាក្យស្នើសុំបោះផ្សាយលក់
# មូលបត្រកម្មសិទ្ធិជាសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:..........................គ.ម.ក

# ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ[១]

## ផ្នែកទី ១: ព័ត៌មានទូទៅ

### ១- ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

ឈ្មោះជាអក្សរខ្មែរ: ____________________

ឈ្មោះជាអក្សរឡាតាំង: ____________________

ឈ្មោះជាអក្សរកាត់: ____________________

ប្រភេទធុរកិច្ចជាភាសាខ្មែរ: ____________________

ប្រភេទធុរកិច្ចជាភាសាអង់គ្លេស: ____________________

អាសយដ្ឋានទីស្នាក់ការចុះបញ្ជី: ____________________

លេខទូរស័ព្ទ: ____________ លេខទូរសារ: ____________

គេហទំព័រ: ____________ អ៊ីម៉ែល: ____________

កាលបរិច្ឆេទចាប់ផ្តើមដំណើរការអាជីវកម្ម: ______/______/______

លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម: ____________________

______________

១ពាក្យស្នើសុំនេះ ត្រូវដាក់ជូន គ.ម.ក. ដោយភ្ជាប់មកជាមួយនូវឯកសារផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងទៀត។



អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម: ____________/____________/ ________________________

លេខអាជ្ញាបណ្ណអាជីវកម្ម: ________________ ចេញដោយ: ________________________

សុពលភាពអាជ្ញាបណ្ណអាជីវកម្ម ពីថ្ងៃទី: ______/______/______ ដល់ថ្ងៃទី: ______/______/______

លេខអត្តសញ្ញាណកម្មសារពើពន្ធ: ________________________________________

**២- ព័ត៌មានអំពីបុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន**

ឈ្មោះជាអក្សរខ្មែរ: ________________________________________

ឈ្មោះជាអក្សរឡាតាំង: ________________________________________

លេខអត្តសញ្ញាណប័ណ្ណ /លេខលិខិតឆ្លងដែន: ________________________

មុខតំណែង: ________________________________________

អាសយដ្ឋាន: ________________________________________

លេខទូរស័ព្ទ: ________________ លេខទូរសារ: ________________

លេខទូរស័ព្ទដៃ: ________________ អ៊ីម៉ែល: ________________

**ផ្នែកទី ២: ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិ**

| | |
|---|---|
| ឈ្មោះមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់ | |
| ប្រភេទមូលបត្រកម្មសិទ្ធិ | |
| ថ្នាក់មូលបត្រកម្មសិទ្ធិ | |
| ថ្លៃលក់ | |
| ចំនួនមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់ | |
| ចំនួនទឹកប្រាក់សរុបពីការបោះផ្សាយ | |

**ផ្នែកទី ៣: មូលធនភាគហ៊ុនិក និងចំណេញភាព**

| បរិយាយ | ទឹកប្រាក់ជារៀល | ទឹកប្រាក់ជាដុល្លារ |
|---|---|---|
| មូលធនភាគហ៊ុនិកសរុបនៅកាលបរិច្ឆេទដាក់ពាក្យស្នើសុំ | | |

| | | |
|---|---|---|
| ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ | | |
| ចំណេញសុទ្ធក្នុងរយៈពេលបីឆ្នាំចុងក្រោយ | | |

*សូមផ្តល់នូវអត្រាប្តូរប្រាក់ដូចគ្នានឹងអត្រាដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។*

## ផ្នែកទី ៤: រចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន និងភាគហ៊ុនិក

១- សូមភ្ជាប់មកជាមួយនូវរចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនដោយបញ្ជាក់ដូចខាងក្រោម៖ រចនាសម្ព័ន្ធជាក្រុម

- ភាគរយនៃភាគហ៊ុនរបស់ក្រុមនីមួយៗ
- សកម្មភាពធុរកិច្ចគោលរបស់ក្រុមនីមួយៗ

២- បញ្ជីភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ៖

| ល.រ. | ឈ្មោះភាគហ៊ុនិក | ចំនួនភាគហ៊ុន | ភាគរយ | ថ្នាក់មូលបត្រ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

*សូមភ្ជាប់នូវបញ្ជីតាមទម្រង់នេះ ករណីភាគហ៊ុនិកកាន់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយ មានចំនួនលើសពីនេះ។*

## ផ្នែកទី ៥: ព័ត៌មានអំពីអភិបាល

បំពេញព័ត៌មានពាក់ព័ន្ធនឹងអភិបាលដូចខាងក្រោម៖

| ល.រ. | ឈ្មោះអភិបាល | ប្រភេទអភិបាល | លេខអត្តសញ្ញាណប័ណ្ណ / លេខលិខិតឆ្លងដែន | សេចក្តីលម្អិតពីលិខិតឆ្លងដែន | | កាលបរិច្ឆេទតែងតាំង |
|---|---|---|---|---|---|---|
| | | | | កាលបរិច្ឆេទអស់សុពលភាព | ចេញដោយប្រទេស | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |

*សូមភ្ជាប់នូវព័ត៌មានតាមទម្រង់នេះ ករណីអភិបាលមានចំនួនលើសពីនេះ។*

## ផ្នែកទី ៦: ព័ត៌មានអំពីបុគ្គលិកជាន់ខ្ពស់

បំពេញព័ត៌មានពាក់ព័ន្ធនឹងបុគ្គលិកជាន់ខ្ពស់ដូចខាងក្រោម:

| ល.រ. | ឈ្មោះបុគ្គលិកជាន់ខ្ពស់ | មុខតំណែង | លេខអត្តសញ្ញាណប័ណ្ណ /លេខលិខិតឆ្លងដែន | សេចក្តីលម្អិតពីលិខិតឆ្លងដែន | | កាលបរិច្ឆេទតែងតាំង |
|---|---|---|---|---|---|---|
| | | | | កាលបរិច្ឆេទអស់សុពលភាព | ចេញដោយប្រទេស | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

*សូមភ្ជាប់នូវព័ត៌មានតាមទម្រង់នេះ ករណីបុគ្គលិកជាន់ខ្ពស់មានចំនួនលើសពីនេះ។*

## ផ្នែកទី ៧: ព័ត៌មានអំពីក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ

១- តើក្រុមហ៊ុនបោះផ្សាយ មានក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធដែរឬទេ?

□ មាន □ គ្មាន

ប្រសិនមាន សូមផ្តល់នូវព័ត៌មានដូចខាងក្រោម:

| ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | លេខអាជ្ញាបណ្ណ ឬ លេខចុះបញ្ជី | កាលបរិច្ឆេទក្លាយជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

*សូមភ្ជាប់នូវព័ត៌មានដូចទម្រង់ខាងលើ ករណីក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ មានចំនួនលើសពីនេះ។*

២- តើក្រុមហ៊ុនបោះផ្សាយ ជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធដទៃដែរឬទេ?

□ មែន □ មិនមែន

ប្រសិនបើមែន សូមផ្តល់នូវព័ត៌មានដូចខាងក្រោម៖

| ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយ % | កាលបរិច្ឆេទក្លាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

**ផ្នែកទី ៨: ព័ត៌មានអំពីការបោះផ្សាយមូលបត្រជាសាធារណៈពីមុន**

តើក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែរឬទេ?

□ ធ្លាប់ សូមបំពេញនូវតារាងខាងក្រោម

□ មិនធ្លាប់

ឈ្មោះមូលបត្រកម្មសិទ្ធិ ______________________________

ថ្ងៃលក់: ______________________________

ចំនួនមូលបត្រកម្មសិទ្ធិ: ______________________________

ទឹកប្រាក់សរុប: ______________________________

កាលបរិច្ឆេទចុះបញ្ជីពីមុន: ______________________________

ទីកន្លែងជួញដូរ: ______________________________

## ផ្នែកទី ៩: ព័ត៌មានអំពីការបដិសេធឯកសារផ្តល់ព័ត៌មាន

តើក្រុមហ៊ុនធ្លាប់ត្រូវបានបដិសេធឯកសារផ្តល់ព័ត៌មានដែរឬទេ?

□ ធ្លាប់ សូមបំពេញនូវតារាងខាងក្រោម

□ មិនធ្លាប់

| ឈ្មោះអាជ្ញាធរ | ប្រភេទនៃការបដិសេធ | ហេតុផលនៃការបដិសេធ | លេខយោង |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ផ្នែកទី ១០: ព័ត៌មានអំពីភាគីពាក់ព័ន្ធ

**១- ក្រុមហ៊ុនគណនេយ្យជំនាញ:** ______________________________

កាលបរិច្ឆេទតែងតាំង __________/__________/__________

សុពលភាពនៃការទទួលស្គាល់ដោយ **គ.ម.ក.**ពីថ្ងៃទី:_____/_____/_____ ដល់ថ្ងៃទី:_____/_____/_____

**២- ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ:** ______________________________

កាលបរិច្ឆេទតែងតាំង __________/__________/__________

សុពលភាពនៃអាជ្ញាបណ្ណ ពីថ្ងៃទី:_____/_____/_____ ដល់ថ្ងៃទី:_____/_____/_____

៣- **មេធាវី** ____________________

កាលបរិច្ឆេទតែងតាំង ______/______/______

សុពលភាពនៃការទទួលស្គាល់ដោយ **គ.ម.ក.**ពីថ្ងៃទី:____/____/____ ដល់ថ្ងៃទី:____/____/____

៤- **ក្រុមហ៊ុនផ្ដល់សេវាវាយតម្លៃ** ____________________

កាលបរិច្ឆេទតែងតាំង ______/______/______

សុពលភាពនៃការទទួលស្គាល់ដោយ **គ.ម.ក.**ពីថ្ងៃទី:____/____/____ ដល់ថ្ងៃទី:____/____/____

## ផ្នែកទី ១១: ឯកសារភ្ជាប់

បុគ្គលដែលស្នើសុំធ្វើសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវភ្ជាប់មកជាមួយនឹងពាក្យស្នើសុំនូវឯកសារដូចខាងក្រោម:

១- ឯកសារផ្ដល់ព័ត៌មាន ដែលរៀបចំឡើងដោយអនុលោមតាមប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

២- វិញ្ញាបនបត្របញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិពីទីផ្សារមូលបត្រប្រតិស្រុត។

៣- លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

៤- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

៥- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៦- លិខិតប្រគល់សិទ្ធិដោយមានបញ្ជាក់ពីតួនាទី និងភារកិច្ចជាអភិបាល ឬនាយកប្រតិបត្តិ ក្នុងការបម្រើការងារនៅក្នុងក្រុមហ៊ុនបោះផ្សាយ ដោយមានការចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៧- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗ (ប្រសិនបើមាន)។

៨- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជស្ដីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៩- កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១០- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្ម ជានាទិញមូលបត្រ។

១១- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១២- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១៣- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។

១៤- កិច្ចព្រមព្រៀងវិនិយោគចម្រុះសំខាន់ៗ ប្រសិនបើមាន។

១៥- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជ ឬលិខិតបញ្ជាក់ពីសវនករនូវចំនួនទឹកប្រាក់តម្កល់សម្រាប់ធ្វើជាមូលធន។

១៦- របាយការណ៍អនុសាសន៍ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់សវនករឯករាជ្យដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

១៧- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនគណនេយ្យជំនាញដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

១៨- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

១៩- បញ្ជីរាយនាមអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនដែលមានលក្ខណៈបច្ចុប្បន្នភាពដោយភ្ជាប់មកជាមួយប្រវត្តិរូបសង្ខេបរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដោយបញ្ជាក់ពីរយៈពេលបំពេញការងារ និងបទពិសោធន៍ការងារ។

២០- លិខិតផ្ទេរសិទ្ធិជូនបុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន។

២១- អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនថតចម្លង របស់បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន។

២២- ប្រវត្តិរូបសង្ខេបរបស់បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន ដោយបញ្ជាក់ពីរយៈពេលបំពេញការងារ និងបទពិសោធន៍ការងារ។

២៣- បញ្ជីរាយនាម និងអត្តសញ្ញាណរបស់ភាគហ៊ុនិកដែលមានលក្ខណៈបច្ចុប្បន្នភាព។

២៤- ឯកសារភ្ជាប់ផ្សេងៗទៀត តាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ផ្នែកទី ១២: សេចក្តីប្រកាស និងកិច្ចសន្យារបស់បុគ្គលដាក់ពាក្យស្នើសុំ**

- ក្រុមហ៊ុនសូមអះអាងថា រាល់ព័ត៌មានដែលបានផ្តល់នៅក្នុងពាក្យស្នើសុំ (រួមមានរាល់ព័ត៌មានពាក់ព័ន្ធ និងឯកសារភ្ជាប់) មានលក្ខណៈពេញលេញ ពិតប្រាកដ និងត្រឹមត្រូវ។
- ក្រុមហ៊ុនសូមអះអាងថា ក្រុមប្រឹក្សាភិបាលបានផ្តល់សេចក្តីសម្រេចយល់ព្រមលើពាក្យស្នើសុំនេះ។

- ក្រុមហ៊ុនដឹងថា ការផ្តល់ព័ត៌មានខុស ឬព័ត៌មានដែលនាំឱ្យយល់ខុសដែលភ្ជាប់មកជាមួយនឹងពាក្យស្នើសុំសម្រាប់ចុះបញ្ជីគឺជាបទល្មើសដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។
- ក្រុមហ៊ុនដឹងថា **គ.ម.ក.** មានសមត្ថកិច្ចគ្រប់ពេលវេលាក្នុងការចាត់វិធានការណ៍ចំពោះការក្លែងបន្លំព័ត៌មាន នៅក្នុងឯកសារផ្តល់ព័ត៌មាន ឯកសារភ្ជាប់ និងពាក្យស្នើសុំ។
- ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមមក **គ.ម.ក.** ប្រសិនបើមានការផ្លាស់ប្តូរពាក់ព័ន្ធនឹងឯកសារផ្តល់ព័ត៌មាន ឯកសារភ្ជាប់ និងពាក្យស្នើសុំ មុនពេលពាក្យស្នើសុំទទួលបានការយល់ព្រម។

## ផ្នែកទី ១៣: ការបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត

ពាក្យស្នើសុំការទទួលស្គាល់ត្រូវភ្ជាប់មកជាមួយនូវវិក្កយបត្រ ជាសាច់ប្រាក់ចំនួន ១២.០០០.០០០(ដប់ពីរលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬជាសាច់ប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម សម្រាប់ពាក្យស្នើសុំ និងសោហ៊ុយសិក្សានិងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ដោយយោងតាមប្រការ ៤៧ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

រាជធានីភ្នំពេញ ថ្ងៃទី :____/______/______

ហត្ថលេខា និងត្រា

ឈ្មោះ:................

(បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន)